ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍
MINISTRY OF TOURISM

កម្ពុជា
ព្រះរាជាណាចក្រអច្ឆរិយៈ
ផ្តល់ភាពកក់ក្តៅ



# ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម
# ២០២១-២០២៥
# ខេត្តមណ្ឌលគិរី


រៀបចំដោយ ៖ មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី

សហការជាមួយ ៖ នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍


ខ្ញុំ
មណ្ឌលគិរី






ការអភិវឌ្ឍសម្បទាទេសចរណ៍ខេត្តមណ្ឌលគិរី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរី

រៀបចំដោយ ៖ មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី
សហការជាមួយ ៖ នាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍







# សារលិខិត

## ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី

ក្នុងនាមគណៈអភិបាលខេត្ត គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និងបិតិសោមនស្សរីករាយដើម្បីបង្ហាញជូននូវផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរី ដែលជាឯកសារគ្រឹះសម្រាប់ជាត្រីវិស័យក្នុងការចង្អុលបង្ហាញពីក្របខណ្ឌអភិវឌ្ឍន៍ខេត្ត និងរាល់គម្រោងអាទិភាពសម្រាប់រយៈពេលប្រាំឆ្នាំក្នុងវិស័យទេសចរណ៍ ដោយសំដៅទៅលើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរី បានកំណត់ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រអភិវឌ្ឍន៍ច្បាស់លាស់ និងផែនការសកម្មភាពសម្រាប់ដាក់ជូនដល់រាជរដ្ឋាភិបាលកម្ពុជា ក្រសួង ស្ថាប័ន ភ្នាក់ងារអភិវឌ្ឍន៍នានា អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ ដើម្បីគៀងគរធនធាន និងការគាំទ្ររាល់គម្រោងដែលបានលើកឡើងក្នុងផែនការនេះ ។

ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្មនេះ បានបង្ហាញពីសក្តានុពលទេសចរណ៍ខេត្តមណ្ឌលគិរី ដ៏សំបូរបែប និងមានលក្ខណៈពិសេសដោយមានស្ថានភាពភូមិសាស្ត្រមានលក្ខណៈអំណោយផល និងល្អវិសេសវិសាល ប្រភពធនធានធម្មជាតិដែលមានលក្ខណៈល្អប្លែក ជាពិសេសទឹកជ្រោះប៊ូស្រាដែលមានសម្រស់ដ៏ល្អប្រណិតធនធានធម្មជាតិប្លែកៗនិងវប្បធម៌ជនជាតិដើមភាគតិចព្នងសម្រាប់បម្រើឲ្យវិស័យទេសចរណ៍នៅក្នុងខេត្តទាំងមូលក៏ដូចជាការចូលរួមអំពាវនាវគៀងគរដល់អ្នកវិនិយោគអង្គការក្រៅរដ្ឋាភិបាល ផ្នែកសាធារណៈ វិស័យឯកជន ចូលរួមអនុវត្តប្រកបស្មារតីទទួលខុសត្រូវខ្ពស់ជាពិសេសដោះស្រាយបញ្ហាចំពោះមុខនៅក្នុងបរិបទកូវីដ-១៩ ។

ក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងខ្ញុំសូមគាំទ្រយ៉ាងពេញទំហឹង ចំពោះការខិតខំប្រឹងប្រែងរបស់មន្ទីរទេសចរណ៍ខេត្ត ដែលបានសហការសម្របសម្រួលបង្កើតជាឯកសារផែនការនេះ និងសូមអំពាវនាវឱ្យមានការគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ ភ្នាក់ងារអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ ក្រសួង ស្ថាប័ន ម្ចាស់ជំនួយ វិស័យឯកជនទាំងអស់ និងសូមដាក់ជូននូវផែនការដ៏ល្អនេះសម្រាប់ប្រើប្រាស់ជាត្រីវិស័យក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ដើម្បីចូលរួមលើកស្ទួយសេដ្ឋកិច្ចសង្គម ។

ថ្ងៃ...ពុធ...១១កើត.... ខែ...មិគសិរ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

មណ្ឌលគិរី ថ្ងៃទី...១៥... ខែ...ធ្នូ.........ឆ្នាំ២០២១

**អភិបាលខេត្ត**

**ថង សាវុន**

# អារម្ភកថា

## របស់ប្រធានមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី

ក្នុងនាមថ្នាក់ដឹកនាំមន្ទីរសទេសចរណ៍ខេត្តមណ្ឌលគិរី និងមន្ត្រីរាជការក្រោមឱវាទ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះឯកឧត្តម បណ្ឌិត **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងឯកឧត្តម **ថង សាវុន** អភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ដែលជានិច្ចកាលតែងយកចិត្តទុកដាក់ក្នុងការគាំទ្រ និងអនុម័តផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរី ដែលជាឯកសារដ៏មានសារៈសំខាន់ និងជាត្រីវិស័យចង្អុលបង្ហាញការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរីប្រកបដោយនិរន្តរភាព គុណភាព និងការទទួលខុសត្រូវ ។

ឯកសារផែនការនេះ បានបង្ហាញនូវចក្ខុវិស័យច្បាស់លាស់សម្រាប់អនាគតនៃការអភិវឌ្ឍវិស័យទេសចរណ៍នៅខេត្តមណ្ឌលគិរី ដោយផ្តោតសំខាន់ទៅលើទិសដៅយុទ្ធសាស្រ្តទាំង៨ រួមមានៈ ការអភិវឌ្ឍផលិតផលទេសចរណ៍ និងគុណភាពសេវាកម្ម ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង ការអភិវឌ្ឍធនធានមនុស្ស និងសមភាពយេនឌ័រក្នុងវិស័យ ទេសចរណ៍ ការវិនិយោគក្នុងវិស័យឧស្សាហកម្មទេសចរណ៍ និងការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ ព្រមជាមួយនេះ ផែនការក៏បានចង្អុលបង្ហាញពីការសិក្សាអំពីបញ្ហាប្រឈម ចំណុចខ្លាំង កាលានុវត្តន៍ភាព និងការដាក់ចេញនូវយុទ្ធសាស្រ្ត វិធានការ ផែនការ និងមានយន្តការគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តដើម្បីអនុវត្ត។

ក្នុងនាមមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី និងមន្ត្រីក្រោមឱវាទទាំងអស់ សូមប្តេជ្ញាយ៉ាងម៉ឺងម៉ាត់បង្កើនកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគី និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ វិស័យឯកជន អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ដើម្បីជំរុញអនុវត្តផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរី នេះឲ្យទទួលបានជោគជ័យ និងសូមអំពាវនាវឲ្យមានការចូលរួមយ៉ាងសកម្មពីផ្នែកឯកជន ក្នុងការផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ក្នុងខេត្ត ដើម្បីទាក់ទាញទេសចរឲ្យបានច្រើនបន្ថែមទៀតក្នុងគោលបំណងពន្យាពេលស្នាក់នៅ បង្កើនចំណូល រួមចំណែកលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសហគមន៍ ។

ថ្ងៃ...ចន្ទ...៥...កើត ខែ...មិគសិរ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

មណ្ឌលគិរី ថ្ងៃទី...១៣...ខែ...មិថុនា...ឆ្នាំ២០២១

**ប្រធានមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី**

[illegible]

**ឋិន សុទិមាន**

# មាតិកា


**សារលិខិតរបស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី** ................................ I

**អារម្ភកថារបស់ប្រធានមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី** ................................ II

**ផែនទីទេសចរណ៍ខេត្តមណ្ឌលគិរី** ................................ 1

I. **សេចក្តីផ្តើម** ................................ 3

II. **ការវិភាគស្ថានភាពទេសចរណ៍** ................................ 5

២.១ សភាពការណ៍ទេសចរណ៍កម្ពុជា ................................ 5

២.២ សភាពការណ៍ទេសចរណ៍ខេត្តមណ្ឌលគិរី ................................ 6

២.៣ ស្ថានភាពភូមិសាស្ត្រខេត្តមណ្ឌលគិរី ................................ 8

២.៣.១ ប្រវត្តិខេត្តមណ្ឌលគិរី ................................ 8

២.៣.២ ភូមិសាស្ត្រទូទៅខេត្តមណ្ឌលគិរី ................................ 8

២.៤ សម្បទា និងសេវាកម្មទេសចរណ៍ខេត្តមណ្ឌលគិរី ................................ 9

២.៤.១ ផលិតផល និងការទាក់ទាញទេសចរណ៍ ................................ 9

២.៤.២ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ................................ 16

២.៤.៣ មគ្គុទ្ទេសក៍ទេសចរណ៍ ................................ 16

២.៤.៤ សេវាកម្មលក់ដូរវត្ថុអនុស្សាវរីយ៍ ................................ 17

២.៤.៥ យេនឌ័រក្នុងវិស័យទេសចរណ៍ ................................ 17

២.៥ ការវិភាគចំណុចខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង ................................ 18

III. **ចក្ខុវិស័យ** ................................ 21

IV. **គោលបំណង និងគោលដៅនៃការអភិវឌ្ឍ** ................................ 24

V. **ក្របខ័ណ្ឌអភិវឌ្ឍន៍ទេសចរណ៍** ................................ 27

៥.១ ការវិភាគការអភិវឌ្ឍទេសចរណ៍ ................................ 27

៥.១.១ ការអភិវឌ្ឍផលិតផលទេសចរណ៍ និងពង្រឹងគុណភាពសេវាកម្ម ................................ 27

៥.១.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ ................................ 28

៥.១.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍ ................................ 28

៥.១.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន ................................ 29

៥.១.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង ................................ 31

៥.១.៦ ការអភិវឌ្ឍធនធានមនុស្ស និងសមាសភាពយេនឌ័រក្នុងវិស័យទេសចរណ៍ ................................ 31

៥.១.៧ ការវិនិយោគក្នុងវិស័យឧស្សាហកម្មទេសចរណ៍ ................................ 32

៥.១.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ ................................ 32

**៥.២ ទិសដៅអភិវឌ្ឍន៍ទេសចរណ៍** ...33
៥.២.១ ការអភិវឌ្ឍផលិតផលទេសចរណ៍ និងពង្រឹងគុណភាពសេវាកម្ម ...33
៥.២.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ ...38
៥.២.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍ ...38
៥.២.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន ...39
៥.២.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង ...41
៥.២.៦ ការអភិវឌ្ឍធនធានមនុស្ស និងសមាសភាពយេនឌ័រក្នុងវិស័យទេសចរណ៍ ...43
៥.២.៧ ការវិនិយោគក្នុងវិស័យទេសចរណ៍ ...43
៥.២.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ ...44
៥.៣ ផែនការសកម្មភាពអាទិភាព ...45
៥.៣.១ ការអភិវឌ្ឍផលិតផលទេសចរណ៍ និងពង្រឹងគុណភាពសេវាកម្ម ...45
៥.៣.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ ...47
៥.៣.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍ ...48
៥.៣.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន ...48
៥.៣.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង ...50
៥.៣.៦ ការអភិវឌ្ឍធនធានមនុស្ស និងសមភាពយេនឌ័រក្នុងវិស័យទេសចរណ៍ ...50
៥.៣.៧ ការវិនិយោគក្នុងវិស័យទេសចរណ៍ ...51
៥.៣.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ ...52

**VI. ធនធានហិរញ្ញវត្ថុ** ...54

**VII. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** ...56

**VIII. សេចក្តីសន្និដ្ឋាន** ...58

**IX. ឧបសម្ព័ន្ធ**

តារាងទី១ ៖ ស្ថិតិចំនួនភ្ញៀវទេសចរណ៍ឆ្នាំ២០១៦ -២០២០ ...6
តារាងទី២ ៖ រមណីយដ្ឋានទេសចរណ៍ខេត្តមណ្ឌលគិរី ឆ្នាំ២០២០ ...10
តារាងទី៣ ៖ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ខេត្តមណ្ឌលគិរី ឆ្នាំ២០១៦-២០២០ ...16
តារាងទី៤ ៖ សេវាកម្មលក់ដូរវត្ថុអនុស្សាវរីយ៍ ...17
តារាងទី ៥ ៖ ការវិភាគចំណុចខ្លាំង ខ្សោយ ឱកាស និងការគំរាមកំហែង ...19
តារាងទី ៦ ៖ ការព្យាករណ៍ស្ថិតិចំនួនភ្ញៀវទេសចរណ៍ ឆ្នាំ២០២១-២០២៥ ...25
ក្រាហ្វិកទី១ ៖ ភ្ញៀវទេសចរដែលបានមកទស្សនាខេត្តមណ្ឌលគិរី ឆ្នាំ២០១៦-២០២០ ...7

# ផែនទីទេសចរណ៍ខេត្តមណ្ឌលគិរី













# I. សេចក្តីផ្តើម

# I. សេចក្តីផ្តើម

មណ្ឌលគីរីគឺជាខេត្តមួយស្ថិតនៅប៉ែកឦសាន្តនៃព្រះរាជាណាចក្រកម្ពុជាសម្បូរទៅដោយធនធានធម្មជាតិ ទាំងនៅលើដី និងក្រោមដី ព្រមជាមួយវប្បធម៌ ទំនៀមទំលាប់ ប្រពៃណីចម្រុះរបស់បងប្អូនជនជាតិដើមភាគតិច។ ធនធានទាំងនេះ មិនត្រឹមតែនៅរក្សាបានទម្រង់ដើមរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែវាជាសក្តានុពលយ៉ាងចម្បង ដើម្បីធ្វើការកែច្នៃទៅជាប្រយោជន៍សម្រាប់ខេត្ត តំបន់ និងសង្គមជាតិទាំងមូល ។

វិស័យទេសចរណ៍ដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបានកំណត់ជាវិស័យអាទិភាពមួយរបស់ខេត្ត ដែលអាជ្ញាធរក៏ដូចជាប្រជាពលរដ្ឋសង្ឃឹមជឿជាក់ថា វិស័យនេះ នឹងរួមចំណែកកសាងសេដ្ឋកិច្ចសង្គម ផ្តល់ឱកាសការងារ ប្រាក់ចំណូលលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្រ និងជាសេដ្ឋកិច្ចបៃតង។

ដើម្បីឱ្យវិស័យទេសចរណ៍នេះបម្រើឲ្យផលប្រយោជន៍ប្រជាជនក្នុងខេត្តក៏ដូចជាក្នុងប្រទេសយ៉ាងពិតប្រាកដ យន្តការគ្រប់គ្រង និងអភិវឌ្ឍន៍ត្រូវតែធានាឲ្យបានប្រសិទ្ធភាពខ្ពស់ដោយសម្រេចឲ្យបានជា អតិបរមានូវផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន ហើយទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានដែលមិនអាចជៀសរួចឱ្យនៅកម្រិតអប្បរមា។ ដើម្បីសម្រេចបានគោលបំណងដូចខាងលើនេះ ទាំងការគ្រប់គ្រង និងការអភិវឌ្ឍទេសចរណ៍ត្រូវមានផែនការមួយជាត្រីវិស័យ ។

ផ្តើមចេញពីច្បាប់ស្តីពីទេសចរណ៍ គោលនយោបាយទេសចរណ៍ជាតិ ផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ២០២១-២០៣៥ មន្ទីរទេសចរណ៍ខេត្តមណ្ឌលគីរី បានរៀបចំឲ្យមានឡើងនូវផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគីរី ដើម្បីចូលរួមសហការអនុវត្ត និងលើកកម្ពស់ការអភិវឌ្ឍទេសចរណ៍ជាតិកម្ពុជាជាទេសចរណ៍វប្បធម៌ ធម្មជាតិ ឆ្ពោះទៅកាន់កំណើនសេដ្ឋកិច្ចបៃតងផ្តល់ឱកាសការងារបៃតង និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដែលផ្តោតលើប្រសិទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ វប្បធម៌ ចីរភាពបរិស្ថាន ដោយគិតគូរបន្ថែមលើការលើកទឹកចិត្តដល់ផ្នែកឧស្សាហកម្មទេសចរណ៍បៃតង និងដោយមានការគាំទ្រការចូលរួមសហការជិតស្និទ្ធពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមាន ស្ថាប័នរដ្ឋ ឯកជន សង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងសាធារណជនទូទៅ ដូចជា ក្រសួងទេសចរណ៍ រដ្ឋបាលខេត្តមណ្ឌលគិរី ក្រុមប្រឹក្សាខេត្ត មន្ទីរទេសចរណ៍ មន្ទីរបរិស្ថាន មន្ទីរផែនការ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរធនធានទឹក និងឧត្តុនិយម មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មន្ទីររ៉ែ និងថាមពល មន្ទីរអប់រំយុវជន និងកីឡា មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរសុខាភិបាល ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី រដ្ឋបាលក្រុង/ស្រុក ក្រុមប្រឹក្សាឃុំសង្កាត់គោលដៅមួយចំនួន អង្គការក្រៅរដ្ឋាភិបាលនានា និងតំណាងប្រតិបត្តិករទេសចរណ៍ឈានមុខមួយចំនួនក្នុងខេត្ត ។

ឯកសារផែនការនេះ នឹងត្រូវបានប្រើប្រាស់ធ្វើជាមូលដ្ឋានក្នុងការវិភាគ និងសម្រេចចិត្តនានា ពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ក្នុងនោះក៏ជាមធ្យោបាយដើម្បីកៀរគរការចូលរួមគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធ រួមមាន៖ ផ្នែករដ្ឋ ផ្នែកឯកជន ដៃគូអភិវឌ្ឍ ប្រជាពលរដ្ឋ និងទេសចរផងដែរ ។

















# II. ការវិភាគស្ថានភាពទេសចរណ៍


២.១ សភាពការណ៍ទេសចរណ៍កម្ពុជា

២.២ សភាពការណ៍ទេសចរណ៍ខេត្តមណ្ឌលគិរី

២.៣ ស្ថានភាពភូមិសាស្រ្តខេត្តមណ្ឌលគិរី

*២.៣.១ ប្រវត្តិខេត្តមណ្ឌលគិរី*

*២.៣.២ ភូមិសាស្រ្តទូទៅខេត្តមណ្ឌលគិរី*

២.៤ សម្បទា និងសេវាកម្មទេសចរណ៍ខេត្តមណ្ឌលគិរ

*២.៤.១  ផលិតផល និងការទាក់ទាញទេសចរណ៍*

*២.៤.២ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍*

*២.៤.៣ មគ្គុទ្ទេសក៍ទេសចរណ*

*២.៤.៤ សេវាកម្មលក់ដូរវត្ថុអនុស្សាវរីយ៍*

*២.៤.៥ យេនឌ័រក្នុងវិស័យទេសចរណ*

២.៥ ការវិភាគចំណុចខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង

# II. ការវិភាគស្ថានភាពទេសចរណ៍

## ២.១ សភាពការណ៍ទេសចរណ៍កម្ពុជា

វិស័យទេសចរណ៍កម្ពុជាត្រូវបានចាត់ទុកជាវិស័យអាទិភាពមួយដើរតួជា "មាសបៃតង" រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការការពារបរិស្ថាន ពោលគឺចូលរួមដល់ការកសាងសេដ្ឋកិច្ចបៃតងនៅកម្ពុជា ដែលជាផ្នែកគាំទ្រដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ២០១៦-២០៣០ របស់អង្គការសហប្រជាជាតិ។

គួររំឭកដែរថា នៅឆ្នាំ២០១៩ កម្ពុជាសម្រេចបានកំណើនក្នុងអត្រា ៦.៦% ជាមួយនឹងការមកដល់នៃភ្ញៀវទេសចរអន្តរជាតិជាង ៦.៦លាននាក់ និងនាំចំណូលប្រមាណ ៤.៩១៩ លានដុល្លាអាមេរិក ចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិរួមចំណែកប្រមាណ ១២.១% នៃផលិតផលក្នុងស្រុកសរុប (GDP) និងបង្កើតការងារដោយផ្ទាល់ប្រមាណជាង ៦៣ម៉ឺននាក់។ ក្នុងរយៈពេល៦ខែ ដើមឆ្នាំ២០២០ កម្ពុជាទទួលបានភ្ញៀវទេសចរជាតិប្រមាណ ១,១៨លាននាក់ ថយចុះ ៦៤,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៩។

បរិកានៃការឆ្លងមេរោគកូវីដ-១៩ ឆ្នាំ២០២០ ទេសចរណ៍កម្ពុជាត្រូវបានព្យាករណ៍ថា មាន ០៣ សេណារីយ៉ូះ (១) សេណារីយ៉ូទី១ ថយចុះពី៥០% ទៅ៦០% កម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណ ២,៥លាននាក់ (២) សេណារីយ៉ូទី២ ថយចុះពី៦០% ទៅ៧០% កម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណ ២.០លាននាក់ (៣) សេណារីយ៉ូទី៣ ថយចុះពី៧០% ទៅ៩០% កម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណ ១,៥ លាននាក់ប៉ុណ្ណោះ។ ស្ថិតក្នុងស្ថានភាពមិនច្បាស់នៃការរីករាលដាលជំងឺកូវីដ-១៩ កម្ពុជាប្រហែល ស្ថិតនៅក្នុងសេណារីយ៉ូទី៣ ដែលផលប៉ះពាល់នៃមេរោគកូវីដ-១៩ មានដូចជា៖(១) ខាតបង់ចំណូលទេសចរណ៍អន្តរជាតិប្រមាណ ៣ពាន់លានដុល្លា (២) រួមចំណែកក្នុងផលិតផលក្នុងស្រុកសរុប (GDP) អាចថយចុះពីជាង ១២% មកក្រោម ១០% (៣) មូលដ្ឋានអាជីវកម្មទេសចរណ៍ ៣,១៣៥ ទីតាំងត្រូវបានបិទ និងផ្អាកដំណើរការ (គិតត្រឹមខែកក្កដា ឆ្នាំ២០២០) រួមមាន៖ សណ្ឋាគារ ផ្ទះភ្ញៀវ ភោជនីយដ្ឋាន ម៉ាស្សា ទីភ្នាក់ងារទេសចរណ៍ កីឡាទេសចរណ៍ និងអាជីវកម្មខារ៉ាអូខេ រង្គសាល ឌីស្កូតែក បៀហ្គាឌិន បុគ្គលិកបម្រើការងារជាង ១១ម៉ឺននាក់ ប្រហែលពី ១៥% ទៅ ២០% នៃកម្លាំងពលកម្មបម្រើការក្នុងវិស័យទេសចរណ៍ត្រូវបានបញ្ឈប់ការងារ ក្នុងនោះបុគ្គលិកបម្រើការផ្នែកសេវាកម្មរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេដូចជា ម៉ាស្សា ស្ប៉ា ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀហ្គាឌិន ស្ទើរតែមួយរយភាគរយ និងផ្នែកសេវាកម្មស្នាក់នៅ ដែលផ្តោតលើទីផ្សារទេសចរណ៍អន្តរជាតិ ដោយឡែកមគ្គុទ្ទេសក៍ទេសចរណ៍ប្រមាណជាង ៣% ត្រូវបានព្យួរអាជ្ញាបណ្ណទេសចរណ៍។

ដោយឡែកនៅឆ្នាំ២០២១ ទេសចរណ៍កម្ពុជាត្រូវបានព្យាករណ៍ថា នឹងមានកំណើនឡើងវិញក្នុងចន្លោះ ពី ២៥%ទៅ ៣៥% តែស្ថិតនៅក្នុងបរិមាណតិចនៅឡើយ ក្នុងនោះចំណូលទេសចរណ៍អន្តរជាតិនឹងទទួលបានប្រមាណ ២ ពាន់លានដុល្លា រួមចំណែកក្នុងផលិតផលក្នុងស្រុកសរុបប្រមាណ ១០% និងមុខរបរ និងការងារក្នុងវិស័យទេសចរណ៍ប្រមាណ ៥០ម៉ឺននាក់។ ជាងនេះទៅទៀត នៅឆ្នាំ២០២២ ទេសចរណ៍កម្ពុជាត្រូវបានព្យាករណ៍ថា នឹងរក្សានូវកំណើនក្នុងចន្លោះពី ២០% ទៅ៣០%។ កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំ SEA GAME ឆ្នាំ២០២៣ នេះជាព្រឹត្តិការណ៍ទាក់ទាញទេសចរយ៉ាងខ្លាំងដែលទេសចរអន្តរជាតិត្រូវបានព្យាការណ៍ថា នឹងមានកំណើនល្អចន្លោះពី ៣០% ទៅ ៣៥% ដែលជាបរិមាណតិចនៅឡើយពី ២,៥ ទៅ ៣,៥ លាននាក់។

ដើម្បីធានាប្រសិទ្ធភាពក្នុងកម្រិតខ្ពស់បំផុត កម្ពុជាបានបង្កើតគណៈកម្មការជាតិប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ជាបញ្ជាការដ្ឋានរួមក្នុងការដឹកនាំដាក់ចេញ និងជម្រុញការអនុវត្តវិធានការទាំងអស់ ក្នុងនោះក្រសួងទេសចរណ៍ ក៏បានយកចិត្តទុកដាក់ដាក់ចុះនូវវិធានការសំខាន់ៗនានា រួមទាំងការអនុវត្តវិធានសុវត្ថិភាព នៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍សំខាន់ៗ និងការរៀបចំផែនទីចង្អុលផ្លូវស្តីពីផែនការស្តារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ ឆ្នាំ២០២១-២០២៥។

## ២.២ សភាពការណ៍ទេសចរណ៍ខេត្តមណ្ឌលគិរី

ភាពសម្បូរបែបដោយធនធានធម្មជាតិ និងវប្បធម៌ធ្វើឲ្យខេត្តមណ្ឌលគិរីមានសក្តានុពលខ្ពស់ក្នុងការទាក់ទាញការចាប់អារម្មណ៍ពីទេសចរឲ្យមកទស្សនា ស្របគ្នានឹងខេត្តនេះជាខេត្តគោលដៅទេសចរណ៍ថ្មីដែលភ្ញៀវទេសចរអាចទៅដល់ដោយងាយស្រួលជាងកាលពីមុន បន្ទាប់ពីមានការសាងសង់ផ្លូវជាតិលេខ ៧៦ ពីស្រុកស្នួល ខេត្តក្រចេះ មកដល់ក្រុងសែនមនោរម្យ ទីរួមខេត្តមណ្ឌលគិរី បានរួចរាល់នៅខែមីនា ឆ្នាំ២០១១។ តាមប្រភពព័ត៌មានពីមន្ទីរទេសចរណ៍ខេត្ត ចំនួនភ្ញៀវទេសចរដែលមកកម្សាន្តនៅខេត្តមណ្ឌលគិរីមានការកើនឡើងគួរឲ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ ចាប់ពីឆ្នាំ២០១៦-២០២០ រហូតមកដូចបង្ហាញខាងក្រោម៖

**តារាងទី១- សូចនាករទេសចរណ៍ឆ្នាំ២០១៦ -២០២០**

| បរិយាយ | ឯកតា | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|
| ទេសចរអន្តរជាតិ | នាក់ | ៨.៦៧៩ | ១១.៧៥៩ | ១៣.២៧៦ | ១៤.៥៣០ | ៤.៨៧៧ |
| ទេសចរជាតិ | នាក់ | ១៤២.១០៤ | ១០២.៥៩០ | ១១៧.៧១៩ | ១៦៤.៦០៧ | ២២៣.៩៦១ |
| សេវាស្នាក់នៅ | បន្ទប់ | ៩២៦ | ១.០៩០ | ៨៩៥ | ១.០៦៤ | ១.៥០២ |
| កម្លាំងពលកម្ម | នាក់ | ៥១០ | ៥៦០ | ៨៩៧ | ៦១៥ | ១.៥០២ |
| ចំណូលទេសចរណ៍ | លានរៀល | ៦.៩៤៣ | ៩.៤០៧ | ១០.៦២០ | ១១.៦២៤ | ៣.៩០១ |

ប្រភព: មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរីឆ្នាំ២០២០

យោងតាមស្ថិតិខាងលើយើងសង្កេតឃើញថា ភាគរយកំណើនប្រចាំឆ្នាំនៃអ្នកទេសចរជាមធ្យមមាន ៥១,៥៦%ហើយទេសចរក្នុងស្រុក គឺជាទីផ្សារដែលកំពុងមានការកើនឡើងយ៉ាងខ្លាំងធៀបនឹងទេសចរបរទេស។ ចាប់ពីឆ្នាំ២០១៦មក ខេត្តមណ្ឌលគិរីមានការកើនឡើងជាលំដាប់ទាំងភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដោយសារមានការផ្សព្វផ្សាយទូលំទូលាយ និងមានផ្លូវធ្វើដំណើរប្រសើរជាងមុន ជាពិសេសមណ្ឌលគិរីទើបតែបង្ហាញខ្លួនជាតំបន់ទេសចរណ៍ថ្មី ។

តាមការព្យាករណ៍ ដោយផ្អែកលើទិន្នន័យបច្ចុប្បន្ន កំណើនភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរីនៅតែមាននិន្នាការខ្ពស់ដូចដែលបង្ហាញក្នុងតារាង។ តាមការរំពឹងទុកកំណើន នឹងរិតតែមានសន្ទុះខ្លាំងលើសពីការព្យាករណ៍ចាប់ពីឆ្នាំ២០១៩ទៅនៅពេលដែលផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ២០២១-២០៣៥ ត្រូវបានបញ្ចប់ និងដាក់អោយអនុវត្តដោយរាជរដ្ឋាភិបាល ការបញ្ចប់ការសាងសង់ព្រលានយន្តហោះ ការកើនឡើងនូវតំបន់រមណីយដ្ឋានថ្មីៗ និងការតភ្ជាប់ផ្លូវជាតិលេខ៧៦ ដែលមានប្រវែង ១៧១,៧៨ គម ចាប់ពី

សែនមនោរម្យ កោះញែក (ខេត្តមណ្ឌលគិរី) ទៅដល់លំផាត់ តាអង្គ (ខេត្តរតនគិរី) បានស្ថាបនារួចរាល់។ នេះគឺដោយសារលំហូរភ្ញៀវមកពីទិសដៅខេត្តរតនគិរីផង និងប្រទេសវៀតណាមផងតាមច្រកទ្វារទ្វេរភាគីដាក់ដាំ ច្រកទ្វារទ្វេភាគី ណាមលៀរ និងច្រកទ្វារទ្វេភាគីឡាប៉ាខេ (មណ្ឌលគិរី) ព្រោះលទ្ធផលកិច្ចប្រជុំលើកទី៨ នៃគណៈកម្មាធិការសម្របសម្រួលចម្រុះ ស្តីពីតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (8th CLV JCC) និងកិច្ចប្រជុំពាក់ព័ន្ធនៅខេត្តកន្ទុំ (វៀតណាម) កាលពីថ្ងៃទី ៣-៧ ខែធ្នូ ឆ្នាំ ២០១២ បានសង្កត់ធ្ងន់លើវិស័យទេសចរណ៍ ជាវិស័យអាទិភាពក្នុងតំបន់ត្រីកោណនេះ។ កំណើនភ្ញៀវនេះ តម្រូវឲ្យមានវិធានការគ្រប់គ្រង និងការផ្គត់ផ្គង់សេវាកម្មសម្បទាទេសចរណ៍បន្ថែមទៀតលើសអ្វីដែលមានបច្ចុប្បន្ន ។

**ក្រាហ្វិកទី១ ៖ ភ្ញៀវទេសចរដែលបានមកទស្សនាខេត្តមណ្ឌលគិរី ឆ្នាំ២០១៦-២០២០**




| | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|
| ទេសចរអន្តរជាតិ នាក់ | ៨.៦៧៩ | ១១.៧៥៩ | ១៣.២៧៦ | ១៤.៥៣ | ៤.៨៧៧ |
| ទេសចរជាតិ នាក់ | ១៤២.១០៤ | ១០២.៥៩ | ១១៧.៧១៩ | ១៦៤.៦០៧ | ២២៣.៩៦១ |

ចាប់ពីឆ្នាំ២០១៦ រហូតមកដល់ឆ្នាំ២០២០ ភ្ញៀវទេសចរធ្វើដំណើរកម្សាន្តមានការកើនឡើងគួរឲ្យកត់សំគាល់ក្នុងអត្រាកំណើនប្រមាណ ១៥% និងបានស្នាក់នៅមិនតិចជាង ២យប់ ៣ថ្ងៃ ភ្ញៀវទេសចរដែលមកទស្សនាខេត្តមណ្ឌលគិរី ចំពោះភ្ញៀវអន្តរជាតិជាមធ្យមស្នាក់នៅរយៈពេល ០៣យប់ ០៤ថ្ងៃ និង ចំណាយ ៣០-៥០ ដុល្លារ ក្នុង ០១ថ្ងៃ ។ រីឯភ្ញៀវជាតិជាមធ្យមស្នាក់នៅរយៈពេល ០២យប់ ០៣ថ្ងៃ និងចំណាយ ១៦-២០ ដុល្លារក្នុង១ថ្ងៃ។ ភ្ញៀវទេសចរបរទេសចំណាយច្រើនជាងភ្ញៀវខ្មែរ ដូចនេះ គួរមានការស្រូបទាញភ្ញៀវបរទេសនេះឲ្យបានច្រើនដើម្បីទាក់ទាញ និងចូលរួមលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ។

ភ្ញៀវដែលមកទស្សនាខេត្តមណ្ឌលគិរី គឺមកតាមមធ្យោបាយរថយន្តផ្ទាល់ខ្លួន រថយន្តក្រុង និងតាម រយៈក្រុមហ៊ុនទេសចរណ៍ ដែលមាន ១០ក្រុមហ៊ុន កំពុងនាំភ្ញៀវមកខេត្តមណ្ឌលគិរី ។ ភ្ញៀវភាគច្រើនទទួលព័ត៌មានពីខេត្តមណ្ឌលគិរីតាមការផ្សព្វផ្សាយតាមប្រព័ន្ធសារព័ត៌មាន ដូចជា ទូរទស្សន៍បាយ័ន ទូរទស្សន៍អាស៊ីអាគ្នេយ៍ ទូរទស្សន៍ជាតិកម្ពុជា និងកាសែតផ្សេងៗទៀត ។ ក្រៅពីនេះ ក៏មានការផ្សព្វផ្សាយតាមរយៈគេហទំព័រ និងហ្វេសបុកផេករបស់មន្ទីរទេសចរណ៍ខេត្ត គេហទំព័ររបស់ក្រសួងទេសចរណ៍ និងតាមការនិយាយតៗគ្នា។ល។

សម្រាប់ភ្ញៀវទេសចរបរទេស គេចូលចិត្តធ្វើសកម្មភាពដូចជា ចូលព្រៃមើលដំរី ទស្សនាភូមិជនជាតិ ងូតទឹកជ្រោះ។ ភ្ញៀវទេសចរជាតិចូលចិត្តទៅកាន់តំបន់ទឹកជ្រោះ មើលទេសភាព និងមើលភូមិជនជាតិភាគតិច។ ទាំងភ្ញៀវទេសចរជាតិ និងអន្តរជាតិសុទ្ធតែពេញចិត្តនឹងទេសភាព អាកាសធាតុត្រជាក់ និងខ្យល់អាកាសបរិសុទ្ធនៅខេត្តនេះ។ ភ្ញៀវទេសចរជាតិនៅតែជាទីផ្សារចំបងរបស់ខេត្តក្នុងរយៈពេល ០៥ឆ្នាំខាងមុខ បើយោងទៅតាម

និទ្ទាការទេសចរណ៍នាពេលបច្ចុប្បន្ន ហើយគម្រោងអភិវឌ្ឍន៍ទាំងឡាយគួរផ្ដោតការយកចិត្តទុកដាក់លើក្រុមភៀវនេះផងដែរ។

## ២.៣ ស្ថានភាពភូមិសាស្ត្រខេត្តមណ្ឌលគិរី

### ២.៣.១ ប្រវត្តិខេត្តមណ្ឌលគិរី

មុនការបង្កើតខេត្តមណ្ឌលគិរីជាផ្លូវការ តំបន់នេះជាផ្នែកមួយនៃស្រុកឆ្លូងលើរបស់ខេត្តក្រចេះដែលបានបង្កើតឡើងដំបូងនៅឆ្នាំ១៨៩៧ និងក្រោយមកនាសម័យអាណានិគមបារាំងបានធ្វើការរួមបញ្ចូលខេត្តទាំងអស់មកត្រឹម១៣ខេត្តប៉ុណ្ណោះ សម្រាប់តម្រូវតាមចំនួនរ៉េស៊ីដង់បារាំងដែលត្រូវត្រួតត្រាតាមខេត្តនីមួយៗ (ប្រភពឯកសារប្រវត្តិខេត្តមណ្ឌលគិរី២០១៧)។ ប្រជាជនដែលរស់នៅក្នុងតំបន់នេះ គឺមានសុទ្ធតែជនជាតិដើមភាគតិច ជាអាទិ៍ ព្នង កួយ ស្មៀង ទំពួន រអួង រដែ ចារាយ ក្រោល ថ្មូន និងគ្រឹង ជាដើម។ តាមការសម្ភាសន៍ជាមួយក្រុមប្រឹក្សាខេត្តមណ្ឌលគិរីបានរៀបរាប់ថា នៅសម័យនោះមានប៉ុស្ដិ៍មួយកន្លែងឈ្មោះថា កង់រ៉ូឡង់ (បច្ចុប្បន្ននៅស្រុកអូររាំង) មានទីតាំងក្បែរព្រំប្រទល់វៀតណាម និងជាទីតាំងសំខាន់មួយសម្រាប់ការធ្វើដំណើរចេញចូលរបស់រ៉េស៊ីដង់បារាំងទៅកាន់ប្រទេសវៀតណាម។ ដើម្បីងាយស្រួលក្នុងការធ្វើដំណើរ ពួកបារាំងបានកេណ្ឌជនជាតិដើមភាគតិចនៅតំបន់នោះធ្វើផ្លូវមួយខ្សែសម្រាប់តភ្ជាប់ពីឃ្សឹម ទៅប្រទេសវៀតណាមតាមច្រកដាក់ដាំ។

នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៦១ ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តមសីហនុព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ បានឡាយព្រះហត្ថលេខាលើរាជក្រមលេខ ៦៤.ប.រ. អនុម័តច្បាប់ស្ដីអំពីការបង្កើតខេត្តមួយឈ្មោះថា “មណ្ឌលគិរី” ដែលមានព្រំដែននៃស្រុកឆ្លូងលើ ខេត្តក្រចេះ ហើយមានទីប្រជុំជននៅមណ្ឌលគិរី ចែកចេញ ជា៣ស្រុកគឺ៖

១. ស្រុកកោះញែក ដែលមានទីប្រជុំនៅកោះញែក ហើយមានឃុំរវាក់ និងពាមជីមៀតជាចំណុះ។

២. ស្រុកច្បារ (បច្ចុប្បន្នស្រុកពេជ្រាដា)ដែលមានទីប្រជុំនៅជ្រៀ (បច្ចុប្បន្នដេអេ) ហើយដែលមានឃុំជ្រៀ និងខ្មែងជាចំណុះ។

៣. ស្រុកអូររាំង ដែលមានទីប្រជុំនៅស្រុកអូររាំង ដែលមានឃុំដាក់ដាំ ស្រែខ្ទុម និងចុងផ្លាស់ជា ចំណុះ

### ២.៣.២ ភូមិសាស្ត្រទូទៅខេត្តមណ្ឌលគិរី

មណ្ឌលគិរី គឺជាខេត្តមួយស្ថិតនៅភូមិភាគឦសាន្តនៃព្រះរាជាណាចក្រកម្ពុជា ដោយធ្វើដំណើរឆ្លងកាត់ផ្លូវជាតិលេខ ៦ លេខ ៧ និងលេខ ៧៦ មានចំងាយ ៣៨២ គីឡូម៉ែត្រ (ភ្នំពេញ-ស្គន់-ស្នួល-មណ្ឌលគិរី) ហើយយើងក៏អាចធ្វើដំណើរតាមផ្លូវមួយទៀត ដោយឆ្លងកាត់ផ្លូវជាតិលេខ ៦ លេខ ៨ លេខ ៧ និងលេខ ៧៦ ដែលមានចំងាយ ៣៥៨ គីឡូម៉ែត្រ (ភ្នំពេញ-ព្រែកតាមាក់-ក្រែក-ស្នួល-មណ្ឌលគិរី)។ ការគ្រប់គ្រងរដ្ឋបាលដែនដី ខេត្តមានក្រុងសែនមនោរម្យជាទីរួមខេត្ត និងស្រុកចំនួន ៤ ដែលចែកចេញជា ៤សង្កាត់ ១៧ឃុំ និង ៩២ភូមិ។ ខេត្តមានផ្ទៃដីសរុបចំនួន ១៤.២៨៨ គីឡូម៉ែត្រក្រឡា ផ្ទៃដីគ្របដណ្ដប់ដោយព្រៃឈើ ប្រជុំភ្នំ និងខ្ពង់រាប សំបូរដោយជ្រលងដងអូរជាច្រើន ។

ខេត្តមណ្ឌលគិរី មានព្រំប្រទល់ខាងលិចទល់នឹងខេត្តក្រចេះ ខាងជើងទល់នឹងខេត្តស្ទឹងត្រែង និង

ខេត្តរតនគិរី ខាងកើត និងខាងត្បូងទល់នឹងខេត្តដាក់ឡាក់ ខេត្តដាក់ណុង និងខេត្តបិញភឿក នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

បច្ចុប្បន្នខេត្តមានប្រជាពលរដ្ឋសរុបចំនួន ៩៣,៤៤១នាក់ ក្នុងនោះស្រីចំនួន ៤៥.៤២៥នាក់ ស្មើនឹង ២២.២២០គ្រួសារ។ ដង់ស៊ីតេប្រជាពលរដ្ឋស្មើនឹង ០៦នាក់ ក្នុង១គីឡូម៉ែត្រក្រឡា។ ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចរស់នៅក្នុងខេត្តសរុបមានចំនួន ០៨ជនជាតិ ក្នុងនោះមាន ព្នង ក្រោល គ្រឹង ទំពួន ស្មៀង ចារាយ រដែរ និង ថ្មូន។ ចំនួនប្រជាជនខេត្តមណ្ឌលគិរី មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារសន្តិសុខល្អ ផ្ទៃដីទូលាយ ដីមានជីជាតិ គមនាគមន៍ល្អប្រសើរ និងមានលំហូរចូលមកពីខេត្តខាងក្រៅ។

## ២.៤ សម្បទា និងសេវាកម្មទេសចរណ៍ខេត្តមណ្ឌលគិរី

### ២.៤.១ ផលិតផល និងការទាក់ទាញទេសចរណ៍

ខេត្តមណ្ឌលគិរី មានភ័ព្វវាសនាខ្ពស់ដោយសារមានស្ថានភាព អាកាសធាតុល្អ ទិដ្ឋភាព និងទេសភាពដ៏ទាក់ទាញ មានទឹកជ្រោះជាច្រើនកន្លែង (ទឹកជ្រោះប៊ូស្រា ទឹកជ្រោះរមនា១ ទឹកជ្រោះរមនា២ ទឹកជ្រោះជ្រៃធំ ទឹកជ្រោះមនោរម្យ(**ដំណាក់ស្តេច**) ទឹកជ្រោះជ្រៃយស ទឹកជ្រោះលែងប៉ូកប្រះ(**ទឹកជ្រោះក្បាលព្រះ**) ទឹកជ្រោះអូរឆ្វេង ទឹកជ្រោះលែងទូវ ទឹកជ្រោះអូររតេ ទឹកជ្រោះលែងអង ទឹកជ្រោះលែងឃិន ទឹកជ្រោះលែងម្លូក អូរផ្លាយ ទឹកជ្រោះអូរតាំកន ទឹកជ្រោះ៧ជាន់) ជួរភ្នំបន្តជាប់គ្នារដឹក ជ្រលងដងអូរជាច្រើន មានវាលស្មៅបៃតងលាតសន្ធឹងលើកំពូលភ្នំ ខ្យល់បរិសុទ្ធ អាកាសធាតុត្រជាក់ ឆ្នេរទន្លេស្រែពកជាប់ព្រំប្រទល់ខេត្តរតនគិរី សម្បូរព្រៃច្រើនប្រភេទ ព្រៃឈើ និងសត្វព្រៃច្រើនប្រភេទ រួមទាំងសត្វកម្រ ព្រៃស្រោង បឹង និងតំបន់ដែនជម្រកសត្វព្រៃចំនួន ០៥ កន្លែង (ដែនជម្រកសត្វព្រៃកែវសីមា ដែនជម្រកសត្វព្រៃភ្នំព្រេច ដែនជម្រកសត្វព្រៃលំផាត់ (មណ្ឌលគិរី) ដែនជម្រកសត្វព្រៃស្រែពក និងដែនជម្រកសត្វព្រៃណាមលៀរ ។ ធនធានធម្មជាតិទាំងនេះ សុទ្ធសឹងជាសក្តានុពលសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍បែបធម្មជាតិ និងអេកូទេសចរណ៍ ដែលមានលក្ខណៈពិសេសដោយឡែកខុសពីខេត្តដទៃក្នុងប្រទេសកម្ពុជា ។

លើសពីនេះទៀត ភាពសម្បូរបែបនៃវប្បធម៌របស់ជនជាតិដើមភាគតិចផ្សេងៗគ្នា ពិសេសជនជាតិព្នង ជាអាទិ៍មាន សិល្បៈ របាំ(របាំគោះគង របាំដាំស្រូវ របាំបូតស្រូវ) ប្រពៃណីជនជាតិ ព្រឹត្តិការណ៍ វប្បធម៌ (បុណ្យសែនស្រូវ) ប្រពៃណីនៃការរៀបអាពាហ៍ពិពាហ៍ សិប្បកម្មតាមទម្លាប់ (ក្រមា ផាហ៊ុំ កងដៃ ឈ្នួតក្បាល) អាហារពិសេសរបស់ជនជាតិប្រចាំតំបន់ (សម្លត្រាវព្រួង សម្លត្រាវប៉ាយ សម្លត្រាវម្ហាមទូម សម្លត្រូវកមហាល់ សម្លត្រាវហ្គុចគូវ៉ះ សម្លត្រាវកមជុះប្លែព្លន់ សម្លត្រាវម៉្រាច់ សម្លត្រាវរ៉ឺ សម្លត្រាវ ប៉ាយវាត់ព្រេន សម្លត្រាវប្លៃ ព្រីតស្រាត សម្លត្រាវប៉ាយវាត់អណ្តោះ សម្លត្រាវប៉ាយវាត់អណ្តោះ សម្ល ត្រាវប្រេង សម្លត្រាវប៉ាយព្យាប សម្លត្រាវគមជុះកន្តរ សម្លត្រាវឆេត សម្លត្រាវប៉ាយកុំចេក សម្លត្រាវ ណ្ហារ៉ាតួញ សម្លត្រាវប៉ាយបាំង សម្លត្រាវប៉ាយការឡាក សម្លត្រាវព្រួច សម្លរិះ សម្លប្រ៉ូងបំពង់ឬស្សី សម្លឈាមក្របី០៣ឆ្នាំ សម្លបុកម្ទេស សម្លល្វែរ) ចំការពនេចរ និងការទស្សនាដំរី សុទ្ធសឹងជាធនធានសក្តានុពលសម្រាប់ការអភិវឌ្ឍទេសចរណ៍បែបវប្បធម៌ និងពិសេសទេសចរណ៍ជនជាតិដើមភាគតិចតាម បែបសហគមន៍។ ទាំងធនធានធម្មជាតិ និងធនធានវប្បធម៌របស់ខេត្តមណ្ឌលគិរីមានច្រើន ជាក់ស្តែង ធនធានតិចតួចប៉ុណ្ណោះដែលត្រូវបានប្រើប្រាស់បម្រើឲ្យវិស័យទេសចរណ៍នាពេលបច្ចុប្បន្ន និង

ប្រើប្រាស់មិនទាន់អស់លទ្ធភាពនៅឡើយ។ ដូចនេះ ខេត្តនៅមានលទ្ធភាពស្រូបទាញការវិនិយោគលើវិស័យទេសចរណ៍យ៉ាងច្រើនក្រាស់ក្រែលទៀតទាំងការវិនិយោគទ្រង់ទ្រាយធំ មធ្យម និងតូច។

**តារាងទី២ រមណីយដ្ឋានទេសចរណ៍ខេត្តមណ្ឌលគិរី ឆ្នាំ២០២០**

| ល.រ | រមណីយដ្ឋានទេសចរណ៍ | ឈ្មោះឡាតាំង | ចម្ងាយ |
|---|---|---|---|
| **១. ក្រុងសែនមនោរម្យៈ ១១កន្លែង** | | **Saen Monourom Town** | |
| ១ | មជ្ឈមណ្ឌលវប្បធម៌ ជនជាតិដើមភាគតិច ភ្នំដោះក្រមុំ | Phnom Doskramom Ethenic Caltural Center | ១ គ.ម |
| ២ | ព្រះរាជដំណាក់ (ស្តេច) | Preah Reach Domnak | ៥ គ.ម |
| ៣ | ទឹកជ្រោះអូត្រា | O Tra waterfall | ៨ គ.ម |
| ៤ | ជ្រៃយស | Chrey Yos | ៧ គ.ម |
| ៥ | ព្រះរាជដំណាក់ | Preah Reach Domnak | ៤ គ.ម |
| ៦ | ទឹកជ្រោះលែងពោកប្រះ (ហៅទឹក ជ្រោះក្បាលព្រះ) | Leng Pok Preah | ២៦ គ.ម |
| ៧ | ទឹកជ្រោះដំណាក់ស្តេច (ទឹកជ្រោះ សែនមនោរម្យ) | Domnak Sdach waterfall (Senmonorom waterfall) | ៥ គ.ម |
| ៨ | ទឹកជ្រោះអូរឆ្វេង | Ou Chhveng waterfall | ១២ គ.ម |
| ៩ | ទឹកជ្រោះលែងទូវ | Leng Tov waterfall | ១៥ គ.ម |
| ១០ | ភ្នំបាយឆៅ | Phnom Bay Chhao | ១៣ គ.ម |
| ១១ | ចំការស្រល់ | (Pine Farm) Chom Kar Srol | ៣ គ.ម |
| **២. ស្រុកអូររាំងៈ ៥៩កន្លែង កន្លែង** | | **Ou Rang District** | |
| ១ | ទឹកធ្លាក់លែងរណេល | Leng Ronel waterfall | ២៨ គ.ម |
| ២ | ទឹកធ្លាក់លែងកាប៉ារ | Leng Kapar waterfall | ២៥ គ.ម |
| ៣ | ទឹកធ្លាក់លែងណុត | Leng Nut waterfall | ៣០ គ.ម |
| ៤ | ទឹកធ្លាក់លែងឆុល | Leng Chhol waterfall | ៣៥ គ.ម |
| ៥ | ទឹកធ្លាក់លែងហូវ | Leng Hov waterfall | ៣៧ គ.ម |
| ៦ | ទឹកធ្លាក់លែងព្លូម | Leng Ploum waterfall | ៤០ គ.ម |
| ៧ | ទឹកធ្លាក់លែងពុរកនក្រង់ជាំងដាំដែក | Leng Pukorn Krong Cheang Dam Dek | ២៧ គ.ម |
| ៨ | ទឹកធ្លាក់លែងទ្រីង | Leng Tring waterfall | ២៥ គ.ម |
| ៩ | ទឹកធ្លាក់លែងបួង | Leng Buong waterfall | ៣១ គ.ម |
| ១០ | ទឹកធ្លាក់លែងរទូង | Leng R'Toung waterfall | ២២ គ.ម |

| | | | |
|---|---|---|---|
| ១១ | ទឹកធ្លាក់លែងប៉ែល | Leng Pel waterfall | ៤០ គ.ម |
| ១២ | ទឹកធ្លាក់លែងគុល | Leng Kul waterfall | ៣៨ គ.ម |
| ១៣ | ទឹកធ្លាក់លែងង៉ល់ | Leng Ngorl waterfall | ៣៥ គ.ម |
| ១៤ | ទឹកធ្លាក់លែងតុងនុំ | Leng Tung Num waterfall | ៣៣ គ.ម |
| ១៥ | ទឹកធ្លាក់លែងចូញ | Leng Choul waterfall | ៤១ គ.ម |
| ១៦ | ទឹកធ្លាក់លែងតុង | Leng Tong waterfall | ៤៥ គ.ម |
| ១៧ | ទឹកធ្លាក់លែងង្លែក | Leng Nglek waterfall | ៣១ គ.ម |
| ១៨ | ទឹកធ្លាក់លែងប៉ង | Leng Borng waterfall | ៣៧ គ.ម |
| ១៩ | ទឹកជ្រោះរមនា១ | Teuk Chroh Romonea I | ១៧ គ.ម |
| ២០ | ទឹកជ្រោះរមនា២ | Teuk Chroh Romonea II | ១២ គ.ម |
| ២១ | ទឹកធ្លាក់លែងតាំត្រុះ | Leng Tam Troh waterfall | ២៨ គ.ម |
| ២២ | ទឹកធ្លាក់លែងឈីបពីយ | Leng Chhib Piy waterfall | ២៥ គ.ម |
| ២៣ | ទឹកធ្លាក់លែងចាស់លែងចាង | Leng Chas Leng Chang waterfall | ២៧ គ.ម |
| ២៤ | ទឹកធ្លាក់លែងប្រាក់ ( ទឹកធ្លាក់ក្មេក ) | Leng Brak waterfall | ៣០ គ.ម |
| ២៥ | ភ្នំយោកយៅ (ភ្នំខ្លា) | Phnom Yok Yeau (Phnom Khla) | ៣២ គ.ម |
| ២៦ | ភ្នំណល់ទីត | Phnom Nol Tit | ២៩ គ.ម |
| ២៧ | ភ្នំចុតម្លុង | Phnom Chut Mlung | ៣០ គ.ម |
| ២៨ | ភ្នំរតាប់ | Phnom R’Tab | ២៣ គ.ម |
| ២៩ | ភ្នំឡាវីក | Phnom Lao Vik | ២៥ គ.ម |
| ៣០ | ភ្នំកុងក្លែ | Phnom Kung Kle | ២១ គ.ម |
| ៣១ | ភ្នំអូមត្រូន | Phnom Oum Troun | ៣៥ គ.ម |
| ៣២ | ភ្នំគង់ក្វាច់ | Phnom Kung Kvach | ៣៧ គ.ម |
| ៣៣ | ទឹកធ្លាក់លែងរ៉ាពូព្រៃ | Leng Ra Pou Prey waterfall | ៤០ គ.ម |
| ៣៤ | ទឹកធ្លាក់លែងច្បាក់រ៉ាឆាន | Leng Chloak Ra Chhan waterfall | ២៥ គ.ម |
| ៣៥ | ទឹកធ្លាក់លែងគ្លឺ | Leng Kleu waterfall | ២២ គ.ម |
| ៣៦ | ទឹកធ្លាក់លែងអូរឈីង | Leng Orchhing waterfall | ២៤ គ.ម |
| ៣៧ | ទឹកធ្លាក់លែងត្រាង | Leng Trang waterfall | ២៥ គ.ម |

| | | | |
|---|---|---|---|
| ៣៨ | ភ្នំដាញ | Phnom Danh | ២៨ គ.ម |
| ៣៩ | ភ្នំគង់ក្លែល | Phnom Kung Klel | ៤២ គ.ម |
| ៤០ | ភ្នំស្រែះចត | Phnom Sres Chort | ៣៤ គ.ម |
| ៤១ | ទឹកជ្រោះជ្រៃធំ | Chrey Thom waterfall | ២០ គ.ម |
| ៤២ | អណ្តូងស្នេហ៍ | Orndoung Snaeh | ២២ គ.ម |
| ៤៣ | ទឹកជ្រោះ ៧ជាន់ | Prapi Chorn waterfall | ២៧ គ.ម |
| ៤៤ | ទឹកជ្រោះលែងអង លែងឃិន | Leng Ong Leng Khin waterfall | ២៦ គ.ម |
| ៤៥ | ទឹកធ្លាក់លែងត្រង | Leng Trang waterfall | ២៦ គ.ម |
| ៤៦ | យោគត្រាច់ត្រាយ (ភ្នំត្រាច់ត្រាយ) | York Trach Tray (Phnom Trach Tray) | ១០ គ.ម |
| ៤៧ | ភ្នំល្វេឆៃ | Phnom Louv Chhey | ២២ គ.ម |
| ៤៨ | ទឹកធ្លាក់លែងកៃ | Leng Kai waterfall | ២៤ គ.ម |
| ៤៩ | ទឹកធ្លាក់អូរតាវ | Ou Tao waterfall | ២៣ គ.ម |
| ៥០ | ទឹកធ្លាក់ត្រុង | Trong waterfall | ២៤ គ.ម |
| ៥១ | ទឹកជ្រោះលែងម្ហុក | Leng Mhok waterfall | ៥២ គ.ម |
| ៥២ | ទឹកធ្លាក់លែងកាវ | Leng Kao waterfall | ២៧ គ.ម |
| ៥៣ | ទឹកធ្លាក់លែងក្រេង | Leng Kreng waterfall | ២៨ គ.ម |
| ៥៤ | ទឹកធ្លាក់លែងប៉ាល់ទោក | Leng Pal Tork waterfall | ២៥ គ.ម |
| ៥៥ | តំបន់ទេសចរណ៍សត្វទោចភ្នំព្រឹក | Phnom Preuk Tourism Wildlife sanctury | ២៥ គ.ម |
| ៥៦ | ទឹកធ្លាក់លែងម្រីវ | Leng Mriv waterfall | ៣០ គ.ម |
| ៥៧ | ទឹកធ្លាក់លែងកក់ | Leng Kork waterfall | ៤០ គ.ម |
| ៥៨ | ភ្នំបារាំងសុង | Phnom Barang Song | ៣៧ គ.ម |
| ៥៩ | ភ្នំគង់រញ្ជួង | Phnom Kung R'Nhoung | ៣៥ គ.ម |
| **៣. ស្រុកកោះញែក: ១២កន្លែង** | | **Koh Nhaek District** | |
| ១ | កោះខ្សាច់ទន្លេស្រែពក | Koh Khsach Tonle Srae Pork | ១៦៨ គ.ម |
| ២ | ជួរថ្មទឹកហូរកែសាន | Chou Thmor Teuk Hou Kaisan | ១៥១ គ.ម |
| ៣ | ជួរថ្មទឹកហូរទន្លេម្រោច | Chou Thmor Teuk Hou Tonle Mreouch | ១៩៣ គ.ម |

| | | | |
|---|---|---|---|
| ៤ | កោះញ្ញាប៉ក្នុងទន្លេស្រែពក | Koh Nhab Knong Tonle Srae Pork | ១៥៦ គ.ម |
| ៥ | តំបន់អេកូទេសចរណ៍ម្រើច | Mreouch E-co Tourism | ១១៣ គ.ម |
| ៦ | ទ្វារទឹកតំបន់អូរប្រេង | Tvear Teuk O'breng | ១០២ គ.ម |
| ៧ | មជ្ឈមណ្ឌលវប្បធម៌ភ្នំក្រោល | Phnom Krol Cultural Center | ១១១ គ.ម |
| ៨ | ទំនប់អូររយេះ | Tomnup O'Ryes | ១០៨ គ.ម |
| ៩ | តំបន់ទេសចរណ៍ធម្មជាតិភ្នំណាម រ៉ាម | Phnom Nam Ram National Tourism Site | ៧៣ គ.ម |
| ១០ | តំបន់ទេសចរណ៍ភ្នំក្លួន | Phnom Kloun E-cotourism | ១២៣ គ.ម |
| ១១ | ទំនប់អូរណំ | Tomnup O'Rnam | ១០៨ គ.ម |
| ១២ | តំបន់ទេសចរណ៍ភ្នំបាក់ខែង | Phnom Bak Kheng Tourism Site | ២៣៨ គ.ម |
| **៤. ស្រុកកែវសីមា: ០៥កន្លែង** | | **Kaev Seima District** | |
| ១ | ភ្នំកែវសីម៉ា | Phnom Keo Seima | ៧០ គ.ម |
| ២ | អូរហុច | O'R Huch | ៧៣ គ.ម |
| ៣ | ទឹកជ្រោះអូរតាំងឡាំង | O'R Tang Lang waterfall | ២៨ គ.ម |
| ៤ | ទឹកធ្លាក់ស្រែប្រាវ | Srae Brav waterfall | ៨៧ គ.ម |
| ៥ | តំបន់ហ្គាទី | Gati Zoon | ៧៥ គ.ម |
| **៥. ស្រុកពេជ្រាដា: ១៨កន្លែង** | | **Pechrada District** | |
| ១ | ទឹកជ្រោះប៊ូស្រា | Bou Sra waterfall | ៣៨ គ.ម |
| ២ | ភ្នំណាមលៀរ | Phnom NamLear | ៥០ គ.ម |
| ៣ | ភ្នំលុប្រាណ | Phnom Lo Bran | ៥០ គ.ម |
| ៤ | ភ្នំមូសរលូង | Phnom Mos R'Loung | ៦០ គ.ម |
| ៥ | ទឹកជ្រោះអូរតាំកន | O'R Tamkorn waterfall | ៦០ គ.ម |
| ៦ | ទឹកជ្រោះ៧ជាន់ | 7 Chean waterfall | ៤០ គ.ម |
| ៧ | រមណីយដ្ឋានទេសចរណ៍ធម្មជាតិ ចំណុចអូរប៉ុលក្រោម (ពាមអូរឆែល) | Chomnoch O'R Pol Krom E-cotourism | ៥១ គ.ម |
| ៨ | ទឹកជ្រោះអូរផ្លាយលើ | O'R Play Loeu waterfall | ៣០ គ.ម |
| ៩ | ទឹកជ្រោះអូរផ្លាយក្រោម (លែងអេល) | O'R Play Krom waterfall | ៣៤ គ.ម |
| ១០ | ទឹកជ្រោះលែងប៉ាឡុង | Leng Pa Long waterfall | ៣៦ គ.ម |

| | | | |
|---|---|---|---|
| ១១ | ភ្នំអូរទេ | Phnom Or Te | ១៩ គ.ម |
| ១២ | អូរផ្លាយ (លែងឆាល) | Or Play | ៤០ គ.ម |
| ១៣ | អូរប៉ុល (លែងរ៉ាទើយ) | Or Pul | ៥១ គ.ម |
| ១៤ | លុទ្រុង | Lo Troung | ៦៧ គ.ម |
| ១៥ | អូរងេះ | O"r Nges | ៦៣ គ.ម |
| ១៦ | ទាកទោល (ទឹកស័ក្តិសិទ្ធិ) | Teak Tol | ៣៦ គ.ម |
| ១៧ | ទឹកធ្លាក់ម៉ុមតាល់ | Mom Tal waterfall | ២៤ គ.ម |
| ១៨ | ត្រពាំងក្អើម | Tra Peang Ka Erm | ២៥ គ.ម |
| **៦. តំបន់ទេសចរណ៍កែច្នៃ និងសិប្បកម្ម** | | **Recreation Tourism Site and handicraft** | |
| ១ | គណៈកម្មាការតម្បាញសាសល្អីជនជាតិដើមភាគតិចព្នង (ភូមិពូតាំង សង្កាត់រមនា ក្រុងសែនមនោរម្យ) | Pnong Basket weaving committee Putang Romanea Senmonorom | ៩ គ.ម |
| ២ | គណៈកម្មាការតម្បាញសាសល្អីជនជាតិដើមភាគតិចព្នង (ភូមិពូត្រែង ឃុំដាក់ដាំ ស្រុកអូររាំង) | Pnong Basket weaving commmittee Pu Treang Dak Dam O'Reang | ២២ គ.ម |
| ៣ | គណៈកម្មាការតម្បាញសំពត់ កន្សែង ជនជាតិដើមភាគតិចព្នង (ភូមិពូឡេះ ឃុំដាក់ដាំ ស្រុកអូររាំង) | Pnong skirt and scarf weaving committee Pu Les Dak Dam O'Reang | ២៥ គ.ម |
| ៤ | គណៈកម្មាការតម្បាញសំពត់ កន្សែង ជនជាតិដើមភាគតិចព្នង (ភូមិទី៦ ឃុំប៊ូស្រា ស្រុកពេជ្រាដា) | Pnong skirt and scarf weaving committee Busra Pechrada | ៤៥ គ.ម |

ប្រភព: មន្ទីរទេសចរណ៍ខេត្តមណ្ឌលគីរី និងរដ្ឋបាលក្រុង ស្រុក

ការអភិវឌ្ឍផលិតផលទេសចរណ៍ត្រូវបានកំណត់តាមប្រភេទផលិតផល និងតាមតំបន់ ឬច្រករបៀងសំខាន់ៗដោយមានការសិក្សាវិភាគច្បាស់លាស់ទៅលើប្រភពធនធានសក្តានុពល ភាពទាក់ទាញ ផ្នែកពាក់ព័ន្ធ និងផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ។ តំបន់ទេសចរណ៍អាទិភាពក្នុងខេត្តមណ្ឌលគីរី ត្រូវបានកំណត់ដូចខាងក្រោម៖

- ក្រុងសែនមនោរម្យ មានដែនជម្រកសត្វព្រៃភ្នំព្រេច ទេសភាពវាលស្មៅ និងភ្នំស្រស់ត្រកាល អាកាសធាតុត្រជាក់ល្មម ទឹកធ្លាក់ បឹងធម្មជាតិ ចំការផ្លែឈើ ចំការស្រល់ ភូមិជនជាតិដើមភាគតិច ក្រុមដំរី រមណីយដ្ឋានធម្មជាតិ សួនផ្កា ភ្នំដោះក្រមុំ អតីតព្រះរាជដំណាក់ ទឹកជ្រោះលែងប៉ូកប្រះ ទឹកជ្រោះអូរឆ្វេង ទឹកជ្រោះលែងទូវភ្នំបាយឆៅ និងជាទីប្រជុំជនក្រុង មាន សក្តានុពលសម្រាប់ការអភិវឌ្ឍទេសចរណ៍បែបវប្បធម៌ ធម្មជាតិ និងលំហែកម្សាន្ត ដូចជាទេសចរណ៍កម្សាន្តដោយទស្សនា និងអោយចំណីដំរី និងទស្សនាភូមិជនជាតិ ទីលានវាយកូនហ្គោល ផ្សារទំនើប ផ្សាររាត្រី សេវាកម្មវិថីលក់ម្ហូបអាហារ មណ្ឌលម្សាន្តទេសចរណ៍មនុស្សពេញវ័យ សួនច្បារសម្រាប់ហាត់កីឡា និងលំហែកាយ។ ក្រុងសែនមនោរម្យគួរទទួលបាន ការវិនិយោគទ្រង់ទ្រាយធំ និងមធ្យមដើម្បីរៀបចំសេវាកម្មទេសចរណ៍ និងតំបន់ទេសចរណ៍ទាំងអស់ខាងលើ ។

- ស្រុកពេជ្រាដា មានដងព្រៃព្រឹក្សា ជ្រោះជ្រលងដងអូរ ទឹកធ្លាក់ ភ្នំណាមលៀរ ភ្នំលុប្រាណ ទឹកជ្រោះ៧ជាន់ ដែលមានទីតាំងស្ថិតនៅជិតដើមឈើខ្នាតធំដ៏កម្រ ទឹកជ្រោះប៊ូស្រាដែលជានិមិត្តរូប របស់ខេត្ត ភ្នំមូសរលូង ទឹកជ្រោះអូរតាំកន រមណីយដ្ឋានទេសចរណ៍ធម្មជាតិចំណុចអូរ ប៉ុលក្រោម ទឹកជ្រោះអូរផ្លាយលើ ទឹកជ្រោះ អូរផ្លាយក្រោម (លែងអល) ទឹកជ្រោះលែងប៉ាឡុង ភ្នំអូរទេ អូរផ្លាយ(លែងឆាល) អូរប៉ុល(លែងរ៉ាទើយ) លុ ទ្រូងអូររងេះ ទាកទោល(ទឹកស័ក្តិសិទ្ធិ) ទឹកធ្លាក់ម៉ុមតាល់ ត្រពាំងក្អែម ទេសភាពល្អប្រណិតជាច្រើនកន្លែង សត្វព្រៃគ្រប់ប្រភេទចូលចិត្តរស់នៅដែនជម្រកសត្វព្រៃណាមលៀរមណ្ឌលគីរី ដែនជម្រកសត្វព្រៃស្រែពក និង ទីប្រជុំជនស្រុកជាតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ និងមានប្រពៃណីវប្បធម៌ជនជាតិដើម ក្រុម សិល្បៈ ក្រុមសិប្បកម្ម ។ ភូមិសាស្ត្រស្រុកពេជ្រាដានេះ គួរតែបង្កើតជាតំបន់ទេសចរណ៍ធម្មជាតិអេកូ ទេសចរណ៍ និងទេសចរណ៍សហគមន៍ជនជាតិដើមភាគតិច ដើម្បីលើកទឹកចិត្តដល់បងប្អូនជនជាតិឲ្យថែរក្សា ធនធានធម្មជាតិ និងប្រពៃណីវប្បធម៌របស់ពួកគេក៏ដូចជាផ្តល់ឱកាសបង្កើនប្រាក់ចំណូល ការងារ ការកាត់ បន្ថយភាពក្រីក្រ និងចំណាកស្រុកតាមរយៈវិស័យទេសចរណ៍នេះផងដែរ ។ លើសពីនេះ ស្រុកពេជ្រាដាមាន ព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម នាំឲ្យមានសក្តានុពលភ្ញៀវមកតាមច្រកព្រំដែនទ្វេភាគីណាមលៀរ (មណ្ឌលគីរី) ដាក់ប៉រ (ខេត្តដាក់ណុង វៀតណាម) ។
- ស្រុកអូររាំង មានរមណីយដ្ឋានធម្មជាតិ ទេសភាពព្រៃភ្នំ ដែនជម្រកសត្វព្រៃកែវសីមា មានសហគមន៍ជនជាតិ ដើមភាគតិចពួងអណ្តូងក្រឡឹង ចំការស្រល់ ភូមិជនជាតិ ទឹកជ្រោះលែងឃិន លែងអង ទឹកជ្រោះលែងម្លូក ទឹកជ្រោះជ្រៃធំ ទឹកជ្រោះអូរតេ អណ្តូងស្នេហ៍ ទឹកជ្រោះរមនា១ រមនា២ ក្រុមសិប្បកម្ម សត្វព្រៃ ដំរីស្រុក ទឹកធ្លាក់ លែងរណោល ទឹកជ្រោះលែងកាប៉ារ ទឹកធ្លាក់លែងណុត ទឹកធ្លាក់លែងឆុល ទឹកធ្លាក់លែងហូរ ទឹកធ្លាក់លែង ព្លូម ទឹកធ្លាក់លែងពុរកនក្រង់ជាំងដាំដែក ទឹកធ្លាក់លែងទ្រីង ទឹកធ្លាក់លែងបួង ទឹកធ្លាក់លែងរទូង ទឹកធ្លាក់ លែងប៉ែល ទឹកធ្លាក់លែងគុល ទឹកធ្លាក់លែងង៉ល់ ទឹកធ្លាក់លែងតុងនុំ ទឹកធ្លាក់លែងចូញ ទឹកធ្លាក់លែងតុង ទឹកធ្លាក់លែងង្លែក ទឹកធ្លាក់លែងប៉ង ទឹកធ្លាក់លែងតាំត្រុះ ទឹកធ្លាក់លែងឈឹបពីយ ទឹកធ្លាក់លែងចាស់លែង ចាង ទឹកធ្លាក់លែកប្រាក់ (ទឹកធ្លាក់ក្ងោក) ភ្នំយោកយៅ (ភ្នំខ្លា) ភ្នំណល់ទីត ភ្នំចុតម្លុង ភ្នំរតាប់ ភ្នំឡាររីក ភ្នំ កុងក្លែ ភ្នំអូមគ្រូន ភ្នំគង់ក្វាច់ ទឹកធ្លាក់លែងរ៉ាពូព្រៃ ទឹកធ្លាក់លែងច្បាក់រ៉ាឆាន ទឹកធ្លាក់លែងគ្លី ទឹកធ្លាក់លែងអូរ ឈើង ទឹកធ្លាក់លែងត្រាង ភ្នំដាញ ភ្នំគង់ក្លេល ភ្នំស្រេះចត ទឹកធ្លាក់លែងត្រុង យោគត្រាច់ត្រាយ(ភ្នំត្រាច់ ត្រាយ) ភ្នំលេបូរឆែ ទឹកធ្លាក់លែងកៃ ទឹកធ្លាក់អូរតាវ ទឹកធ្លាក់ត្រេង ទឹកធ្លាក់លែងការ ទឹកធ្លាក់លែងក្រេង ទឹកធ្លាក់ លែងប៉ាល់ទោក តំបន់ទេសចរណ៍សត្វទោចភ្នំព្រឹក ទឹកធ្លាក់ធ្លាក់លែងម្រើវ ទឹកធ្លាក់លែងកក់ ភ្នំបារាំងសុង ភ្នំ គង់រញួង ដែលសុទ្ធសឹងជាសក្តានុពលសម្រាប់អភិវឌ្ឍន៍ទេសចរណ៍បែបធម្មជាតិ វប្បធម៌ អេកូទេសចរណ៍ និងទេសចរណ៍សហគមន៍។ ស្រុកអូររាំង មានព្រំប្រទល់ជាប់នឹងប្រទេស វៀតណាម មានសក្តានុពលភ្ញៀវ មកតាមច្រកព្រំដែនទ្វេភាគី ដាក់ដាំ (មណ្ឌលគីរី) ប៊ូប្រាំង (ខេត្តដាក់ណុង វៀតណាម) ។
- ស្រុកកែវសីមា មានដែនជម្រកសត្វព្រៃកែវសីមា ដែនជម្រកសត្វព្រៃភ្នំព្រេច ភូមិកាទី(ផ្នូរខ្មោចជនជាតិបារាំង ស្លាប់ក្នុងសម័យអាណានិគមនិយមបារាំង) សត្វព្រៃច្រើនប្រភេទ ភូមិជនជាតិដើមភាគតិច ភ្នំកែវសីមា អូរ ហុច ទឹកធ្លាក់ស្រែប្រាវ ទឹកជ្រោះអូរតាំងឡាំង ដីមានជីជាតិ ជាតំបន់កសិឧស្សាហកម្ម (កៅស៊ូ ដំឡូងមី) និង ដំណាំរួមផ្សំផ្សេងៗ។ ស្រុកកែវសីមា គួរមានការអភិវឌ្ឍទេសចរណ៍ធម្មជាតិ អេកូទេសចរណ៍ ទេសចរណ៍

សហគមន៍ និងកសិទេសចរណ៍។ ស្រុកកែវសីមាមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម មានសក្តានុពលភ្ញៀវមកតាមច្រកព្រំដែនទ្វេភាគីឡាប៉ាខេ (មណ្ឌលគិរី) ហ្វាងយឺវ (ខេត្តប៊ិញភឿក វៀតណាម)។

➢ ស្រុកកោះញែកមានដែនជម្រកសត្វព្រៃស្រែពក ដែនជម្រកសត្វព្រៃលំផាត់ វាលស្រែធំល្វឹង ល្វើយ ទន្លេស្រែពក ខ្សាច់ទន្លេ សត្វព្រៃ រមណីយដ្ឋានភ្នំក្រោល ទំនប់ទឹកអូរហ្រ្វង់ ទំនប់ទឹកអូរយ៉េះ កោះខ្សាច់ទន្លេស្រែពក ជួរថ្មទឹកហូរកែសាន ជួរថ្មទឹកហូរទន្លេម្រោច កោះញ៉ាប៉ក្នុងទន្លេស្រែពក តំបន់អេកូទេសចរណ៍ម្រើច តំបន់ទេសចរណ៍ធម្មជាតិភ្នំណាមរ៉ាម តំបន់ទេសចរណ៍ភ្នំក្អួន តំបន់ទេសចរណ៍ភ្នំបាក់ខែង ជនជាតិចម្រុះច្រើនសាសន៍ (ឡាវ-ខ្មែរ...)។ ស្រុកកោះញែក មានសក្តានុពលសម្រាប់អភិវឌ្ឍន៍ទេសចរណ៍ធម្មជាតទេសចរណ៍វប្បធម៌ អេកូទេសចរណ៍ កសិទេសចរណ៍ និងទេសចរណ៍សហគមន៍។ ស្រុកកោះញែកមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាម មានសក្តានុពលភ្ញៀវមកតាមច្រកព្រំដែនទ្វេភាគីជីមៀត (មណ្ឌលគិរី) ដាក់រ៉េ (ខេត្តដាក់ឡាក់ វៀតណាម)។

### ២.៤.២ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍

ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ គឺជាបណ្តុំនៃឧបករណ៍ និងគ្រឹះស្ថានសម្រាប់ចូលរួមអភិវឌ្ឍន៍វិស័យទេសចរណ៍ដែលរួមមានធាតុផ្សំ ៤សំខាន់ៗ ដូចជា សេវាកម្មស្នាក់នៅ សេវាកម្មម្ហូបអាហារ សេវាកម្មដឹកជញ្ជូន និងសេវាកម្មទំនាក់ទំនង ព្រមទាំងសេវាកម្មបន្ទាប់ន្សំជាច្រើនទៀត។ គុណតម្លៃទាំងនេះបានបង្កើតនូវមូលដ្ឋានគ្រឹះសម្រាប់ទាក់ទាញភ្ញៀវទេសចរ និងផ្តល់ជូនដល់ភ្ញៀវប្រកបដោយផាសុខភាពក្នុងការមក ទស្សនាកម្សាន្តនៅតាមតំបន់ទាក់ទាញ។ នៅក្នុងវិស័យទេសចរណ៍ការដឹកជញ្ជូនភ្ញៀវក៏មានសារៈសំខាន់សម្រាប់ជាមធ្យោបាយក្នុងការចូលទៅដល់តំបន់គោលដៅទេសចរណ៍ ហើយក៏ជាការមើលឃើញដំបូងរបស់ភ្ញៀវ។ ដូចនេះហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍អាចត្រូវបានកំណត់ជាផលិតផលទេសចរណ៍ម៉្យាងដែលគួរត្រូវបានយកចិត្តទុកដាក់អភិវឌ្ឍន៍ និងគ្រប់គ្រងក្នុងការផ្តល់ជូននូវគុណភាព និងប្រសិទ្ធភាពសេវាកម្មទេសចរណ៍។

**តារាងទី៣ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ខេត្តមណ្ឌលគិរី ឆ្នាំ២០១៦-២០២០**

| បរិយាយ | ឯកតា | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|---|
| សណ្ឋាគារ | បន្ទប់ | ៣៣៦ | ៣៣៦ | ៣៧១ | ៣៨៤ | ៧៨០ |
| ផ្ទះសំណាក់ | បន្ទប់ | ៥៨៩ | ៦៤៣ | ៧៨០ | ៦៧៩ | ៧២២ |
| ភោជនីយដ្ឋាន | កៅអី | ៣១២ | ៣២៦ | ៣៤០ | ៣៤៩ | ៣០៥ |
| មគ្គុទ្ទេសក៏ទេសចរណ៍តំបន់ | នាក់ | ៧៥ | ៧៥ | ៧៥ | ៧៥ | ៧៥ |

### ២.៤.៣ មគ្គុទ្ទេសក៍ទេសចរណ៍

មគ្គុទេសក៏ទេសចរណ៍ គឺជាភ្នាក់ងារផ្តល់សេវាផ្ទាល់អំពីព័ត៌មានប្រវត្តិសាស្រ្ត ណែនាំភ្ញៀវឲ្យស្គាល់ពីវប្បធម៌អរិយធម៌ក្នុងខេត្ត ក្នុងរមណីយដ្ឋាន និងក្នុងសហគមន៍នីមួយៗ។ មគ្គុទេសក៏ទេសចរណ៍ មានសារៈសំខាន់ណាស់សម្រាប់ណែនាំភ្ញៀវឲ្យយល់ពីរបៀបរបបរស់នៅ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់តាមមូលដ្ឋាននីមួយៗ។

យោងតាមអនុក្រិត្យស្តីពីមគ្គុទ្ទេសក៏ទេសចរណ៍ ដែលជាឯកសារគតិយុត្តដ៏សំខាន់សម្រាប់គ្រប់គ្រងមគ្គុ

ទេសក៏ទេសចរណ៍។ អនុក្រឹត្យនេះមានចែងអំពីការបែងចែកប្រភេទមគ្គុទេសក៏ទេសចរណ៍ជា ៥ប្រភេទ ដូចជា មគ្គុទេសក៏ថ្នាក់ពិសេស ថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍។ មន្ទីរទេសចរណ៍ខេត្តបានរៀបចំវគ្គបណ្តុះបណ្តាលលើមុខជំនាញ "បដិសណ្ឋារកិច្ច" ជូនដល់មន្ត្រីរាជការ ប្រតិបត្តិករ ទេសចរណ៍ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតក្នុងគោលបំណងលើកកម្ពស់គុណភាពសេវាជូនភ្ញៀវដែលមកទស្សនាក្នុងខេត្ត ដោយមានការទទួលខុសត្រូវមួយច្បាស់លាស់លើសេវាកម្មវិស័យទេសចរណ៍។

### ២.៤.៤ សេវាកម្មលក់ដូរវត្ថុអនុស្សាវរីយ៍

ដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ការពង្រឹងសមត្ថភាព និងការថែរក្សាវប្បធម៌ប្រពៃណីរបស់ប្រជាជនដែលក្នុងនោះការអភិវឌ្ឍជំនាញក៏ត្រូវបានពង្រឹង និងយកចិត្តទុកដាក់ផងដែរ។ ជាងនេះទៅទៀតចំនួនអ្នកលក់វត្ថុអនុស្សាវរីយ៍ក្នុងខេត្តមណ្ឌលគីរីមានតិច ហើយភាគច្រើនលក់នៅក្នុងបណ្ណាគារ និងតាមទីផ្សារ ផ្ទះផ្ទាល់ខ្លួន និងមួយចំនួនទៀតលក់នៅតាមបណ្តារមណីយដ្ឋាន ហើយភាគច្រើនជារបស់ កែច្នៃពីធនធានធម្មជាតិក្នុងស្រុក។ តាមរយៈគំហើញនេះ មន្ទីរទេសចរណ៍ខេត្ត បានធ្វើការផ្សព្វផ្សាយនិងសម្របសម្រួលឲ្យអាជីវករចូលរួមក្នុងការលើកស្ទួយសិល្បៈខ្មែរដែលកើតចេញពីស្នាដៃកូនខ្មែរ តាមរយៈការលក់វត្ថុអនុស្សាវរីយ៍ដែលមានដូចជា គំនូរ គ្រឿងចម្លាក់ធ្វើពីថ្ម ត្បូងថ្ម ឈើ និងសម្ភារៈប្រើប្រាស់ដែលធ្វើពីសូត្រ ក្រមា ផ្តៅ ឬស្សី ជាដើម ។

បច្ចុប្បន្ននេះនៅក្នុងខេត្តមណ្ឌលគីរីមានហាងលក់វត្ថុអនុស្សាវរីយ៍ចំនួន ១០កន្លែងគឺៈ

**តារាងទី៤ សេវាកម្មលក់ដូរវត្ថុអនុស្សាវរីយ៍**

| ទីតាំង | ឈ្មោះហាងលក់វត្ថុអនុស្សាវរីយ៍ | ប្រភេទវត្ថុអនុស្សាវរីយ៍ |
|---|---|---|
| ក្រុងសែនមនោរម្យ | ហាងលក់វត្ថុអនុស្សាវរីយ៍អូរមីស | ចម្លាក់ឈើ ត្បូង |
| ស្រុកពេជ្រាដា | ហាងលក់វត្ថុអនុស្សាវរីយ៍រមណីយដ្ឋានទឹកជ្រោះប៊ូស្រា ៩តូប | ត្បូង សម្លៀកបំពាក់ជនជាតិដើមភាគតិច |

ប្រភពៈ មន្ទីរទេសចរណ៍ខេត្តមណ្ឌលគីរី

### ២.៤.៥ យេនឌ័រក្នុងវិស័យទេសចរណ៍

សម្រាប់ការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ដោយស្មើភាព ស្មើសិទ្ធិជាមួយ បុរសក្នុងភាពជាដៃគូទាំងក្នុងសកម្មភាពសង្គម សេដ្ឋកិច្ច និងការធ្វើសេចក្តីសម្រេចដើម្បីធានាបានសុខដុមនីយកម្មសេចក្តីថ្លៃថ្នូរ និងការពង្រឹងភាពជាម្ចាស់លើខ្លួនឯង ការបង្កើតភាពអង់អាចផ្នែកសេដ្ឋកិច្ចតាមរយៈចំណេះ ជំនាញ បទពិសោធន៍ និងសហគ្រិនភាព។

នៅឆ្នាំ២០១៩កន្លងទៅនេះ វិស័យទេសចរណ៍កម្ពុជាសម្រេចបានកំណើនក្នុងអត្រា ៦.៦ % ជា មួយនឹងការមកដល់នៃទេសចរអន្តរជាតិ និងបានបង្កើតឱកាសការងារដោយផ្ទាល់ប្រមាណ ៦៣ម៉ឺននាក់ ក្នុងនោះ ស្ត្រីប្រមាណជាង ៦០% មានវត្តមាននៅគ្រប់សេវាកម្មទេសចរណ៍ទាំងអស់រួមមានៈ ទីភ្នាក់ងារទេសចរណ៍ កីឡា

ទេសចរណ៍ សេវាកម្មដឹកជញ្ជូន សណ្ឋាគារ ផ្ទះសំណាក់ អាផាតមិន ភោជនីយដ្ឋាន អាហារដ្ឋាន មណ្ឌលកម្សាន្ត ម៉ាស្សា បៀរហ្គាដិន។ល។ ដើម្បីបន្តនូវនិន្នាការនៃការចូលរួមរបស់ស្ត្រីក្នុងកិច្ចការងារទាំងនេះ ក្រសួងទេសចរណ៍បានរៀបចំផែនការយុទ្ធសាស្ត្រលើកកម្ពស់យេនឌ័រក្នុងវិស័យទេសចរណ៍ ដែលមានទិសដៅយុទ្ធសាស្ត្រចម្បងៗត្រូវបានដាក់ចេញដូចខាងក្រោម ៖

- លើកកម្ពស់សមភាពយេនឌ័រ
- លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- ផ្លាស់ប្តូរឥរិយាបទសង្គមចំពោះស្ត្រីដែលប្រកបការងារក្នុងសេវាកម្មទេសចរណ៍
- កាត់បន្ថយហានិភ័យ និងផលប៉ះពាល់អវិជ្ជមានដល់ស្ត្រីដែលបម្រើការក្នុងវិស័យទេសចរណ៍។
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធ
- លើកកម្ពស់ស្ថានភាពស្ត្រីសហគមន៍ទេសចរណ៍ និងសហគ្រិនស្ត្រីក្នុងវិស័យទេសចរណ៍
- បង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យទេសចរណ៍

## ២.៥ ការវិភាគចំណុចខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង

ការវិភាគ SWOT នេះធ្វើឡើងដើម្បីប្រមើលមើលទៅលើស្ថានភាពទេសចរណ៍របស់ខេត្តមណ្ឌលគិរីនាពេលបច្ចុប្បន្ន និងនិន្នាការនៃការវិវត្តរបស់វាទៅថ្ងៃអនាគត។ ការវិភាគនេះ ក៏អាចជួយឲ្យការកំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍កាន់តែមានភាពច្បាស់លាស់ តាមរយៈការយល់ដឹងស៊ីជម្រៅលើស្ថានភាពខ្លួនឯងធៀបនឹងចក្ខុវិស័យទៅថ្ងៃអនាគត ។

លទ្ធផលនៃការវិភាគ SWOT ក្នុងតារាងខាងក្រោមបង្ហាញថា ខេត្តមណ្ឌលគិរី មានសក្តានុពលទេសចរណ៍ច្រើន និងមិនទាន់បានប្រើប្រាស់នៅឡើយ។ ធនធានទាំងនេះនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍទេសចរណ៍របស់ខេត្ត។ កត្តាសន្តិសុខ និងសុវត្ថិភាពល្អក៏ជាចំនុចសំខាន់មួយដែរក្នុងការទាក់ទាញទេសចរឲ្យមកខេត្តនេះ។ លើសពីនេះទៀត ការវិភាគបង្ហាញថា ខេត្តនឹងផ្តល់ឱកាសច្រើនសម្រាប់ការវិនិយោគលើវិស័យទេសចរណ៍ ស្របគ្នានឹងការកើនឡើងនៃចំនួនភ្ញៀវទេសចរគួរឱ្យកត់សម្គាល់ និងការគាំទ្រពេញទំហឹងពីអាជ្ញាធរខេត្ត និងភាគីពាក់ព័ន្ធក្នុងខេត្ត។ តែទោះជាយ៉ាងណាក៏ដោយ នៅមានការគំរាមកំហែងមួយចំនួន ដែលតម្រូវឲ្យភាគីពាក់ព័ន្ធទាំងឡាយរួមគ្នាដោះស្រាយទើបទទួលបានលទ្ធផលល្អ។ ក្រៅពីនេះ នៅមានចំនុចខ្សោយមួយចំនួនដែលត្រូវបាន និងកំពុងកែប្រែជាបន្តបន្ទាប់ដើម្បីធ្វើឲ្យប្រសើរឡើង និងសម្រេចបានចក្ខុវិស័យអភិវឌ្ឍន៍ទេសចរណ៍ដែលខេត្តចង់បាន។ ក្នុងការធ្វើវិភាគសំយោគដោយប្រើប្រាស់ចំនុចខ្លាំង ដើម្បីឈោងចាប់យកឱកាសកែប្រែចំនុចខ្សោយ និងដោះស្រាយការគំរាមកំហែងបានផ្តល់ពន្លឺជាទិសដៅយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រទាំងឡាយដែលលើកឡើងក្នុងផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្មខេត្តមណ្ឌលគិរីនេះ ។

**តារាងទី ៥ ៖ ការវិភាគចំណុចខ្លាំង ខ្សោយ ឱកាស និងការគំរាមកំហែង**

| ចំណុចខ្លាំង | ចំណុចខ្សោយ |
|---|---|
| - ធនធានធម្មជាតិ និងវប្បធម៌សម្បូរបែបសម្រាប់ការអភិវឌ្ឍទេសចរណ៍ជាច្រើនទម្រង់ និងច្រើនខ្នាត<br>- ភាពប្លែកពីគេនៃទេសភាព វាលស្មៅ និងអាកាសធាតុត្រជាក់បរិសុទ្ធ<br>- មានសន្តិសុខ និងសុវត្ថិភាពល្អ<br>- ហេដ្ឋារចនាសម្ព័ន្ធនានាក្នុងខេត្តកំពុងត្រូវបានកសាង<br>- មានចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍ទេសចរណ៍ច្បាស់លាស់<br>- មានការកើនឡើងនូវចំនួនអ្នកវិនិយោគ<br>- មានអង្គការដៃគូមួយចំនួនចូលរួមក្នុងការអភិវឌ្ឍន៍ វិស័យទេសចរណ៍ | - ការគ្រប់គ្រងទេសចរណ៍នៅមានកម្រិត<br>- ផ្លូវចូលទៅកាន់គោលដៅទេសចរណ៍នីមួយៗមានស្ថានភាពលំបាក និងរអិលនៅរដូវវស្សា( កន្លែងខ្លះមិនទាន់មានផ្លូវរថយន្តទៅដល់នៅឡើយទេ )<br>- មិនទាន់មានការវិនិយោគពេញលេញលើ វិស័យទេសចរណ៍<br>- សិទ្ធិក្នុងការគ្រប់គ្រងធនធានធម្មជាតិផ្ទាល់របស់សហគមន៍នៅមានកម្រិត<br>- ខ្វះធនធានមនុស្សក្នុងវិស័យទេសចរណ៍<br>- ការសហការលើវិស័យទេសចរណ៍ពីគ្រប់ ភាគីពាក់ព័ន្ធនៅមិនទាន់បានល្អ<br>- សេវាកម្មទេសចរណ៍ នៅមិនទាន់ត្រូវតាមស្តង់ដារ |
| **ឱកាស** | **ការគំរាមកំហែង** |
| - កំណើនភ្ញៀវទេសចរមកកាន់ខេត្តមណ្ឌលគិរីដែលជាគោលដៅថ្មី<br>- ការគាំទ្រពីអាជ្ញាធរក្នុងការដាក់វិស័យទេសចរណ៍ជា វិស័យអាទិភាពរបស់ខេត្ត<br>- ធនធានសក្តានុពលជាច្រើននៅមិនទាន់បានកែច្នៃ និងប្រើប្រាស់ក្នុងគោលដៅទេសចរណ៍<br>- មានការគាំទ្រពីអង្គការសង្គមស៊ីវិល<br>- ហេដ្ឋារចនាសម្ព័ន្ធជាច្រើនត្រូវបាន និងកំពុងសាងសង់ បង្កលក្ខណៈងាយស្រួលសម្រាប់អ្នកវិនិយោគ | - ប្រព័ន្ធអេកូឡូស៊ីមានការបំពុលពីសកម្មភាព ទេសចរណ៍<br>- មិនទាន់មានការគ្រប់គ្រងកាកសំណល់ឲ្យបានល្អ<br>- ការទន្ទ្រានដីតំបន់រមណីយដ្ឋាន និងដីព្រៃនៅតែមានជាបន្តបន្ទាប់<br>- ការអភិវឌ្ឍសំណង់អគារ ដោយគ្មានប្លង់មេអាចធ្វើឱ្យខូចខាតដល់តំបន់ទេសភាព ដែលគួរតែអភិរក្សទុក<br>- ភ្លើងឆេះព្រៃជារៀងរាល់ឆ្នាំ<br>- ការហូរចូលវប្បធម៌ពីខាងក្រៅ បង្កគ្រោះថ្នាក់ដល់ ការអភិរក្សប្រពៃណីវប្បធម៌របស់សហគមន៍ ជាពិសេសជនជាតិដើមភាគតិច |











# III. ចក្ខុវិស័យ

# III. ចក្ខុវិស័យ

ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរី មានចក្ខុវិស័យជាចំណែកមួយក្នុងការចូលរួមសម្រេចឲ្យបាននូវផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍តំបន់ឦសាន ដើម្បីជំរុញការអភិវឌ្ឍមួយដែលមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយត្រឹមត្រូវ ដែលនោះធ្វើឲ្យមានកំណើនដល់គុណប្រយោជន៍សេដ្ឋកិច្ច សង្គម វប្បធម៌ និងសុខភាពបរិស្ថាន និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

ចក្ខុវិស័យសម្រាប់ការអភិវឌ្ឍទេសចរណ៍ខេត្តមណ្ឌលគិរី រយៈពេល០៥ឆ្នាំខាងមុខ (២០២១- ២០២៥) ត្រូវបានកំណត់ថា ខេត្តមណ្ឌលគិរីនឹងក្លាយជាគោលដៅទេសចរណ៍វប្បធម៌ និងធម្មជាតិ ជាគំរូប៉ូលសេដ្ឋកិច្ចទី៤ (ភាគឦសាន្ត) មានទេសចរមកទស្សនាកើនឡើង និងលើកកម្ពស់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងខេត្ត ។

ការជំរុញទេសចរណ៍វប្បធម៌ និងធម្មជាតិគឺធ្វើឡើងប្រកបដោយការទទួលខុសត្រូវ និងធានានិរន្តរភាព ដោយស្រូបយកផលប្រយោជន៍ពីវិស័យទេសចរណ៍ដើម្បីរួមចំណែកកសាងសេដ្ឋកិច្ចសង្គមបង្កើនឱកាសការងារ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋសហគមន៍។ ផែនការអភិវឌ្ឍន៍ទេសចរណ៍ខេត្តនេះ គឺត្រូវសម្រេចឲ្យបានទាំងបរិមាណ និងគុណភាព ដោយប្រើប្រាស់ឲ្យអស់លទ្ធភាពនូវធនធានសក្តានុពល ដែលមានប្រកបដោយមនសិការ និងត្រូវគោរពដល់តម្លៃវប្បធម៌សង្គមជាតិទាំងមូល។ ជាពិសេសឆ្លើយតបតាមនិន្នាការទេសចរណ៍ជាតិ តំបន់ និងសកល គឺការអភិវឌ្ឍទេសចរណ៍បៃតង។

ដើម្បីសម្រេចឲ្យបានចក្ខុវិស័យខាងលើនេះ ការអភិវឌ្ឍទេសចរណ៍ខេត្ត ត្រូវធ្វើឡើងទៅតាមគោលការណ៍គ្រឹះជាមូលដ្ឋានទាំង ០៨ យ៉ាង ដូចខាងក្រោម៖

១. ប្រើប្រាស់ឱ្យបានសមស្រប និងអស់លទ្ធភាពនូវធនធានធម្មជាតិ និងវប្បធម៌មូលដ្ឋានសម្រាប់វិស័យទេសចរណ៍ដោយគិតគូរពីផលប៉ះពាល់អវិជ្ជមាន ព្រមទាំងធ្វើការផ្សព្វផ្សាយ និងជំរុញការអភិរក្សធនធានទាំងនោះ។

២. ជំរុញលើកទឹកចិត្តការបង្កើតអេកូទេសចរណ៍ខ្នាតតូចមានផលប៉ះពាល់តិចតួច និងជួយបណ្តុះបណ្តាលវិជ្ជាជីវៈពាក់ព័ន្ធនឹងទេសចរណ៍ដល់សហគមន៍មូលដ្ឋាន ។

៣. អភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរីទៅជាគោលដៅទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ ធម្មជាតិ និងកែច្នៃប្រកបដោយភាពទាក់ទាញ និងមាននិរន្តរភាពដើម្បីទាក់ទាញភ្ញៀវទេសចរជាតិអាចមកទស្សនាកំសាន្តបានចំនួន ៣៩២,២៩៧នាក់ និងទេសចរអន្តរជាតិចំនួនប្រហែលជាជិត ១៨,៤៧០នាក់ ឆ្នាំ២០២៥ ដើម្បីរួមចំណែកលើកកម្ពស់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងខេត្តមណ្ឌលគិរី។

៤. ធ្វើពិពិធកម្មផលិតផល និងសេវាកម្មទេសចរណ៍ក្នុងខេត្តធានាឲ្យបានគុណភាពនៃផលិតផល និងសេវាកម្មទាំងនោះ ។

៥. បង្កើនចំណូលនិងឱកាសការងារតាមរយៈវិស័យទេសចរណ៍ដែលនាំទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាននិងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

៦. បង្កើនការអប់រំតាមរយៈវិស័យទេសចរណ៍ ដើម្បីការអភិវឌ្ឍសហគមន៍មូលដ្ឋាន និងការ ផ្ដល់សេវាកម្មទេសចរណ៍ប្រកបដោយគុណភាព ។

៧. បង្កើននូវកិច្ចសហប្រតិបត្តិការវិស័យទេសចរណ៍ពីគ្រប់ភាគីពាក់ព័ន្ធ រួមមានៈ ផ្នែករដ្ឋ ផ្នែកឯកជន ដៃគូអភិវឌ្ឍ និងប្រជាពលរដ្ឋ ដោយអនុញ្ញាតឲ្យគ្រប់ផ្នែកទាំងអស់ចូលរួមក្នុងការអភិវឌ្ឍទេសចរណ៍តាមលក្ខណៈជាប្រព័ន្ធ និងធ្វើសមាហរណកម្មក្នុងផែនការអភិវឌ្ឍន៍ខេត្ត ។

៨. លើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងប្រើប្រាស់មូលដ្ឋានគតិយុត្ត ដើម្បីធានាការបែងចែកដោយសមធម៌និងការការពារផលប្រយោជន៍ស្របច្បាប់របស់គ្រប់ភាគីពាក់ព័ន្ធធានាបានការអភិវឌ្ឍទេសចរណ៍ប្រកបដោយគុណភាព និរន្តរភាព និងការទទួលខុសត្រូវ។












# IV. គោលបំណង និង គោលដៅនៃការអភិវឌ្ឍ

# IV. គោលបំណង និងគោលដៅនៃការអភិវឌ្ឍ

### ១- គោលបំណង

ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរី គឺជាឯកសារផែនការមួយដែលបានរៀបចំឡើងស្របទៅតាមផែនការយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍វិស័យទេសចរណ៍ ២០២១-២០៣៥ របស់ក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍តំបន់ឦសាន និងស្របតាមតម្រូវការចាំបាច់នៃការអភិវឌ្ឍទេសចរណ៍របស់ខេត្ត ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ ។

ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរី មានចរិតជាឯកសារតម្រង់ទិសសម្រាប់ក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ខេត្ត ដោយប្រមូលផ្តុំនូវព័ត៌មានសំខាន់ៗ ការវិភាគស្ថានភាព និងប្រភពធនធានសក្តានុពលសម្រាប់វិនិយោគលើវិស័យទេសចរណ៍ ដើម្បីដាក់ចេញជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ខេត្តក្នុងក្តីសង្ឃឹមយ៉ាងមុតមាំថា ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃវិស័យនេះ នឹងបានជាផលប្រយោជន៍ដល់ប្រជាពលរដ្ឋទូទាំងខេត្ត និងរួមចំណែកយ៉ាងសំខាន់ដល់ការថែរក្សាការពារ និងអភិរក្សសម្បត្តិវប្បធម៌ និងធនធានធម្មជាតិ ព្រមទាំងការទប់ទល់ដល់ការប្រែប្រួលអាកាសធាតុជាសកល ។ ឯកសារផែនការនេះ នឹងជំរុញឲ្យមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយទាំងក្នុង និងក្រៅប្រទេស ស្តីអំពីទេសចរណ៍ធម្មជាតិ និងនាំឲ្យមានការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍ប្រកបដោយវិជ្ជាជីវៈ។

ផែនការអភិវឌ្ឍទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរី មានគោលបំណងអភិវឌ្ឍន៍ដូចខាងក្រោម៖

១. ជំរុញវិស័យទេសចរណ៍របស់ខេត្ត ឲ្យក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធិភាពក្នុងការអភិរក្សធនធានធម្មជាតិ ធនធានវប្បធម៌មូលដ្ឋាន និងជាគោលដៅទាក់ទាញបំផុត។

២. កែលម្អរមណីយដ្ឋានទេសចរណ៍ សហគមន៍ទេសចរណ៍ សហគមន៍អេកូទេសចរណ៍ដែលមានស្រាប់ដោយតម្រង់ទិសឲ្យស្របទៅនឹងបទដ្ឋាន នៃចលនាប្រឡងប្រណាំងរមណីយដ្ឋាន និងសហគមន៍ទេសចរណ៍គំរូ។

៣. លើកទឹកចិត្តចំពោះសហគមន៍ ឬវិស័យឯកជនក្នុងការវិនិយោគឬបង្កើតកន្លែងកម្សាន្តទាំងកែច្នៃ និងធម្មជាតិឲ្យបានច្រើនបន្ថែមទៀតសម្រាប់បម្រើការកម្សាន្តរបស់ភ្ញៀវទេសចរ រួម ចំណែកបង្កើនការងារជូនប្រជាពលរដ្ឋ បង្កើនប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រ។

៤. បង្កើនផលិតផលទេសចរណ៍ថ្មីៗ និងប្លែកៗ ប្រកបដោយគុណភាព ដើម្បីផ្គត់ផ្គង់ទីផ្សារ ទេសចរណ៍មានកសិទេសចរណ៍ ដោយប្រែក្លាយកសិដ្ឋានចម្ការហូបផ្លែទៅជាទីកន្លែងកម្សាន្ត ផ្តល់បទពិសោធន៍ចំពោះវិស័យកសិកម្ម និងប្រែក្លាយតំបន់ទាក់ទាញធម្មជាតិដែលមាន សក្តានុពលផ្សារភ្ជាប់ នឹងសហគមន៍ឲ្យក្លាយជាតំបន់អេកូទេសចរណ៍។

## ២- គោលដៅ

ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍វិស័យទេសចរណ៍ ទាមទារឲ្យមានការយកចិត្តទុកដាក់ចូលរួមសហការពីគ្រប់ស្ថាប័នពាក់ព័ន្ធនានាជាពិសេសសាមីមន្ទីរទេសចរណ៍ផ្ទាល់ត្រូវយកចិត្តទុកដាក់ជាចម្បងទៅលើគុណភាពធនធានមនុស្ស ដោយធ្វើការពង្រឹងបំប៉នសមត្ថភាពសិក្សាចំណេះដឹងថ្មីៗប្រកបដោយគុណភាព និងគុណធម៌ដល់មន្ត្រីបុគ្គលិកក្នុងអង្គភាព ដើម្បីឲ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់ សម្រេចឲ្យបាននូវគោលបំណង និងទិសដៅខាងលើ។

ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរីនេះ មានគោលដៅ ៖

- លើកកម្ពស់ការអភិវឌ្ឍទេសចរណ៍នៅខេត្តមណ្ឌលគិរី ឲ្យក្លាយជាវិស័យអាទិភាពមួយរួមចំណែកបង្កើនប្រាក់ចំណូល ឱកាសការងារ និងកាត់បន្ថយភាពក្រីក្រក្នុងសហគមន៍មូលដ្ឋាន
- ជំរុញឲ្យទេសចរណ៍ក្លាយជាយន្តការដ៏មានប្រសិទ្ធភាពមួយក្នុងការរួមចំណែកថែរក្សា និងអភិរក្សធនធានធម្មជាតិ និងវប្បធម៌របស់ខេត្ត ដែលកំពុងទទួលរងការគំរាមកំហែងពីការដកហូត និងប្រើប្រាស់ដោយគ្មាននិរន្តរភាព។
- លើកតម្កើងកិត្យានុភាពរបស់ខេត្ត ឲ្យក្លាយជាគោលដៅអេកូទេសចរណ៍មួយដ៏ល្បីល្បាញក្នុងប្រទេស និងលើពិភពលោក។
- ផ្សព្វផ្សាយពីសក្តានុពលទេសចរណ៍ និងចក្ខុវិស័យអភិវឌ្ឍន៍ទេសចរណ៍របស់ខេត្ត ដើម្បីទាក់ទាញអ្នកវិនិយោគដៃគូអភិវឌ្ឍនានាឲ្យមកចូលរួមចំណែកក្នុងដំណើរការអភិវឌ្ឍន៍ប្រកបដោយស្មារតីទទួលខុសត្រូវ។
- រួមចំណែកអនុវត្ត គោលនយោបាយជាតិលើវិស័យទេសចរណ៍ និងបទដ្ឋានគតិយុត្តិនានា ដែលដាក់ចេញដោយក្រសួងទេសចរណ៍។
- កៀរគរការចូលរួម និងសហការពីគ្រប់ភាគីពាក់ព័ន្ធ (4Ps) មានផ្នែករដ្ឋ ផ្នែកឯកជន ដៃគូអភិវឌ្ឍ និងសហគមន៍មូលដ្ឋានព្រមទាំងភ្ញៀវទេសចរដើម្បីធានាឲ្យការអភិវឌ្ឍទេសចរណ៍នៅខេត្តមណ្ឌលគិរីប្រកបដោយប្រសិទ្ធភាព និរន្តភាព និងការទទួលខុសត្រូវ ។

**តារាងទី ៦ ៖ ការព្យាករណ៍សូចនាករទេសចរណ៍ ឆ្នាំ២០២១-២០២៥**

| សូចនាករទេសចរណ៍ | ឯកតា | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|---|---|
| ទេសចរអន្តរជាតិ | នាក់ | ៦,០៩៦ | ៧,៦២០ | ១០,២៨៧ | ១៣,៨៨៧ | ១៨,៤៧០ |
| ទេសចរជាតិ | នាក់ | ២២៤,២៩៧ | ២៥៧,៩៤១ | ២៩៦,៦៣៣ | ៣៤១,១៨២ | ៣៩២,២៩៧ |
| សេវាស្នាក់នៅ | បន្ទប់ | ១,៧១២ | ១,៩៥២ | ២,២២៥ | ២,៥៣៧ | ២,៨៩២ |
| កម្លាំងពលកម្មបម្រើឲ្យវិស័យ ទេសចរណ៍ | នាក់ | ២,១៧៨ | ៣,១៨៥ | ៤,៥៧៩ | ៦,៦៤៦ | ៩,៦២៧ |
| ចំណូលទេសចរណ៍ | លានរៀល | ៤,៨៧៦ | ៦,០៩៦ | ៨,២២៩ | ១១,១០៩ | ១៤,៧៧៦ |

ប្រភព៖ មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី















# V. ក្របខ័ណ្ឌ អភិវឌ្ឍន៍ទេសចរណ៍

**៥.១ ការវិភាគការអភិវឌ្ឍទេសចរណ៍**

*៥.១.១ ការអភិវឌ្ឍផលិតផលទេសចរណ៍ និងគុណភាពសេវាកម្ម*
*៥.១.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍*
*៥.១.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍*
*៥.១.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន*
*៥.១.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង*
*៥.១.៦ ការអភិវឌ្ឍធនធានមនុស្ស និងសមភាពយេនឌ័រក្នុងវិស័យទេសចរណ៍*
*៥.១.៧ ការវិនិយោគក្នុងវិស័យឧស្សាហកម្មទេសចរណ៍*
*៥.១.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ*

**៥.២ ទិសដៅអភិវឌ្ឍន៍ទេសចរណ៍**

*៥.២.១ ការអភិវឌ្ឍផលិតផលទេសចរណ៍ និងគុណភាពសេវាកម្ម*
*៥.២.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍*
*៥.២.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍*
*៥.២.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជាមាន*
*៥.២.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង*
*៥.២.៦ ការអភិវឌ្ឍធនធានមនុស្ស និងសមភាពយេនឌ័រក្នុងវិស័យទេសចរណ៍*
*៥.២.៧ ការវិនិយោគក្នុងវិស័យទេសចរណ៍*
*៥.២.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ*

**៥.៣ ផែនការសកម្មភាពអាទិភាព**

*៥.៣.១ ការអភិវឌ្ឍផលិតផលទេសចរណ៍ និងគុណភាពសេវាកម្ម*
*៥.៣.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍*
*៥.៣.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍*
*៥.៣.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន*
*៥.៣.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង*
*៥.៣.៦ ការអភិវឌ្ឍធនធានមនុស្ស និងសមភាពយេនឌ័រក្នុងវិស័យទេសចរណ៍*
*៥.៣.៧ ការវិនិយោគក្នុងវិស័យទេសចរណ៍*
*៥.៣.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ*

# V. ក្របខ័ណ្ឌអភិវឌ្ឍន៍ទេសចរណ៍

## ៥.១ ការវិភាគការអភិវឌ្ឍទេសចរណ៍

ទោះបីជាខេត្តមណ្ឌលគិរី មានសក្តានុពលខ្ពស់ចំពោះការអភិវឌ្ឍវិស័យទេសចរណ៍ ភ្ញៀវជាតិ អន្តរជាតិមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំប្រកបដោយនិរន្តរភាពនៅក្នុងខេត្តមណ្ឌលគិរីក៏ដោយក៏ការអភិវឌ្ឍវិស័យទេសចរណ៍នៅមានការជួបឧបសគ្គ និងបញ្ហាប្រឈមមួយចំនួននាពេលបច្ចុប្បន្ននេះ ដែលតម្រូវឲ្យមានការពិនិត្យឆ្លុះបញ្ចាំង និងដោះស្រាយជាជំហ៊ានៗ ដូចជាៈ

### ៥.១.១ ការអភិវឌ្ឍផលិតផលទេសចរណ៍ និងពង្រឹងគុណភាពសេវាកម្ម

ការទាក់ទាញភ្ញៀវទេសចរបន្ថែម និងការផ្សព្វផ្សាយឲ្យភ្ញៀវទេសចរដែលមកទស្សនាម្តងហើយ ហើយមកទស្សនាជាលើកទីពីរ និងទីបីទៀត គឺជាការចាំបាច់ណាស់អាស្រ័យលើការអភិវឌ្ឍសម្បទាទេសចរណ៍ថ្មីៗ ប្លែកៗ និងប្រកបដោយគុណភាព។ ការអភិវឌ្ឍផលិតផលទេសចរណ៍នេះ វាជាយន្តការ និងយុទ្ធសាស្ត្រដ៏ល្អមួយក្នុងការទាក់ទាញភ្ញៀវទេសចរឲ្យមកកំសាន្ត ហើយការអភិវឌ្ឍផលិតផល ទេសចរណ៍នេះទៀតសោធន៍ មិនត្រឹមតែពឹងផ្អែកលើធនធានដែលមានស្រាប់នៅក្នុងតំបន់ យកមករៀបចំប៉ុណ្ណោះទេ ប៉ុន្តែយើងត្រូវធ្វើការរៀបចំបន្ថែមទៀតរាល់ប្រភពសក្តានុពលដែលអាចធ្វើការអភិវឌ្ឍច្នៃប្រឌិត ធ្វើពិពិធកម្មឲ្យមានលក្ខណៈផ្សេងៗគ្នា ដើម្បីបំពេញតម្រូវការរបស់អ្នកទស្សនា ហើយផលិតផលនោះត្រូវតែមានគុណភាព និងជាលក្ខណៈថ្មីហើយប្លែក។ ផលិតផលទេសចរណ៍នៅក្នុងខេត្តមានតិច មានលក្ខណៈ ដដែលៗគ្មានការប្រែប្រួល និងស្រាវជ្រាវអភិវឌ្ឍន៍បន្ថែម ហើយការរៀបចំសេវាកម្មទេសចរណ៍មិនបានគ្រប់គ្រាន់ និងគុណភាពមិនទាន់បានល្អប្រសើរ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ភ្ញៀវវាក៏ជាកត្តាប៉ះពាល់ដល់កំណើន ភ្ញៀវទេសចរមកកាន់តំបន់ផងដែរ។

ការរៀបចំបរិស្ថានស្អាត ការគ្រប់គ្រងកាកសំណល់ ការផ្គត់ផ្គង់ប្រព័ន្ធទឹកស្អាត ថាមពលអគ្គិសនីគ្រប់គ្រាន់ ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដូចជា បង្គន់អនាម័យសាធារណៈ និងតាមតំបន់រមណីយដ្ឋានទេសចរណ៍ ការជំរុញការអភិវឌ្ឍសម្បទាទេសចរណ៍នេះមានលក្ខណៈយឺតយ៉ាវរបស់ខេត្ត វាជាកត្តាអាចទទួលរងនូវផលអវិជ្ជមាននៃលំហូរភ្ញៀវទេសចរមកកំសាន្តក្នុងខេត្ត។

សេវាកម្មទេសចរណ៍ជាការប្រកួតប្រជែងនឹងបណ្តាប្រទេសជិតខាង និងជាចំណុចដ៏សំខាន់ផងដែរក្នុងការទាក់ទាញភ្ញៀវទេសចរបន្ថែម។ ការរៀបចំសេវាកម្មល្អ និងមានគុណភាពសំរាប់បំរើដល់ភ្ញៀវទេសចរណ៍ វាជាយុទ្ធសាស្ត្រមួយក្នុងការប្រមូលកៀរគររាល់គ្រប់ប្រភេទភ្ញៀវទេសចរមកកាន់តំបន់។

ថ្វីត្បិតតែអេកូទេសចរណ៍ សហគមន៍ទេសចរណ៍កំពុងត្រូវបានចាប់អារម្មណ៍ពីសំណាក់ភ្ញៀវទេសចរជាតិ និងអន្តរជាតិដែលមកទស្សនាខេត្តមណ្ឌលគិរីក៏ដោយ ក៏មានផលិតផលទេសចរណ៍ផ្សេងៗទៀតដែលភ្ញៀវអន្តរជាតិចូលចិត្តមកទស្សនាកម្សាន្តផងដែរ នៅតាមតំបន់ការពារធម្មជាតិ តំបន់ឧទ្យានជាតិជាលក្ខណៈទេសចរណ៍ផ្សងព្រេង តែការរៀបចំតំបន់ទស្សនាទាំងនោះខ្លះពុំទាន់មានការសិក្សា និងស្តង់ដា ត្រឹមត្រូវនៅឡើយ ដូចជាការកំណត់តំបន់កំសាន្តទឹកធ្លាក់ តំបន់បោះតង់ តំបន់ទស្សនាសត្វព្រៃកម្រ ។ល។

ខេត្តមណ្ឌលគិរី ជាខេត្តដែលមានសក្តានុពលទេសចរណ៍ខ្ពស់ មានតំបន់ធម្មជាតិស្រស់ត្រកាល និងសីតុណ្ហភាពអំណោយផលដល់ការកម្សាន្ត ស្នាក់នៅ មិនតែប៉ុណ្ណោះវប្បធម៌ជនជាតិដើមភាគតិចព្នងនៅតាមបណ្តាជ្រលងភ្នំក៏មានច្រើន និងមានសក្តានុពលខ្ពស់ក្នុងការទាញទេសចរ ប៉ុន្តែមិនទាន់មានការរៀបចំផែនការមេច្បាស់លាស់ ដើម្បីគ្រប់គ្រងឲ្យមានប្រសិទ្ធិភាពនៅឡើយ។ ចំណែកការរៀបចំព្រឹត្តការណ៍ទាក់ទាញ និងសកម្មភាពកម្សាន្តផ្សេងៗ ទាំងក្នុងទីក្រុង និងតំបន់ធម្មជាតិទាំងនោះនៅមានកម្រិតតិចតួចនៅឡើយ។

**៥.១.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍**

ទោះបីជាការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍របស់ខេត្តមណ្ឌលគិរីនៅមានកំរិត ប៉ុន្តែយន្តការ និងសកម្មភាពជាច្រើនដែលរួមគ្នាដោយរដ្ឋ និងឯកជន បានជំរុញលើកកម្ពស់កិត្យានុភាពខេត្ត ក៏ដូចជាខេត្តនានាទូទាំងប្រទេសកម្ពុជាផងដែរ។ ក្នុងនោះយុទ្ធនាការផ្សព្វផ្សាយ ***“កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ”*** និងចលនាប្រឡងប្រណាំង ***“ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ”*** ដែលត្រូវបានទទួលការចូលរួមគាំទ្រជ្រួតជ្រាបជាសកល។

ការចូលរួមរបស់វិស័យឯកជនក្នុងការផ្សព្វផ្សាយផលិតផលទេសចរណ៍ នៅពុំទាន់ស៊ីសង្វាក់គ្នា ដោយការផ្សព្វផ្សាយដាច់ដោយឡែកពីគ្នា និងសម្ភារៈផ្សព្វផ្សាយទេសចរណ៍ទាំងនោះ គុណភាព និងបរិមាណនៅមានកម្រិត និងការផ្សព្វផ្សាយពុំទាន់បានចំគោលដៅប្រព័ន្ធបច្ចេកទេស ដែលជាបញ្ហាតម្រូវឲ្យអ្នកអនុវត្តត្រូវរិះរកយុទ្ធសាស្ត្រដោះស្រាយជាជំហានៗ ។

បច្ចុប្បន្ននេះ ខេត្តមណ្ឌលគិរីពុំទាន់មានការអង្កេត និងសិក្សាស្រាវជ្រាវទីផ្សារទេសចរណ៍ច្បាស់លាស់នៅឡើយ ការខ្វះនូវការសិក្សាទីផ្សារនេះធ្វើឲ្យមានការលំបាកក្នុងការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍ ការបង្កើតផលិតផលទេសចរណ៍ ផែនការទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ឲ្យចំគោលដៅ និងមានប្រសិទ្ធភាព ។

**៥.១.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍**

ខេត្តមណ្ឌលគិរីជាច្រកទេសចរណ៍ដ៏សំខាន់បន្ទាប់ពីសៀមរាប ភ្នំពេញ និងក្រុងព្រះសីហនុ ហើយក៏ជាខេត្តមួយក្នុងខេត្តបណ្តាខេត្តទាំងបួនរបស់តំបន់ភូមិភាគឦសានផងដែរ តែហេដ្ឋារចនាសម្ព័ន្ធសម្រាប់តភ្ជាប់មិនទាន់ឆ្លើយតបទៅតាមតម្រូវការឡើយ។ ភ្ញៀវទេសចរអាចទៅដល់ទីរួមខេត្តមណ្ឌលគិរីតាមមធ្យោបាយធ្វើដំណើរនាពេលបច្ចុប្បន្ននេះតាមរថយន្តក្រុង រថយន្តដឹកអ្នកដំណើរ តាក់ស៊ីឯកជន និងរថយន្តឈ្នួលផ្សេងៗទៀត ដោយឡែកខេត្តក៏មានផងដែរព្រលានយន្តហោះក្នុងស្រុក ក៏ប៉ុន្តែពុំទាន់ដំណើរការ ត្រឹមត្រូវនៅឡើយ។

ការធ្វើដំណើរពីភ្នំពេញទៅមណ្ឌលគិរី ដោយធ្វើដំណើរឆ្លងកាត់ផ្លូវជាតិលេខ ៦ លេខ ៧ និងលេខ ៧៦ មានចំងាយ ៣៨២ គីឡូម៉ែត្រ (ភ្នំពេញ-ស្គន់-ស្នួល-មណ្ឌលគិរី) ហើយយើងក៏អាចធ្វើដំណើរតាមផ្លូវមួយទៀត ដោយឆ្លងកាត់ផ្លូវជាតិលេខ ៦ លេខ ៨ លេខ ៧ និងលេខ ៧៦ ដែលមានចំងាយ ៣៥៨ គីឡូម៉ែត្រ (ភ្នំពេញ-ព្រែកតាមាក់-ក្រែក-ស្នួល-មណ្ឌលគិរី)។ ម៉្យាងវិញទៀតការមកទស្សនាខេត្តមណ្ឌលគិរី ទេសចរអាចចេញដំណើរពីខេត្តរតនគីរីមកមណ្ឌលគិរីដែលមានចំងាយផ្លូវប្រមាណ ១៥៣គ.ម តាមផ្លូវជាតិលេខ៧៦ ដោយឆ្លងកាត់ស្រុកកោះញែកដែលតាមដងផ្លូវអមដោយភូមិប្រជាពលរដ្ឋ និងព្រៃឈើដ៏ស្រស់ត្រកាលនិងងាយស្រួលភ្ជាប់ការ

ទស្សនាខេត្តពីរក្នុងគោលដៅតែមួយ។ ការភ្ជាប់ខ្សែទស្សនកិច្ចពីប៉ូលសៀមរាបអង្គរមកមណ្ឌលគិរីដោយឆ្លងកាត់តាមខេត្តកំពង់ធំ និងខេត្តកំពង់ចាមរួចបន្តដំណើរតាមស្នួលដោយធ្វើដំណើរតាមរថយន្តឆ្លងកាត់ចំការកៅស៊ូ ដំណាំហូបផ្លែ ភូមិប្រជាពលរដ្ឋនៅតាមដងផ្លូវ។ ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ពាក់ព័ន្ធ ក្នុងស្ថានភាពបច្ចុប្បន្ននៅខេត្តក៏ពុំទាន់ឆ្លើយតបតាមតម្រូវការរបស់ភ្ញៀវទេសចរបានគ្រប់គ្រាន់នៅឡើយ ដូចជា ផ្លូវក្នុងក្រុងភាគច្រើនពុំទាន់បានរៀបចំល្អ និងផ្លូវជាតិសំខាន់ៗ តភ្ជាប់ទៅកាន់ខេត្តមានលក្ខណៈចង្អៀតនៅឡើយ។

ភាគច្រើននៃការមកដល់របស់ភ្ញៀវទេសចរ គឺប្រព្រឹត្តទៅតាមរថយន្ត ដែលត្រូវតែមានការគិតគូរដល់ការរៀបចំនូវចំណតសាធារណៈ និងទីតាំងចំណតច្បាស់លាស់របស់រថយន្តក្រុង រថយន្តអ្នកដំណើរ រថយន្តទេសចរណ៍និងការរៀបចំចំណតផ្សារក្នុងខេត្ត ដែលបង្កអោយមានការកកស្ទះជាយថាហេតុនៅក្នុងក្រុង និងបង្កឲ្យមានគ្រោះថ្នាក់នៅតាមដងផ្លូវ។

### ៥.១.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន

#### ក. សន្តិសុខ សុវត្ថិភាពទេសចរណ៍

បង្ហាញឲ្យយើងដឹងកាន់តែច្បាស់នូវបញ្ហាដែលអាចកើតមានឡើងដល់ភ្ញៀវទេសចរដូចជា បញ្ហាកេងបន្លំរបស់ជនខិលខូចមួយចំនួនលក់ផលិតផលក្លែងក្លាយ ដើម្បីបោកប្រាស់ភ្ញៀវទេសចរ ភាពអនាធិបតេយ្យរបស់អ្នកនាំភ្ញៀវនិងសេវាកម្មដឹកជញ្ជូនយកតម្លៃហួសកំរិត អនាម័យម្ហូបអាហារ ការស្នាក់នៅ និងបញ្ហាគ្រោះថ្នាក់ជាយថាហេតុផ្សេងៗ ជាដើម គឺតម្រូវឲ្យយើងប្រុងប្រយ័ត្នទុកជាមុន ដើម្បីធានាបានសន្តិសុខ សុវត្ថិភាព និងសុខដុមមនារបស់ភ្ញៀវនិងដើម្បីជួយដល់ការលើកមុខមាត់របស់ខេត្តក្នុងការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវខ្ពស់ ហើយស្របតាមគោលនយោបាយ ការអភិវឌ្ឍភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព។

ការពង្រឹងសុវត្ថិភាពទេសចរភាគច្រើន គឺជាតួនាទី និងភារកិច្ចរបស់ស្ថាប័នសាធារណៈ រួមទាំងការចូលរួមពីវិស័យឯកជនធ្វើយ៉ាងណាឲ្យទេសចរពេញចិត្ត និងទទួលបានភាពកក់ក្ដៅក្នុងអំឡុងពេលនៃការស្នាក់នៅកំសាន្តតាមរយៈការអនុវត្តស្តង់ដាសុវត្ថិភាពតាមមធ្យោបាយដឹកជញ្ជូន ការស្នាក់នៅ ម្ហូបអាហារសកម្មភាពកម្សាន្ត និងព័ត៌មានសំខាន់ៗ ជាពិសេសតាមរមណីយដ្ឋាន ការការពារសន្តិសុខសណ្ដាប់ធ្នាប់ និងសុវត្ថិភាពតាមទីសាធារណៈ នៅក្នុងទីក្រុង និងតំបន់រមណីយដ្ឋាន ដែលទេសចរនិយមទៅសម្រាកកម្សាន្ត។

ខេត្តមណ្ឌលគិរី ក៏ជាខេត្តគោលដៅទេសចរណ៍ដ៏ទាក់ទាញ និងមានកំណើនភ្ញៀវទេសចរជាច្រើនរៀងរាល់ឆ្នាំដែលទាមទារនូវការគ្រប់គ្រងសន្តិសុខ សុវត្ថិភាពទេសចរឲ្យបានកាន់តែល្អប្រសើរ។ ខេត្តនេះទោះបីគ្រប់ផ្នែកពាក់ព័ន្ធបានខិតខំយ៉ាងសកម្ម ប៉ុន្តែក៏នៅមានករណីអសកម្មមួយចំនួនកើតឡើងដូចជាសកម្មភាពឃាតកម្ម ការគ្រោះថ្នាក់ចរាចរណ៍ញឹកញាប់នៅផ្លូវជាតិ មានការលួចឆក់ ការបាត់បង់សម្ភារៈរបស់ភ្ញៀវនៅក្នុងសេវាស្នាក់នៅទេសចរណ៍ និងតាមរមណីយដ្ឋានធម្មជាតិ ឧទ្យានជាតិ ដែលទាមទារឲ្យសមត្ថកិច្ច គ្រប់លំដាប់ថ្នាក់ និងមន្ទីរជំនាញពាក់ព័ន្ធបន្តសហការខិតខំយកចិត្តទុកដាក់ដោះស្រាយថែមទៀតដើម្បីទប់ស្កាត់ និងលុបបំបាត់សកម្មភាពអសកម្មទាំងនេះ។

ជ្រកក្រោមស្លាកនៃការអភិវឌ្ឍវិស័យទេសចរណ៍សកម្មភាពអវិជ្ជមានមួយចំនួន អាចបង្កឲ្យមានដូចជាៈ អំពើពេស្យាចារ ការធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរមនុស្ស (ពិសេសស្ត្រី និងកុមារ) ចរាចរនិងប្រើប្រាស់គ្រឿងញៀន ឥទ្ធិពលនៃវប្បធម៌បរទេស។ល។ ឬសកម្មភាពខុសច្បាប់ផ្សេងៗ ដែលទាំងនេះជាបញ្ហាប្រឈមត្រូវទប់ស្កាត់ និង លុបបំបាត់ជាបន្ទាន់ដើម្បីកុំឲ្យខូចកិត្តិនាមរបស់ខេត្ត ដែលជាគោលដៅទេសចរណ៍ប្រកបដោយភាពទាក់ទាញ។

## ខ. ការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន

- ការអភិវឌ្ឍរីកចម្រើននៃវិស័យទេសចរណ៍ នាំឲ្យមានតម្រូវការផ្គត់ផ្គង់ក្នុងឧស្សាហកម្មទេសចរណ៍ និងវិស័យផ្សេងៗទៀត ដែលទ្រទ្រង់ឲ្យវិស័យទេសចរណ៍ ដែលភាគច្រើននាំចូលពីបរទេស ដូចជា បន្លែ ផ្លែឈើត្រី សាច់ ភេសជ្ជៈ ស្រាល្អៗ និងកំលាំងពលកម្ម ក៏ដូចសម្ភារៈសំណង់ និងគ្រឿង តុបតែងសណ្ឋាគារជាដើម។ល។ ដែលធ្វើឲ្យបាត់បង់តម្លៃសេដ្ឋកិច្ច និងថវិកាជាតិ។
- ការគ្រប់គ្រងកាន់កាប់ដីធ្លីរួមទាំងគម្រោងវិនិយោគនានា ដែលទទួលបានការអនុញ្ញាតពី រាជរដ្ឋាភិបាល ប៉ុន្តែមិនត្រូវបានអនុវត្ត ឬគ្រាន់តែកាន់កាប់ដីធ្លី ដើម្បីលក់យកប្រាក់ចំណេញ ឬ លក់គម្រោងទៅអ្នកទី៣ ដែលធ្វើឲ្យប៉ះពាល់ដល់វិនិយោគិនពិតប្រាកដ ក៏ដូចជាគម្រោងអភិវឌ្ឍ ទាក់ទាញទេសចរណ៍ទាំងមូល។
- ការរងឥទ្ធិពលផ្សេងៗនៃកត្តាខាងក្រៅដូចជា វិបត្តិសេដ្ឋកិច្ច នយោបាយ គ្រោះធម្មជាតិ និងការ រាលដាលនៃជំងឺឆ្លងជាដើម ជាពិសេសការរាលដាលនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលអវិជ្ជមាន យ៉ាងខ្លាំងទៅលើវិស័យទេសចរណ៍ ក៏ដូចជាវិស័យសេដ្ឋកិច្ចសង្គមរបស់ពិភពលោក កម្ពុជា និង ខេត្តមណ្ឌលគិរី ផងដែរ ដូចជា ការបិទឬផ្អាកមធ្យោបាយធ្វើដំណើរ ការវិនិយោគ សកម្មភាព អាជីវកម្ម ដែលធ្វើឲ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចជាតិ រួមទាំងការកាត់បន្ថយកំណើនភ្ញៀវ ទេសចរ និងពលកម្មក៏ដូចជា ការចំណាយលើការថែទាំ និងព្យាបាលអ្នកជំងឺជាដើម។
- ការអភិវឌ្ឍ និងគម្រោងវិនិយោគមួយចំនួនដែលពុំមានច្បាប់អនុញ្ញាត ឬពុំបានអនុវត្តតាម គោលការណ៍ណែនាំរបស់ក្រសួងស្ថាប័នជំនាញ ជាពិសេសការសិក្សាពីផលប៉ះពាល់គម្រោងឲ្យ បានត្រឹមត្រូវ បានធ្វើឲ្យប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ។ ទន្ទឹមនេះ ការវិនិយោគដោយ គំហុក ដោយពុំមានការគ្រប់គ្រងបានត្រឹមត្រូវ និងច្បាស់លាស់បណ្តាលឲ្យមានបញ្ហាលើ ការគ្រប់គ្រងសំណល់រឹង រាវក្នុងទីក្រុង និងរមណីយដ្ឋាននានាបានបង្កបញ្ហាដល់បរិស្ថាន និង ជះឥទ្ធិពលមិនល្អដល់ភ្ញៀវទេសចរក៏ដូចជាប្រជាពលរដ្ឋ។
- សំណង់លំនៅដ្ឋាន និងអាជីវកម្មមួយចំនួន ដែលពុំមានច្បាប់អនុញ្ញាត រួមទាំងការចូលរួមពីម្ចាស់ អាជីវកម្មនិងប្រជាពលរដ្ឋ ក៏ដូចជាភ្ញៀវទេសចរក្នុងការទុកដាក់ និងគ្រប់គ្រងសំណល់រឹងរាវមិន បានល្អ បានបង្កបញ្ហាបរិស្ថាន និងអនាម័យសាធារណៈនៅក្នុងទីក្រុង និងនៅតាមរមណីយដ្ឋាន នានា។
- ការគ្រប់គ្រងការវិនិយោគ និងអាជីវកម្មរបស់ជនបរទេសមួយចំនួនដែលពុំបានអនុវត្តតាមច្បាប់ ឬ គោលការណ៍ណែនាំរបស់ក្រសួងស្ថាប័នជំនាញ និងអាជ្ញាធរដែនដី ដូចជា ការលើកស្លាកយីហោ

អាជីវកម្ម ឬប៉ាណូផ្សព្វផ្សាយ ដែលមានរូបភាពអាសអាភាស និងខ្លឹមសារមិនបានត្រឹមត្រូវបានធ្វើឲ្យប៉ះពាល់តម្លៃវប្បធម៌សង្គម។

➢ សកម្មភាពអាជីវកម្មខុសច្បាប់មួយចំនួនដូចជា ការជួញដូរផ្លូវភេទ ការជួញដូរ និងប្រើប្រាស់គ្រឿងញៀននៅក្នុងសេវាកម្មកម្សាន្តទេសចរណ៍មនុស្សពេញវ័យ និងម៉ាស្សាបានបង្កបញ្ហាធ្ងន់ធ្ងរដល់សង្គមជាតិ ក៏ដូចជាទំនៀមទំលាប់ប្រពៃណីខ្មែរផងដែរ។

### ៥.១.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង

ទោះបីមានយន្តការទេសចរណ៍ជាច្រើននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែនៅខេត្តមណ្ឌលគិរីយើងទាមទារឲ្យមានយន្តការសមស្រប និងពង្រឹងកិច្ចសហការបន្ថែមទៀតដើម្បីការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ ពិសេសនៅតាមតំបន់ការពារធម្មជាតិ ឧទ្យានជាតិ ដែលមានសក្តានុពល ម៉្យាងទៀតយន្តការគ្រប់គ្រងទេសចរណ៍របស់ផ្នែកឯកជនក៏ពុំទាន់មានភាពរឹងមាំនៅឡើយ ដែលចាំបាច់ត្រូវរៀបចំបង្កើតជាសហគមន៍ទេសចរណ៍ សមាគមឧស្សាហកម្មទេសចរណ៍ ដើម្បីងាយស្រួលសហការជាមួយវិស័យសាធារណៈ ក្រសួង មន្ទីរទេសចរណ៍ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងការរួមគ្នាអភិវឌ្ឍន៍ និងពង្រីកគុណភាពសហគមន៍ និងគ្រប់សេវាកម្មវិស័យទេសចរណ៍ ក៏ដូចជា ការដោះស្រាយបញ្ហាផ្សេងៗឲ្យមានប្រសិទ្ធភាព។ ទន្ទឹមនេះ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទាំងក្របខ័ណ្ឌជាតិ និងអន្តរជាតិចាំបាច់ត្រូវតែផ្សព្វផ្សាយ និងរៀបចំឲ្យបានត្រឹមត្រូវ ដើម្បីធានានូវការគ្រប់គ្រងអនុវត្តឲ្យមានភាពរលូន និងមានប្រសិទ្ធភាពខ្ពស់។

ការពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យទេសចរណ៍ ជាយន្តការមួយសម្រាប់ធានានិរន្តភាព ក្នុងការ អភិវឌ្ឍទេសចរណ៍។ សម្រាប់វិស័យទេសចរណ៍យើងមានច្បាប់ស្តីពីទេសចរណ៍ដែលបាននិងកំពុងមានអនុភាពគតិយុត្តក្នុងការអនុវត្ត ហើយប្រព័ន្ធច្បាប់ទាំងនេះបានជួយការពង្រឹងការគ្រប់គ្រងទេសចរណ៍ប្រកប ដោយប្រសិទ្ធភាពឈានទៅសម្រេចចក្ខុវិស័យសម្រាប់ពេលអនាគត។ ក្នុងបរិបទនៃការអនុវត្តច្បាប់នេះ ខេត្តមណ្ឌលគិរី ក៏នៅមានបញ្ហាប្រឈមខ្លះដែរ ប្រការទាំងនេះបណ្តាលមកពីធនធានមនុស្សផ្នែកច្បាប់នូវមានកម្រិត។

### ៥.១.៦ ការអភិវឌ្ឍធនធានមនុស្ស និងសមាសភាពយេនឌ័រក្នុងវិស័យទេសចរណ៍

នៅខេត្តមណ្ឌលគិរី បច្ចុប្បន្នមានសាលាវិទ្យាស្ថានមួយចំនួនបង្រៀនមុខវិជ្ជាទេសចរណ៍ និងបរិញ្ញាបត្រជាន់ខ្ពស់ តែយើងនឹងត្រូវការច្រើនលើផ្នែកជំនាញសម្រាប់បម្រើនៅក្នុងឧស្សាហកម្មទេសចរណ៍។ ការបង្កើត និងដំណើរការសាលាវិជ្ជាជីវៈទេសចរណ៍ និងកម្មវិធីបណ្តុះបណ្តាលប្រកបដោយស្តង់ដាទាំងផ្នែករដ្ឋ និងឯកជនក្នុងខេត្តមណ្ឌលគិរី ដើម្បីជំរុញការបណ្តុះបណ្តាលគ្រូបង្គោល និងបណ្តុះបណ្តាលនៅនឹងកន្លែង គឺជាផែនការអាទិភាពសំខាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការនាពេលបច្ចុប្បន្ន និងថ្ងៃអនាគត។ ក្រសួង និងមន្ទីរទេសចរណ៍ចាំបាច់សិក្សាឲ្យបានលម្អិត និងច្បាស់លាស់អំពីធនធានមនុស្ស និងជំនាញវិជ្ជាជីវៈទេសចរណ៍ពិតប្រាកដដែលជាតម្រូវការជាក់ស្តែងនៅក្នុងឧស្សាហកម្មទេសចរណ៍ និងធ្វើការសម្របសម្រួលឲ្យមានបណ្តាញទំនាក់ទំនង និងជួយគ្នាទៅវិញទៅមក រវាងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងតម្រូវការជំនាញនៅក្នុងឧស្សាហកម្មទេសចរណ៍។

បញ្ហាប្រឈមមួយចំនួន ដែលតែងតែជួបប្រទះនៅក្នុងការអនុវត្តផែនការសម្រាប់ការអភិវឌ្ឍធនធានមនុស្សរួមមាន ៖

- តួនាទីជំនាញរបស់មន្ត្រីមន្ទីរពុំទាន់បានឆ្លើយតប បានតាមសំណូមពរការងារដែលកំពុងរីវឌ្ឍន៍ឈានឡើង។
- សមត្ថភាពមន្ត្រីមួយចំនួនមានកម្រិតវប្បធម៌ខ្ពស់ប៉ុន្តែនៅខ្វះបទពិសោធន៍ក្នុងការងារ
- ធនធានមនុស្សក្នុងបណ្តាសេវាកម្មឯកជន និងសហគមន៍នៅមានភាពទន់ខ្សោយក្នុងការចាប់យកការយល់ដឹងឲ្យស៊ីជម្រៅពីវិស័យទេសចរណ៍
- បណ្តាមូលដ្ឋាន សេវាកម្មឯកជនជារួមនៅមិនទាន់បានស៊ីជម្រៅពីសមភាពយេនឌ័រក្នុងការលើកកម្ពស់តួនាទីស្ត្រីក្នុងមូលដ្ឋានអាជីវកម្មរបស់ខ្លួន ពិសេសស្ត្រីបម្រើឲ្យទីតាំងអាជីវកម្មមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យរីឯមូលដ្ឋានអាជីវកម្មខ្លះទៀតនៅមិនទាន់មានតំណាងស្ត្រីសម្រាប់អង្គភាពរបស់ខ្លួននៅឡើយទេ។

### ៥.១.៧ ការវិនិយោគក្នុងវិស័យឧស្សាហកម្មទេសចរណ៍

ដោយមានសក្តានុពលទាក់ទាញ ហើយក៏ជាឱកាសមួយសម្រាប់ខេត្តមណ្ឌលគិរីធ្វើការអភិវឌ្ឍវិស័យទេសចរណ៍ ទាក់ទាញទេសចរឲ្យមកទស្សនាកម្សាន្តក្នុងខេត្ត និងបង្កើនមុខរបរបន្ថែមសម្រាប់ប្រជាពលរដ្ឋ រួមចំណែកកាត់បន្ថយភាពក្រីក្រ។ ដើម្បីបានកំណើនភ្ញៀវទេសចរ ចាំបាច់ទាមទារឲ្យមានការពង្រីកតំបន់កម្សាន្តបន្ថែមទាំងកែច្នៃ និងធម្មជាតិ ប៉ុន្តែខេត្តមណ្ឌលគិរីនៅមិនទាន់មានវិនិយោគិនណាមក បណ្តាក់ ទុនផ្នែកអេកូទេសចរណ៍ ឬវិនិយោគផ្នែករមណីយដ្ឋានច្រើននៅឡើយ ដែលទាមទារឲ្យមន្ទីរសាមីត្រូវខិតខំផ្សព្វផ្សាយអូសទាញវិនិយោគិនតាមគ្រប់រូបភាពតាមដែលអាចធ្វើបាន។

ការរៀបចំប្លង់មេនៃការអភិវឌ្ឍប្លង់ប្រើប្រាស់ដីធ្លី និងការកំណត់តំបន់អភិវឌ្ឍ (Zoning) ជាពិសេស រាល់គម្រោងអភិវឌ្ឍន៍ទេសចរណ៍នានាចាំបាច់ត្រូវមានការសិក្សា និងរៀបចំផែនការមេឲ្យបានច្បាស់ ដើម្បីបង្កើនការទាក់ទាញវិនិយោគិន និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រកបដោយស្តង់ដា សម្បទាគុណភាព និងនិរន្តរភាពស្របតាមលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលក៏ដូចជាគណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្ត និងក្រសួងស្ថាប័នជំនាញពាក់ព័ន្ធ។

### ៥.១.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ

ដោយមើលឃើញពីទិសដៅរយៈពេលវែងការអភិវឌ្ឍវិស័យទេសចរណ៍ធម្មជាតិត្រូវគិតគូរដល់ការងារគ្រប់គ្រង និងអភិរក្សធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់និងនិរន្តរភាព។ ធនធានជាច្រើនត្រូវបានមើលឃើញថា កំពុងទទួលរងការបំផ្លិចបំផ្លាញដោយសារការគ្រប់គ្រងពុំមានប្រសិទ្ធភាព។

ធនធានដែលជាលក្ខណៈទោលដូចជា វប្បធម៌ជនជាតិដើមភាគតិច និងធនធានធម្មជាតិជាច្រើនទៀត កំពុងទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងពុំទាន់មានយន្តការ អនុវត្តច្បាស់លាស់។ ការទទួលរងផលប៉ះពាល់ពីការជ្រៀតចូលនូវវប្បធម៌ ទំនៀមទំលាប់ ប្រពៃណីផ្សេងៗដល់ប្រជាជនមូលដ្ឋាន ក៏ជាបញ្ហាចោទ ដែលយើងទាំងអស់គ្នាត្រូវយកចិត្តទុកដាក់លើកិច្ចការពារ ថែរក្សា និងអភិរក្សផងដែរ ។

ការជំរុញដោយមានការទទួលខុសត្រូវខ្ពស់ពីគ្រប់ភាគីពាក់ព័ន្ធដើម្បីស្វែងរកយុទ្ធសាស្ត្រជារយៈពេលខ្លី និង វែង ក្នុងគោលបំណងរៀបចំយុទ្ធសាស្ត្ររួម ដើម្បីគ្រប់គ្រងអភិរក្សធនធានសម្បត្តិវប្បធម៌ ដែលមានស្រាប់ ដែលជាការលើកកម្ពស់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិប្រកបដោយប្រសិទ្ធភាពចីរភាព និងមានការទទួលខុសត្រូវខ្ពស់ក្នុងតំបន់ ។

លើសពីនេះទៀតនៅមានបញ្ហាប្រឈមមួយចំនួនទៀតផងដែរដូចជា ៖

- កង្វះខាតថវិកាក្នុងការរៀបចំអភិវឌ្ឍន៍ទេសចរណ៍ ជាឧបសគ្គមួយរាំងស្ទះដល់ការអភិវឌ្ឍ វិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព។
- កង្វះខាតធនធានមនុស្សក្នុងការគ្រប់គ្រងវិស័យទេសចរណ៍ មន្ត្រីជំនាញនិងមានបទពិសោធន៍សម្រាប់បំរើការងារដល់មន្ទីរទេសចរណ៍។
- រមណីយដ្ឋានសហគមន៍ទេសចរណ៍ដែលបានបង្កើតឡើងថ្មីៗ ងាយស្រួលនឹងបាត់បង់ទៅវិញដោយសារកង្វះខាតថវិកា ធនធានមនុស្សនិងគ្មានជំនាញគ្រប់គ្រងច្បាស់លាស់។
- ការចូលរួមរបស់វិស័យឯកជន ដែលបំរើក្នុងវិស័យឧស្សាហកម្មទេសចរណ៍នៅមានកម្រិត និងកង្វះចំណេះ ជំនាញក្នុងការអភិវឌ្ឍលើវិស័យទេសចរណ៍នេះ ។
- ការបែងចែកតួនាទី និងការទទួលខុសត្រូវរវាងមន្ទីរទេសចរណ៍ ជាមួយស្ថាប័នពាក់ព័ន្ធមួយចំនួនពុំទាន់ច្បាស់លាស់ និងការងារទទួលខុសត្រូវមួយចំនួនត្រួតស៊ីគ្នា។
- ការចូលរួមជាមួយស្ថាប័ន មន្ទីរពាក់ពន្ធ័មួយចំនួន និងអភិបាលកិច្ចនៅមានកម្រិត។

## ៥.២ ទិសដៅអភិវឌ្ឍន៍ទេសចរណ៍

### ៥.២.១ ការអភិវឌ្ឍផលិតផលទេសចរណ៍ និងពង្រឹងគុណភាពសេវាកម្ម

#### ក. ការពង្រឹងគុណភាពផលិតផលទេសចរណ៍តាមទស្សនទាន សេវាមួយ ស្តង់ដាមួយ

ទន្ទឹមនឹងការបង្កើតផលិតផលទេសចរណ៍ថ្មីៗ ការយកចិត្តទុកដាក់លើការពង្រឹងគុណភាពផលិតផលទេសចរណ៍ដែលមានស្រាប់ គឺមិនអាចមើលរំលងបានទេ។ នេះគឺដើម្បីធានាការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាពផង និងទាក់ទាញទេសចរបន្ថែមផង។ គុណភាពផលិតផលនិងសេវាកម្មទេសចរណ៍ក្នុងខេត្តមណ្ឌលគិរីនៅមានកម្រិតនៅឡើយ។ មិនទាន់អាចឆ្លើយតបបានទៅនឹងស្តង់ដាផលិតផល និងសេវាកម្មដែលដាក់ចេញដោយក្រសួងទេសចរណ៍ ដូចជា ចំណាត់ថ្នាក់សណ្ឋាគារ ស្តង់ដាមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ ស្តង់ដារមណីយដ្ឋាន ស្តង់ដាសេវាកម្មវិថីលក់ម្ហូបអាហារ និងតូបលក់ម្ហូបអាហារ ស្តង់ដាសហគមន៍ទេសចរណ៍ ស្តង់ដាបង្គន់សាធារណៈកម្ពុជា ស្តង់ដាផ្ទះស្នាក់ ស្តង់ដាសេវាកម្មស្ប៉ា និងមាស្សាកម្ពុជា យុទ្ធនាការភោជនីយដ្ឋានស្អាត (ភោជនីយដ្ឋានគ្មានសំរាមជាក្រដាសប្រព័ន្ធចុះបញ្ជីស្នាក់នៅទេសចរណ៍ចំណាត់ថ្នាក់ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍។ល។ ការពង្រឹងគុណភាពផលិតផល និងសេវាកម្មនេះ ទាមទារឲ្យមានការចូលរួមយ៉ាងសកម្មពីប្រតិបត្តិករទេសចរណ៍ ដោយធ្វើការសហការជាមួយមន្ទីរទេសចរណ៍ខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធដែលទទួលបន្ទុក ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាពនូវរាល់បទបញ្ញត្តិ និងស្តង់ដាសេវាកម្មជាមូលដ្ឋានដែលបានដាក់ចេញ ។

បច្ចុប្បន្នយុទ្ធនាការឃោសនាផ្សព្វផ្សាយ កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ និងចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ គឺជាយន្តការដ៏មានប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងពង្រឹងគុណភាពផលិតផលទេសចរណ៍។ ខេត្ត និងគ្រប់ស្ថាប័នពាក់ព័ន្ធក្នុងខេត្ត និងផ្នែកឯកជន បាន និងកំពុងចូលរួមជំរុញគាំទ្រអនុវត្តយុទ្ធនាការ និងចលនាប្រឡងប្រណាំងនេះយ៉ាង សកម្មផងដែរ ។ ផែនការដើម្បីឈានទៅសម្រេចទិសដៅពង្រឹងគុណភាពគឺ ៖

១. ជំរុញការអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងទេសចរណ៍៖ បង្កើនការផ្សព្វផ្សាយ ណែនាំ និងអនុវត្តដល់ប្រតិបត្តិករទេសចរណ៍ដូចជា ម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន ខារ៉ាអូខេ ម៉ាស្សា ស្តង់ដាផលិតផលអនាម័យ និងសុវត្ថិភាពចំណីអាហារដែលផ្តល់ជូនអតិថិជន។ លើសពីនេះគួរបង្កើតឲ្យមានសមាគមក្រុមអ្នកផ្តល់សេវាកម្មទេសចរណ៍ដើម្បីភាពងាយស្រួលក្នុងការគ្រប់គ្រង ដូចជា សមាគមអ្នកនាំភ្ញៀវ សមាគម ផ្ទះសំណាក់ និងសណ្ឋាគារ។ល។

២. បន្តជំរុញអនុវត្តចលនាប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងដិសណ្ឋារកិច្ចល្អ បន្តរៀបចំក្រុងសែនមនោរម្យឲ្យស្របតាមស្តង់ដាទីក្រុងស្អាត តាមរយៈក្រុមការងារទីក្រុងស្អាតថ្នាក់ខេត្តដោយសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ។ នៅតាមបណ្តារមណីយដ្ឋានដែលកំពុងដំណើរការ ត្រូវធ្វើការចុះពិនិត្យវាយតម្លៃ និងលើកគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍នានា។

៣. សហការពង្រឹងក្រុមសិប្បកម្មវត្ថុអនុស្សាវរីយ៍ ចុះពិនិត្យ វាយតម្លៃ ណែនាំ និងពង្រឹងសមត្ថភាពដល់ក្រុមសិប្បកម្មទាំង ០៥ កន្លែង រួមមាន ក្រុមសិប្បកម្មតម្បាញ សាស់ ល្អី ជនជាតិដើមភាគតិចព្នងភូមិពូតាំង ក្រុមសិប្បកម្មតម្បាញ សាស់ ល្អី ជនជាតិដើមភាគតិចព្នងភូមិពូត្រែង ក្រុមតម្បាញសំពត់កន្សែងជនជាតិដើមភាគតិចភូមិពូត្រែង ក្រុមតម្បាញសំពត់កន្សែងជនជាតិដើមភាគតិចភូមិពូឡេះ និងក្រុមសិប្បកម្មតម្បាញសំពត់ កន្សែង ជនជាតិព្នងភូមិទី៦ ឃុំប៊ូស្រា។

៤. បន្តពង្រឹង និងរៀបចំក្រុមជូនទេសចរទស្សនាជំរី នៅភូមិពូតាំង និងរៀបចំក្រុមមួយទៀតនៅភូមិពូលុង

**ខ. ការបង្កើតផលិតផលទេសចរណ៍ថ្មី**

ការបង្កើតផលិតផលទេសចរណ៍ថ្មី គឺជាកត្តាចាំបាច់ដើម្បីគាំទ្រផង និងដោះស្រាយផង ជាមួយនឹងផលិតផលដែលមានស្រាប់ដែលមិនទាន់មានភាពសម្បូរបែប ព្រមទាំងបំពេញយុទ្ធសាស្ត្រស្តីពីការផ្តល់ជម្រើសឱកាសទស្សនារបស់ភ្ញៀវឲ្យបានច្រើន ដើម្បីពន្យារពេលស្នាក់នៅ និងការចំណាយរបស់ភ្ញៀវក្នុងគោលបំណងស្រូបទាញចំណូលពីទេសចរឲ្យបានកាន់តែច្រើន។ ដោយហេតុតែផលិតផលទេសចរណ៍របស់ខេត្តមានតិចតួចនៅឡើយ កន្លងមកភ្ញៀវម្នាក់ៗ ចំណាយរយៈពេលជាមធ្យមត្រឹមតែ ០២ថ្ងៃ ប៉ុណ្ណោះ សម្រាប់ការទស្សនារបស់គេនៅក្នុងខេត្តមណ្ឌលគិរី។ ផែនការចំបងៗក្នុងការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីនេះ គឺផ្តោតជាសំខាន់លើចំនុច ០៣ យ៉ាង ៖

១. ការរៀបចំតំបន់រមណីយដ្ឋាន ដែលកំពុងដំណើរការឲ្យមានសេវាកម្មដែលនៅខ្វះខាត ស្របតាមស្តង់ដាអប្បរមាសម្រាប់រមណីយដ្ឋានទេសចរណ៍ និងសេវាកម្មសមស្របផ្សេងៗទៀត ដូចជា ផ្ទះស្នាក់សហគមន៍ ផ្ទះស្នាក់ក្នុងព្រៃ (Eco lodge) ការបង្កើតជាសកម្មភាព និងសេវាកំសាន្តផ្សេងៗទៀត ដូចជា ការដាំដើមឈើក្នុងទីតាំងសមស្រប ដើម្បីចូលរួមក្នុងចលនាទេសចរម្នាក់ ដើមឈើមួយដើម ការសម្តែងសិល្បៈប្រពៃណី

តាមភូមិការទេសចរណ៍ទស្សនាសិប្បកម្ម និងការដើរលេងក្នុងព្រៃជាមួយអ្នកភូមិជនជាតិដើមភាគតិចដើម្បីស្វែងយល់ពីធម្មជាតិ និងការរស់នៅរបស់ពួកគេ។

២. ជំរុញបង្កើតសហគមន៍អេកូទេសចរណ៍ នៅតាមតំបន់ដែនជម្រកសត្វព្រៃ៖ ទេសចរណ៍ សហគមន៍ គឺជាផលិតផលទេសចរណ៍ថ្មី ដែលខេត្តចង់បានព្រោះថា វាជាយន្តការមួយដ៏មាន ប្រសិទ្ធភាព ក្នុងការជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសជនជាតិដើមភាគតិចជាច្រើនដែលរស់នៅតាមតំបន់ព្រៃភ្នំធម្មជាតិក្នុងខេត្តនេះ។ ជាងនេះទៅទៀត ការបង្កើតទេសចរណ៍សហគមន៍នេះ ថែមទាំងជួយជំរុញដល់ការអភិរក្សធនធានធម្មជាតិដែលកំពុងទទួលរងការគំរាមកំហែងដោយការដកហូត និងកាប់ទន្រ្ទានដីខុសច្បាប់ឲ្យមកជាការប្រើប្រាស់ប្រកបដោយនិរន្តរភាពបម្រើឲ្យវិស័យទេសចរណ៍វិញ។ តែទោះជាយ៉ាងណាក៏ដោយដំណើរការបង្កើតទេសចរណ៍សហគមន៍តម្រូវឲ្យដើរតាមបទដ្ឋានគតិយុត្តមួយច្បាស់លាស់ដែលបានដាក់ចេញដោយក្រសួងទេសចរណ៍។ កិច្ចការចំពោះមុខមុននឹងឈានដល់ការបង្កើតទេសចរណ៍សហគមន៍នៅតាមតំបន់ទាំងនោះ បានតម្រូវឲ្យមានការចុះសិក្សាស្រាវជ្រាវលទ្ធភាព ដើម្បីអភិវឌ្ឍន៍គម្រោងទេសចរណ៍នៅតាមតំបន់ទាំងនោះ រួមមាន ១.ដែនជម្រកសត្វព្រៃ ណាមលៀរមណ្ឌលគិរី ២.ដែនជម្រកសត្វព្រៃភ្នំព្រេចមណ្ឌលគិរី និងក្រចេះ ៣.ដែនជម្រកសត្វព្រៃស្រែពក ៤.ដែនជម្រកសត្វព្រៃមណ្ឌលគិរី និងទី ៥.ដែនជម្រកសត្វព្រៃលំផាត់ មណ្ឌលគិរី និងរតនៈគិរី។

៣. រៀបចំព្រឹត្តិការណ៍ទេសចរណ៍នានាដែលអាចឆ្លុះបញ្ចាំងពី អត្តសញ្ញាណ និងប្រវត្តិរបស់ខេត្ត ដូចជា បុណ្យភ្នំ ការសម្តែងសិល្បៈជនជាតិ ពិព័រណ៍ម្ហូបអាហារជនជាតិ ពិធីបុណ្យប្រពៃណីជនជាតិ និងព្រឹត្តិការណ៍កីឡាដូចជា ការប្រណាំងកង់។ល។

ក្នុងការធ្វើពិពិធកម្ម ក៏តម្រូវឲ្យមានការជំរុញការយកចិត្តទុកដាក់ខ្ពស់ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍ដោយឈរលើប្រភពសម្បត្តិវប្បធម៌ និងធនធានធម្មជាតិប្រកបដោយការទទួលខុសត្រូវ ដូចមានចែងក្នុងគោលនយោបាយជាតិលើវិស័យទេសចរណ៍ និងច្បាប់ស្តីពីទេសចរណ៍។ ការប្រើប្រាស់ហួសកម្រិត និងគ្មានផែនការច្បាស់លាស់នាំឲ្យធនធានទាំងនោះបាត់បង់ ហើយការមិនខិតខំប្រើប្រាស់ឲ្យអស់លទ្ធភាពនាំឲ្យបាត់បង់ឱកាសនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ដូច្នេះ ការអភិវឌ្ឍទេសចរណ៍ក្នុងខេត្តមណ្ឌលគិរី គឺដើរតាមមាគ៌ាដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ដោយប្រកាន់យកគោលការណ៍ “ ការអភិវឌ្ឍ និងការអភិរក្សវប្បធម៌ និងធម្មជាតិត្រូវដើរទន្ទឹមគ្នា “ មានន័យថា “ មិនយកការអភិរក្ស រារាំងការអភិវឌ្ឍ “ ហើយមិនធ្វើការអភិវឌ្ឍបំផ្លាញសម្បត្តិវប្បធម៌ និងធនធានធម្មជាតិ " ។

ជាយុទ្ធសាស្ត្រ ឈ្នះ ឈ្នះ ការអភិវឌ្ឍផលិតផលទេសចរណ៍ត្រូវផ្សារភ្ជាប់ទៅនឹងការសិក្សាទីផ្សារ និងសភាពការណ៍និន្នាការទេសចរណ៍តំបន់ភូមិភាគឦសាន្ត ជាតិ និងអន្តរជាតិ ។ លើសពីនេះទៀត ការអភិវឌ្ឍផលិតផលទេសចរណ៍ ត្រូវមានពីរកម្រិតជាសំខាន់គឺ កម្រិតតូច គួរលើកទឹកចិត្តផ្តល់ជូនសហគមន៍ប្រជាពលរដ្ឋដោយផ្តោតលើការអភិវឌ្ឍទេសចរណ៍សហគមន៍ និងកម្រិតធំត្រូវមានសិក្សាច្បាស់លាស់ និងស្វែងរកការវិនិយោគដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើប និងមានការទទួលខុសត្រូវខ្ពស់។ ដើម្បីសម្រេចគោលបំណងនេះ គន្លឹះជាសំខាន់ គឺការលើកទឹកចិត្តឲ្យគ្រប់ភាគីពាក់ព័ន្ធ ផ្នែកឯកជន វិនិយោគិន ដៃគូអភិវឌ្ឍ និងប្រជាពលរដ្ឋចូលរួមក្នុងការអភិវឌ្ឍផលិតផលទេសចរណ៍ និងថែរក្សាការពារនិរន្តរភាពរបស់វា ។

### គ. ការជំរុញការអភិវឌ្ឍអេកូទេសចរណ៍ និងទេសចរណ៍សហគមន៍

ខេត្តមណ្ឌលគិរី គឺជាខេត្តមួយដែលស្ថិតនៅក្នុងភូមិភាគឦសាន្ត ដែលត្រូវបានកំណត់ថា មានសក្តានុពលសម្រាប់ការអភិវឌ្ឍអេកូទេសចរណ៍ ដោយពឹងផ្អែកលើធនធានធម្មជាតិដ៏សម្បូរបែប។ លើសពីនេះទៀតខេត្តមណ្ឌលគិរីមានជនជាតិដើមភាគតិចប្រមាណ ៤៧% ដែលរស់នៅ ភាគច្រើនតាមតំបន់ជនបទ និងព្រៃភ្នំដោយអាស្រ័យលើធនធានធម្មជាតិ និងកសិកម្មតាមប្រពៃណី។ ដូចនេះការអភិវឌ្ឍអេកូទេសចរណ៍ និងទេសចរណ៍សហគមន៍ គឺមានលទ្ធភាពច្រើន និងពិតជានឹងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់បងប្អូនទាំងនោះព្រមទាំងជួយដល់ការអភិរក្ស ធនធានធម្មជាតិ និងវប្បធម៌របស់ពួកគេឲ្យបានគង់វង្ស យូរអង្វែង។ ផែនការសម្រាប់លើកកម្ពស់ការអភិវឌ្ឍអេកូទេសចរណ៍ និងទេសចរណ៍សហគមន៍មាន ៖

១. ខិតខំអនុវត្តតាមស្មារតី នៃគោលនយោបាយជាតិអេកូទេសចរណ៍៖ រួមមានការធ្វើផែនការ និងបែងចែកជាតំបន់សក្តានុពលសម្រាប់ការអភិវឌ្ឍអេកូទេសចរណ៍ ការរៀបចំតំបន់រមណីយដ្ឋានអេកូទេសចរណ៍គំរូ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍ និងធានាគុណភាពផលិតផលក្នុងរមណីយដ្ឋានអេកូទេសចរណ៍ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយអេកូទេសចរណ៍ ការបង្កើនលទ្ធភាពធ្វើអាជីវកម្ម និងវិនិយោគអេកូទេសចរណ៍ ការធានាសុវត្ថិភាពនៅតាមរមណីយដ្ឋានអេកូទេសចរណ៍ ការបញ្ជ្រាបការយល់ដឹង និងអប់រំពីអេកូទេសចរណ៍ទៅដល់សហគមន៍ និងភ្ញៀវទេសចរ

២. សហការជាមួយគ្រប់ភាគីពាក់ព័ន្ធដើម្បីពង្រឹង និងពង្រីកការបង្កើតសហគមន៍ទេសចរណ៍ និងសហគមន៍អេកូទេសចរណ៍ ដើម្បីកិច្ចការពារបរិស្ថាន ការកាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយចំណាកស្រុក

៣. បង្កើនការពង្រឹងសមត្ថភាព បណ្តុះបណ្តាលជំនាញអេកូទេសចរណ៍ រួមមាន មគ្គុទេសក៍ទេសចរណ៍សហគមន៍ ការរៀបចំផ្ទះស្នាក់ ម្ហូបអាហារ ការទទួលបដិសណ្ឋារកិច្ច និងការធានាសន្តិសុខសុវត្ថិភាពជូនភ្ញៀវ ។ល។

៤. បង្កើនការអប់រំផ្សព្វផ្សាយ ស្តីពីសារៈសំខាន់នៃទេសចរណ៍ និងអេកូទេសចរណ៍ ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការលើកកម្ពស់កិច្ចការពារបរិស្ថានធម្មជាតិ ក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ដើម្បីឲ្យពួកគេចូលរួមគាំទ្រ និងរួមចំណែកក្នុងការអភិវឌ្ឍទេសចរណ៍ និងអេកូទេសចរណ៍ក្នុងខេត្តមណ្ឌលគិរីប្រកបដោយមនសិការស្រលាញ់ និងការទទួលខុសត្រូវខ្ពស់ចំពោះធនធានធម្មជាតិវប្បធម៌ ក៏ដូចជាចូលរួមទប់ស្កាត់រាល់ផលប៉ះពាល់អវិជ្ជមានដែលអាចកើតមាន

៥. ជំរុញចលនាទេសចរណ៍ម្នាក់ ដើមឈើមួយដើមនៅតាមបណ្តាសហគមន៍ទេសចរណ៍/ អេកូ ទេសចរណ៍ និងរមណីយដ្ឋានអេកូទេសចរណ៍

៦. សហការជំរុញការរក្សាអនាម័យបរិស្ថាននៅតាមទីក្រុង ទីប្រជុំជន និងគោលដៅទេសចរណ៍ទាំងអស់ពិសេសគឺយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងលុបបំបាត់កុំឲ្យមានថង់ប្លាស្ទិកហើរតាមខ្យល់

៧. សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា វិស័យឯកជន និងដៃគូអភិវឌ្ឍជំរុញរាល់គម្រោងវិនិយោគ (ខ្នាតធំ) និងសហគមន៍ទេសចរណ៍/អេកូទេសចរណ៍ (ខ្នាតតូច) នៅគ្រប់តំបន់ សក្តានុពលក្នុងខេត្តឲ្យ

មានដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់។

៨. ជំរុញការផលិតក្នុងសហគមន៍ដើម្បីផ្គត់ផ្គង់ដល់ទេសចរ ដូចជា ការដាំបន្លែ ផ្លែឈើគ្មានជាតិគីមី ការចិញ្ចឹមសត្វ និងសិប្បកម្មតាមសហគមន៍ ។

៩. រៀបចំពិធីបុណ្យអេកូទេសចរណ៍

**ឃ. ការងារទីក្រុងស្អាត**

ការចូលរួមចលនាប្រឡងប្រណាំងទីក្រុងស្អាតក្នុងគោលបំណងលើកកម្ពស់សោភ័ណភាព អនាម័យ បរិស្ថានល្អ នៅក្រុងសែនមនោរម្យ ឲ្យក្លាយជាគោលដៅទេសចរណ៍ដែលទាក់ទាញ និងប្រកបដោយភាពកក់ក្តៅ។ ចំនុចធំៗជាយុទ្ធសាស្ត្រចំនួន ៤ ត្រូវបានដាក់ចេញរួមមាន ៖

**១. ការគ្រប់គ្រងសំណល់រឹង**

- ជម្រុញអោយមានប្រព័ន្ធឬភ្នាក់ងារអចិន្ត្រៃយ៍ប្រមូលសំណងរឹង លុបបំបាត់បរិស្ថានមិនល្អ (កាកសំណល់នៅតាមដងផ្លូវសាធារណៈ ទីផ្សារ រមណីយដ្ឋានទេសចរណ៍។ល។ ដោយបំពាក់ធុងសំរាម មានដេប៉ូសំរាម និងមានមធ្យោបាយដឹកជញ្ជូនឲ្យបានគ្រប់គ្រាន់ និងរៀបចំទីលានចាក់សំរាម (ដែលគោរពតាមស្តង់ដា) ការបញ្ជ្រាបការយល់ដឹងដល់សាធារណៈជន រួមនឹងយន្តការផាកពិន័យ។

**២. ការគ្រប់គ្រងកាកសំណល់រាវ**

- ជម្រុញការធ្វើប្រព្រឹត្តកម្មកាកសំណល់រាវនៅគ្រប់ទីក្រុងស្របជាមួយ និងយន្តការបង្កើតឲ្យមានបង្គន់អនាម័យសាធារណៈតាមស្តង់ដាអាស៊ាន (ASEAN Public Toilet Standard)។

**៣. ការពង្រឹងគុណភាពសេវាកម្មទេសចរណ៍ និងការផ្តល់សេវាសាធារណៈ**

- ពង្រឹង និងបង្កើតមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ និងបញ្ហាសុខភាព និងសង្គ្រោះបឋម ពង្រឹងសុវត្ថិភាពទេសចរណ៍ ការរក្សាសុវត្ថិភាពចំណីអាហារតាមភោជនីយដ្ឋាន អាហារដ្ឋាន និងសុវត្ថិភាពចំណីអាហារតាមដងផ្លូវ (Food Street)។
- ការបង្កើតសួនកុមារ សួនច្បារសាធារណៈ តំបន់បៃតង និងជម្រុញឲ្យមាន " សួនទេសចរណ៍ " " សួនអាពាហ៍ពិពាហ៍ " យ៉ាងហោចណាស់០១កន្លែងនៅក្នុងក្រុង និងការដាំដើមឈើនៅតាមដងវិថីនានាក្នុងក្រុងឆ្លើយតបនឹងយុទ្ធនាការ " ទេសចរម្នាក់ ដើមឈើមួយដើម "។

**៤. ការបង្កើតសង្កាត់គំរូ**

- បង្កើត ឬរៀបចំសង្កាត់គំរូក្នុងក្រុង-សង្កាត់បេក្ខភាព ដើម្បីជាគំរូឆ្នើមក្នុងការអនុវត្តនយោបាយ " ភូមិឃុំ-សង្កាត់ មានសុវត្ថិភាព" ផង និងជាសង្កាត់ស្អាតដែលរក្សាបាននូវភាពស្អាត និងបៃតងផង (សង្កាត់ស្អាត និងបៃតង)។

### ៥.២.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍

ការសិក្សាទីផ្សារទេសចរណ៍ គឺដើម្បីស្វែងយល់អំពីប្រភេទនៃទីផ្សារ និងឈានទៅការដាក់ចេញនូវផែនការ

ឬវិធានការអនុវត្ត ដើម្បីស្រូបទាញទីផ្សារពោល គឺភ្ញៀវទេសចរ។ វាទាមទារការសិក្សាវិភាគច្បាស់លាស់ ដោយឈរលើប្រភពព័ត៌មានគាំទ្រផ្សេងៗជាច្រើន។ កន្លងមកខេត្តមណ្ឌលគិរីមិនទាន់មានការសិក្សាអំពីទីផ្សារនៃអ្នកទេសចរជាតិ និងអន្តរជាតិដែលបានមកទស្សនានៅឡើយទេ។ ដើម្បីឈានទៅសម្រេចទិសដៅនេះ យុទ្ធសាស្ត្រដែលលើកឡើងមាន ៖

១. ធ្វើអង្កេតបែបល្អិតល្អន់មួយទៅលើភ្ញៀវដែលបានមកទស្សនា។ នេះគឺជាការសិក្សាទីផ្សារ ដែលចាំបាច់ត្រូវតែធ្វើឡើង ព្រោះព័ត៌មានពីការអង្កេតអាចប្រាប់ដល់អ្នកធ្វើផែនការ អ្នកគ្រប់គ្រង និងប្រតិបត្តិករទេសចរណ៍អំពីភ្ញៀវដែលមានសក្តានុពល ដែលខេត្តត្រូវស្រូបយកហើយតើប្រភេទផលិតផលទេសចរណ៍អ្វីដែលខេត្តគួរផលិតថ្មី និងកែលម្អ ដើម្បីទាក់ទាញក្រុមភ្ញៀវនោះ ។ ជាងនេះទៅទៀតខេត្តក៏អាចធ្វើការសម្រេចចិត្តថា តើក្រុមភ្ញៀវប្រភេទណាដែលគេចង់ទទួលយក និងផ្សព្វផ្សាយទាក់ទាញ ហើយក្រុមភ្ញៀវណាដែលមិនគួរទាក់ទាញ។

២. បន្ទាប់ពីការសិក្សាទីផ្សារ គឺការផ្សព្វផ្សាយដើម្បីទាក់ទាញទីផ្សារគោលដៅដែលខេត្តចង់បាន ។ កន្លងមកការផ្សព្វផ្សាយទាក់ទាញទេសចរជាតិ និងអន្តរជាតិឲ្យមកទស្សនានៅខេត្តមណ្ឌលគិរីធ្វើឡើងតាមរយៈគេហទំព័ររបស់មន្ទីរទេសចរណ៍ តាមប័ណ្ណផ្ទត់ តាមការផ្សព្វផ្សាយតគ្នាពីមាត់មួយទៅមាត់មួយ ការតាំងពិព័រណ៍ ការផលិតវីដេអូខ្លីៗ និងតាមរយៈចម្រៀងទេសចរណ៍ ស្តីពីខេត្តមណ្ឌលគិរី ដែលត្រូវបានផលិត និងចាក់ផ្សាយតាមទូរទស្សន៍ក្នុងស្រុក ដែលទាំងអស់នេះបានទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិឲ្យមកទស្សនាខេត្តមណ្ឌលគិរី ជាហូរហែពេញមួយឆ្នាំ ជាពិសេសនៅពេលបុណ្យប្រពៃណីជាតិ និងថ្ងៃឈប់សម្រាកការងារ ។ ផែនការផ្សព្វផ្សាយទាក់ទាញភ្ញៀវដែលខេត្តត្រូវធ្វើបន្ត គឺបន្តធ្វើបច្ចុប្បន្នភាព និងចងក្រងទិន្នន័យសក្តានុពលទេសចរណ៍ក្នុងខេត្ត ដើម្បីបញ្ចូលទៅក្នុងឧបករណ៍ផ្សព្វផ្សាយ មានគេហទំព័រ ផែនទីទេសចរណ៍ និងប័ណ្ណផ្ទត់ ។ ការរៀបចំព្រឹត្តិការណ៍កីឡា បុណ្យទាន និងបុណ្យសាសនាដែលខេត្តអាចរៀបចំឡើង ដោយផ្អែកលើសក្តានុពលទាក់ទាញរបស់ខ្លួន ដូចជា បុណ្យអកទេសចរណ៍ បុណ្យភ្នំ បុណ្យសែនស្រូវ ។ល។ ដែលជាឱកាសអាចបន្ថែមការទាក់ទាញ ចំណាប់អារម្មណ៍របស់ទេសចរមកលើខេត្ត និងអាចស្រូបទាញចំនួនភ្ញៀវបន្ថែមផងដែរ។ យុទ្ធសាស្ត្រនេះ ក៏អាចជួយដោះស្រាយបានផងដែរ នូវបញ្ហាការប្រមូលផ្តុំភ្ញៀវច្រើនហួសពីសមត្ថភាពនៃការផ្គត់ផ្គង់សេវាកម្មរបស់ខេត្ត នៅពេលបុណ្យជាតិធំៗ ។ ចរចារជាមួយនឹងខេត្តដាក់ណុង ដាក់ឡាក់ និងប៊ិញភឿក ( វៀតណាម )ដើម្បីទាក់ទាញ និងដោះដូរភ្ញៀវទេសចររវាងខេត្តទាំងបួន។ ដំណើរការចរចារនេះនឹងត្រូវបានជំរុញល្បឿនបន្ថែមទៀត ដោយសារវាមានភាពស្របគ្នា និងទិសដៅអភិវឌ្ឍន៍របស់តំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា ឡាវ វៀតណាម។

### ៥.២.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍

តំបន់គោលដៅក្នុងខេត្តមណ្ឌលគិរីអាចតភ្ជាប់ទៅកាន់ខេត្តនានា នៅតាមបណ្តាភូមិភាគឦសាន និងសម្រួលការធ្វើដំណើររបស់ទេសចរបានយ៉ាងល្អ លើសពីនេះទៅទៀតនោះភ្ញៀវទេសចរ ដែលមកទស្សនាខេត្តមណ្ឌលគិរី និងក៏អាចភ្ជាប់ដំណើរកំសាន្តរបស់ពួកគាត់ទៅកាន់ខេត្តក្រចេះ និងរតនគិរី រួចក៏អាចបន្តដំណើរចាកចេញតាមព្រះវិហារ និងយកការហោះហើរពីខេត្តសៀមរាប ទៅកាន់តំបន់គោលដៅនិងប្រទេសផ្សេងៗទៀតក្នុង

តំបន់ជុំវិញបានផងដែរ។ ដើម្បីឲ្យយុទ្ធសាស្ត្រខាងលើអាចអនុវត្តបានប្រកបដោយភាពជោគជ័យខ្ពស់សកម្មភាពចាំបាច់មួយចំនួនត្រូវបានកំណត់ដូចខាងក្រោមៈ

ការរៀបចំព័ត៌មានទេសចរណ៍ខេត្តតាមប្រព័ន្ធបច្ចេកវិទ្យា អាចជាវិធីសាស្ត្រមួយយ៉ាងល្អប្រសើរចំពោះការបង្កភាពងាយស្រួលទៅដល់ភ្ញៀវទេសចរលើការស្វែងយល់បន្ថែមពីតំបន់គោលដៅទេសចរណ៍នៅក្នុងខេត្តមណ្ឌលគិរីដែលពួកគាត់ចង់ទៅទស្សនា ហើយកម្មវិធីនេះទៀតសោតក៏ត្រូវផ្តល់លទ្ធភាពទៅដល់ទេសចរចំពោះការកក់ទុកមុននូវសេវាកម្មផ្សេងៗ ដែលមាននៅតាមតំបន់ទេសចរណ៍ដូចជាការកក់សំបុត្រចូលទស្សនា ម្ហូបអាហារ និងការស្នាក់នៅជាដើម។

ត្រូវមានកិច្ចសហការណ៍ពីតាមបណ្តាមន្ទីរទេសចរណ៍ខេត្ត នៅតំបន់ជុំវិញ និងជាមួយក្រុមហ៊ុនទេសចរណ៍ផ្សេងៗទៀតជាចាំបាច់ក្នុងការសិក្សារៀបចំខ្សែរទស្សនៈកិច្ច ហើយត្រូវកំណត់ឲ្យបានច្បាស់លាស់ ពីសេវាកម្មធនធាន ពេលវេលា និងតម្លៃនៃកញ្ចប់នីមួយៗ។ ផ្សព្វផ្សាយពីកញ្ចប់ខ្សែទស្សនៈកិច្ចនេះឲ្យបានទូលំទូលាយទៅតាមបណ្តាក្រុមហ៊ុន និងភ្នាក់ងារទេសចរណ៍ជាតិ និងអន្តរជាតិ។ ហើយការកែសម្រួលនិងធ្វើបច្ចុប្បន្នភាពព័ត៌មានជាប្រចាំទៅតាមការប្រែប្រួលនៃស្ថានភាពទីផ្សារ តម្លៃ និងសេដ្ឋកិច្ចជាតិ និងអន្តរជាតិ។

ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់មានលក្ខណៈល្អប្រសើរ ដោយអាចតភ្ជាប់ផ្លូវទៅកាន់ខេត្តដទៃទៀតនៅតំបន់ភូមិភាគឦសាន្ត និងមានព្រំដែនគោកជាប់ជាមួយប្រទេសវៀតណាម ដូចនេះការកែលម្អស្លាកសញ្ញាមណ្ឌលព័ត៌មាននិងអាគារសម្រាក់រយៈពេលខ្លីសម្រាប់អ្នកទេសចរ ក៏ត្រូវសហការរៀបចំជាមួយភាគី វៀតណាមឲ្យបានល្អប្រសើរជាងមុនដែរ។ មធ្យោបាយធ្វើដំណើរ គឺជាកត្តាមួយយ៉ាងសំខាន់ ក្នុងការទាក់ទាញនិងបំពេញសេចក្តីត្រូវការរបស់ភ្ញៀវទេសចរបានមួយកម្រិតធំផងដែរ។ ចំពោះមធ្យោបាយធ្វើដំណើរវិញ គឺផ្តោតសំខាន់ទាំងផ្លូវគោក ផ្លូវអាកាសនិងផ្លូវទឹក។ សម្រាប់ស្ថានភាពជាក់ស្តែងចំពោះការធ្វើដំណើររបស់ទេសចរក្នុងខេត្តមណ្ឌលគិរី គឺទាមទារឲ្យមានការកែសម្រួល និងកែលម្អចំនុចមួយចំនួនដែរ គឺក្នុងនោះរួមមានការរៀបចំឲ្យមានទីចំណតរថយន្តទេសចរក្នុងខេត្តមណ្ឌលគិរី ទាំងរថយន្តក្រុង និងរថយន្តទេសចរតូចៗដើម្បីរក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

### ៥.២.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជាមាន

ជាភ័ព្វសំណាងខេត្តមណ្ឌលគិរី ជាខេត្តមួយដែលមានសន្តិសុខ និងសុវត្ថិភាពល្អ ដោយចំនួនប្រជាជននៅតិចនិងដោយសារភាពស្លូតបូតរបស់ប្រជាជនម្ចាស់ស្រុក ដែលជាជនជាតិដើមភាគតិច មានដល់ទៅប្រមាណ ៥៧ភាគរយ នៃចំនួនប្រជាជនទាំងអស់ ។តែកន្លងមកដោយសារការកើនឡើងនូវមនុស្សចំណូលថ្មី និងដោយសារការធ្វេសប្រហែសរបស់ភ្ញៀវខ្លួនឯង ក៏ធ្លាប់មានករណីនៃការបាត់បង់ឥវ៉ាន់របស់ភ្ញៀវដែលមកកម្សាន្ត ការភូតកុហកពីវត្ថុអនុស្សាវរីយ៍ ដែលនាំចូលថា ជារបស់ប្រចាំតំបន់ដូចជា ការក្លែងទឹកឃ្មុំសុទ្ធ ។ល។ បច្ចុប្បន្ននេះ មន្ទីរបានសហការជាមួយអាជ្ញាធរមូលដ្ឋាន នគរបាល កងរាជអាវុធហត្ថនៅមូលដ្ឋានផ្ទាល់ ដើម្បីរៀបចំការពារសន្តិសុខជូនភ្ញៀវទេសចរជាតិ អន្តរជាតិទាំងពេលមានបុណ្យទាន និងគ្មាន បុណ្យទាន។ ប៉ុន្តែស្របពេលជាមួយគ្នានេះនៅពេលកើតមានគ្រោះថ្នាក់ណាមួយនៅតំបន់ជនបទដាច់ ស្រយ៉ាល ប្រព័ន្ធសុវត្ថិភាព និងការជួយសង្គ្រោះរបស់ខេត្តនៅមានកម្រិតនៅឡើយ ព្រោះមិនមានសម្ភារៈ និងមធ្យោបាយគ្រប់គ្រាន់ដើម្បីជួយសង្គ្រោះឲ្យទាន់ពេលវេលា។ ចំពោះសុវត្ថិភាពផ្នែកចំណីអាហារក៏នៅមានកម្រិតផងដែរ ជាពិសេសទាក់ទងនឹងអនាម័យក្នុងការរៀបចំ និងទីកន្លែងទទួលភ្ញៀវនៅតាមភោជនីយដ្ឋានមួយចំនួនធំ។

ផលប៉ះពាល់អវិជ្ជមានពីវិស័យទេសចរណ៍ ដែលខេត្តជួបប្រទះកន្លងមកមានការផ្លះផ្លាយសេដ្ឋកិច្ច ដែលភាគច្រើនបណ្តាលមកពីការនាំចូល ដើម្បីផ្គត់ផ្គង់សកម្មភាពទេសចរណ៍ ការចម្លងវប្បធម៌បរទេស និងទេសចរក្នុងស្រុក ដែលធ្វើឲ្យចុះអន់ខ្សោយដល់ប្រពៃណីវប្បធម៌របស់បងប្អូនជនជាតិដើមភាគតិច។ ការបំពុលបរិស្ថានមានជាអាទិ៍ គ្មានកន្លែងទុកដាក់សំរាមសមស្រប គ្មានប្រព័ន្ធលូបង្ហូរទឹកក្នុងក្រុង សេវាប្រមូលសំរាមមានកម្រិត ។ការបំពុលបរិស្ថាននៅជាបញ្ហាប្រឈមដ៏ធំរបស់ខេត្ត ហើយបញ្ហានេះមិនត្រឹមបណ្តាលមកពីសកម្មភាពទេសចរណ៍ប៉ុណ្ណោះទេ តែក៏បណ្តាលមកពីកង្វះខាតការរៀបចំហេដ្ឋារចនាសម្ព័ន្ធទុកដាក់កាកសំណល់ក្នុងខេត្ត ។

ឆ្លើយតបនឹងស្ថានភាពនេះ ផែនការដូចខាងក្រោមត្រូវបានដាក់ចេញ ៖

១. ពង្រឹង និងពង្រីកយន្តការគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពនៅតាមគោលដៅទេសចរណ៍នីមួយៗ រួមមាន ពង្រឹងតួនាទីរបស់នគរបាលទេសចរណ៍ បំផុសចលនាការពាររបស់សហគមន៍ ដោយការចូលរួមរបស់ប្រជាជនតាមស្មារតីប្រជាជនម្នាក់ជាអ្នកការពារម្នាក់នៅតាមរមណីយដ្ឋាន និង ទីកន្លែងទេសចរណ៍ ។ ខេត្ត និងស្នងការនគរបាលខេត្តបានរៀបចំឲ្យមានក្រុមបណ្តាញយុវជនស្ម័គ្រចិត្តផ្តល់ព័ត៌មានទេសចរណ៍ ចំនួន ១៨នាក់ ដែលមានសមាសភាពមកពីមគ្គុទេសក៍ទេសចរណ៍ ម៉ូដូរ និងសណ្ឋាគារ ។ ទោះជាយ៉ាងណាក៏ដោយក្រុមនេះត្រូវការនូវសម្ភារៈ ជំនាញបច្ចេកទេសមូលដ្ឋាន និងការគាំទ្របន្ថែមទៀត ដើម្បីឲ្យពួកគេមានលទ្ធភាពបំពេញភារកិច្ចបានល្អ

២. រៀបចំឲ្យមានកន្លែងសង្គ្រោះបឋមមធ្យោបាយដឹកជញ្ជូន និងការទំនាក់ទំនងតាមតំបន់គោលដៅទេសចរណ៍នានា ដើម្បីជួយសង្គ្រោះភ្ញៀវពេលមានគ្រោះថ្នាក់

៣. ផ្តល់ការអប់រំបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធ ពិសេសមគ្គុទេសក៍ទេសចរណ៍អំពីវិធីសង្គ្រោះបឋម ព័ត៌មានរហ័ស និងការត្រៀមបង្ការទប់ស្កាត់បញ្ហាផ្សេងៗដែលអាចកើតឡើងចំពោះភ្ញៀវ

៤. សហការជាមួយមន្ទីរជំនាញ ដើម្បីចុះអប់រំប្រតិបត្តិករទេសចរណ៍ដល់មូលដ្ឋានស្តីពីអនាម័យ ចំណីអាហារ និងការថែរក្សាបរិស្ថាននៅតាមភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ រមណីយដ្ឋាន និងកន្លែងកម្សាន្តនានា

៥. អប់រំ និងផ្សព្វផ្សាយពីការគ្រប់គ្រងកាកសំណល់ការចូលរួមថែរក្សាបរិស្ថាន ការអភិរក្សសត្វព្រៃ និងធនធានធម្មជាតិនៅតាមរមណីយដ្ឋានដល់សហគមន៍ទេសចរណ៍ និងដាក់ស្លាកអប់រំបរិស្ថានសម្រាប់ទេសចរដែលទៅកម្សាន្ត ។ លើកទឹកចិត្តដល់ភ្ញៀវទេសចរកុំឲ្យទិញ និងបរិភោគសត្វព្រៃ ព្រមទាំងទំនិញដែលនាំទៅដល់ភាពហិនហោចនៃធនធានធម្មជាតិ

៦. ផ្តល់យោបល់ និងរៀបចំឲ្យមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងកាកសំណល់នៅតាមរមណីយដ្ឋានស្របតាមការកំណត់ក្នុងស្តង់ដារមណីយដ្ឋាន

៧. ជំរុញការអភិវឌ្ឍទេសចរណ៍បៃតង យុទ្ធនាការទេសចរម្នាក់ ដើមឈើមួយដើម ស្របតាម ស្តង់ដាសួនទេសចរណ៍ និងទីក្រុងស្អាតជាទីក្រុងដែលគ្មានថង់ប្លាស្ទិកហើរតាមខ្យល់ ស្នើសុំអាជ្ញាធរខេត្តនូវទីតាំងមួយចំនួនដើម្បីរៀបចំជាសួនសម្រាប់ដាំ និងបណ្តុះកូនឈើបម្រើឲ្យភ្ញៀវទេសចរ បន្តសហការជាមួយ

សាលាក្រុងសែនមនោរម្យ និងអាជ្ញាធរឃុំ សង្កាត់ ដើម្បីអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីអនាម័យ ការទុកដាក់សំរាម និងការថែរក្សាបរិស្ថាននៅតាមគេហដ្ឋាន និងទីធ្លាសាធារណៈ

៨. ជំរុញលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យទេសចរណ៍ដូចជា សហគមន៍ដាំបន្លែ ចិញ្ចឹមសត្វ សិប្បកម្ម ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងខេត្ត ដូចជា ម្ហូបអាហារ និងសម្ភារៈដែលជាតម្រូវការរបស់ភ្ញៀវផង ប្រជាពលរដ្ឋផង និងអាចនាំចេញទៅលក់ខាងក្រៅខេត្តផង ។

៩. ផ្សព្វផ្សាយ ទប់ស្កាត់ការចម្លងវប្បធម៌បរទេស និងលើកតម្កើងការថែរក្សាវប្បធម៌ជនជាតិដើមភាគតិចតាមរយៈការអប់រំផ្សព្វផ្សាយជាស្លាកសញ្ញា រូបភាព អត្ថបទ និងតាមរយៈមគ្គុទ្ទេសក៍ទេសចរណ៍ទៅដល់ភ្ញៀវ និងប្រជាសហគមន៍

១០.ផ្សព្វផ្សាយសេចក្តីជូនដំណឹង សេចក្តីណែនាំដែលបានដាក់ចេញដោយក្រសួងទេសចរណ៍ដល់ម្ចាស់អាជីវកម្មសេវាកម្មទេសចរណ៍ ប្រតិបត្តករទេសចរណ៍ និងភ្ញៀវទេសចរក្នុងគោលបំណងចូលរួមចំណែកដល់ការការពារជំងឺឆ្លង និងសុវត្ថិភាពរបស់ពួកគាត់។

### ៥.២.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង

### ក. ការពង្រឹងច្បាប់ស្តីពីទេសចរណ៍ និងបទដ្ឋានគតិយុត្តទេសចរណ៍

ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រងអនុវត្ត គឺជាទិសដៅយុទ្ធសាស្ត្រដ៏សំខាន់សម្រាប់ធានានិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍ ។ កម្ពុជាមានច្បាប់ និងបទដ្ឋានគតិយុត្តជាច្រើនក្នុងនោះច្បាប់ស្តីពីទេសចរណ៍ ក៏បាននិងកំពុងមានអានុភាពគតិយុត្តក្នុងការអនុវត្តដែលប្រព័ន្ធច្បាប់ទាំងនេះបានជួយពង្រឹងការគ្រប់គ្រងទេសចរណ៍ឈានទៅសម្រេចចក្ខុវិស័យនានាក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ។

ស្របគ្នា នឹងទំហំនៃការរីកចំរើនជាលំដាប់នៃវិស័យទេសចរណ៍ក្នុងខេត្ត ការពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តនានាទាក់ទងនឹងវិស័យទេសចរណ៍ ដែលដាក់ចេញដោយក្រសួងទេសចរណ៍ និងរាជ រដ្ឋាភិបាលកម្ពុជា ពិសេសច្បាប់ស្តីពីទេសចរណ៍ គឺជាកិច្ចការចាំបាច់ចំពោះមុខ ដែលគ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវតែចូលរួមសម្រេចទិសដៅនេះឲ្យបាន ដើម្បីធានាការពារផលប្រយោជន៍ដល់ភាគីពាក់ព័ន្ធទាំងអស់ផង និងធានាការអភិវឌ្ឍទេសចរណ៍ប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវផងមុនពេលដែល ស្ថានភាពនៃការរីកចម្រើនឈានដល់កម្រិតដែលពិបាកគ្រប់គ្រង ។ ផែនការសម្រាប់ខេត្តមណ្ឌលគិរីគឺ ៖

១. បង្កើនការផ្សព្វផ្សាយ ណែនាំអនុវត្តច្បាបស្តីពីទេសចរណ៍ បទបញ្ញត្តិស្តីពីការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ដល់ប្រតិបត្តិករទេសចរណ៍រួមទាំងសហគមន៍ទេសចរណ៍

២. សហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គភាពពាក់ព័ន្ធចុះតាមដានត្រួតពិនិត្យ នៅតាមបណ្តាអាជីវកម្មទេសចរណ៍ ដើម្បីពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តនានា ក៏ដូចជាចាត់វិធានការទប់ស្កាត់សកម្មភាពអាជីវកម្មទេសចរណ៍ខុសច្បាប់ និងគ្មានអាជ្ញាប័ណ្ណ

៣. ប្រមូល និងចងក្រងទិន្នន័យស្តីពីបណ្តាឧស្សាហកម្មទេសចរណ៍ដែលមានក្នុងខេត្ត ដើម្បីក្តាប់ឱ្យបានពីទំហំ និងសកម្មភាពអាជីវកម្មទាក់ទងនឹងទេសចរណ៍ទាំងនោះ

៤. រៀបចំបណ្តាញអ្នកតាមដានត្រួតពិនិត្យ និងរាយការណ៍ពីការអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងបទដ្ឋានគតិយុត្តនានា ដោយប្រមូលផ្តុំសមាសភាពមកពីផ្នែកឯកជន ផ្នែករដ្ឋ អង្គការសង្គមស៊ីវិល និងសហគមន៍ ។

**ខ. ការពង្រឹងអភិបាលកិច្ចល្អក្នុងវិស័យទេសចរណ៍**

អភិបាលកិច្ចល្អក្នុងវិស័យទេសចរណ៍ សំដៅលើការពង្រឹងតួនាទី និងភារកិច្ចរបស់ស្ថាប័នរដ្ឋ ពោលគឺមន្ទីរទេសចរណ៍ខេត្ត ក្នុងការងារដឹកនាំគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ដោយមានទំនាក់ទំនង និងកិច្ចសហការជាមួយនឹងប្រជាជន ទេសចរ ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍ឆ្លើយតបបានទាំងតួនាទីភារកិច្ចនៅថ្នាក់មូលដ្ឋានក្នុងកំរិតខេត្ត និងនៅថ្នាក់ជាតិ ដែលដាក់ចេញដោយក្រសួងទេសចរណ៍។ ក្នុងន័យនេះ យុទ្ធសាស្រ្តដែលលើកឡើងមានដូចតទៅ៖

១. រៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្មខេត្ត ០៥ឆ្នាំ និងផែនការ ០៣ឆ្នាំរំកិលជាបន្តបន្ទាប់ស្របតាមផែនការយុទ្ធសាស្រ្តជាតិអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ទេសចរណ៍តំបន់ឦសាន្ត ដើម្បីជាត្រីវិស័យក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍ខេត្តប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ

២. ពង្រឹងរចនាសម្ព័ន្ធការងាររបស់មន្ទីរទេសចរណ៍ខេត្ត ឆ្លើយតបទៅនឹងការរីកចម្រើននៃវិស័យទេសចរណ៍ក្នុងខេត្ត ការបែងចែកតួនាទី និងភារកិច្ចរបស់មន្ត្រីមន្ទីរទេសចរណ៍ទៅតាមជំនាញ និងបទពិសោធន៍

៣. បន្តបណ្តុះបណ្តាលសមត្ថភាពមន្ត្រី ដើម្បីឆ្លើយតបនឹងភារកិច្ចថ្មីៗ ដែលជាតម្រូវការជាក់ស្តែងក្នុងខេត្ត និងដាក់ចេញដោយក្រសួងទេសចរណ៍ បញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំដោយក្រសួងទេសចរណ៍ និងស្ថាប័នអប់រំទេសចរណ៍នានាទាំងក្នុង និងក្រៅប្រទេស

៤. លើកកម្ពស់ប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវរបស់មន្ត្រី ការគោរពវិន័យការងារ សាមគ្គីភាព ការខិតខំបំពេញភារកិច្ចដែលប្រគល់ជូនបានទាន់ពេលវេលា និងប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការដើម្បីរក្សាភាពថ្លៃថ្នូរក្នុងពេលបំពេញភារកិច្ច

៥. បង្កើតទំនាក់ទំនងល្អរវាងមន្ទីរទេសចរណ៍ អាជ្ញាធរ ស្ថាប័ន ជំនាញពាក់ព័ន្ធ ប្រតិបត្តិករទេសចរណ៍ និងដៃគូអភិវឌ្ឍន៍ជុំវិញខេត្ត ដើម្បីកៀរគរការចូលរួមរបស់ពួកគេក្នុងដំណើរការអភិវឌ្ឍទេសចរណ៍

៦. មន្ទីរទេសចរណ៍ដើរតួជាអ្នកសម្របសម្រួលរវាងភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍ និងបង្ក បរិយាកាសងាយស្រួល និងអំណោយផលដល់រាល់គម្រោងវិនិយោគ និងអភិវឌ្ឍន៍ទេសចរណ៍ក្នុងខេត្ត

៧. បង្កើតប្រអប់គណនេយ្យភាព ដើម្បីទទួលយករាល់គំនិតរិះគន់ស្ថាបនារបស់ភាគីពាក់ព័ន្ធ និងមហាជនក្នុងខេត្ត ដើម្បីបន្តកែប្រែ និងពង្រឹងប្រសិទ្ធភាពការងាររបស់មន្ទីរ។

**៥.២.៦ ការអភិវឌ្ឍធនធានមនុស្ស និងសមាសភាពយេនឌ័រក្នុងវិស័យទេសចរណ៍**

ធនធានមនុស្សជាអាទិភាពយ៉ាងសំខាន់ក្នុងការអភិវឌ្ឍទេសចរណ៍ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។

ការរីកចម្រើននៃវិស័យទេសចរណ៍ គឺកាន់តែមានទំហំធំឡើងជាលំដាប់ដែលទាមទារការពង្រីកទាំងបរិមាណ និងគុណភាពនៃធនធានមនុស្សគ្រប់កម្រិតដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍ។ ដោយឡែកខេត្ត មណ្ឌលគិរី គឺជាខេត្តមួយដែលមានធនធានមនុស្សតិចស្ទើរគ្រប់វិស័យរួមទាំងទេសចរណ៍ផងដែរ ។ ដើម្បីឲ្យផែនការអភិវឌ្ឍន៍ទេសចរណ៍ត្រូវបានអនុវត្តទៅប្រកបដោយប្រសិទ្ធភាព ផែនការអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងវិស័យទេសចរណ៍សម្រាប់ខេត្តនេះត្រូវផ្តោតលើៈ

១. បន្តការបណ្តុះបណ្តាលជំនាញ ក្នុងការផ្តល់សេវាទេសចរណ៍ទៅដល់ប្រតិបត្តិករទេសចរណ៍ រួមមានជំនាញវគ្គបដិសណ្ឋារកិច្ច ផ្នែកសេវាកម្មភ្ញៀវទេសចរ មគ្គុទ្ទេសក៏ទេសចរណ៍សហគមន៍ និងការគ្រប់គ្រងសហគមន៍ទេសចរណ៍ គេហកិច្ច ការិយាល័យជួរមុខ សេវាកម្មម្ហូបអាហារនិងភេសជ្ជៈ បណ្តុះបណ្តាលចុងភៅចំអិនអាហារ ឆុងកាហ្វេ និងបដិសណ្ឋារកិច្ចសុវត្ថិភាពចំណីអាហារក្នុងវិស័យទេសចរណ៍។ល។

២. បន្តសហការកសាងសមត្ថភាពជំនាញគ្រប់គ្រង និងផ្តល់សេវាទេសចរណ៍ទៅដល់សហគមន៍ទេសចរណ៍អេកូទេសចរណ៍ទាំងអស់ក្នុងខេត្តដើម្បីឲ្យពួកគេទទួលបានជំនាញវិជ្ជាជីវៈតាមរយៈវិស័យទេសចរណ៍ និងដើម្បីជំរុញដំណើរការផ្តល់សេវាកម្មទេសចរណ៍ប្រកបដោយគុណភាព និងការពេញចិត្តដល់ភ្ញៀវផង។

៣. ពង្រឹងសមត្ថភាពការងាររបស់មន្ត្រីរាជការបម្រើការនៅមន្ទីរទេសចរណ៍តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាលនានា ដែលរៀបចំឡើងដោយក្រសួងទេសចរណ៍ និងអង្គការនានា។

៤. បណ្តុះបណ្តាលគ្រូបង្គោលសម្រាប់មន្ទីរ និងឯកជន និងបើកវគ្គបណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមអនឡាញ។

៥. ស្នើសុំមន្ត្រីក្របខណ្ឌបន្ថែម ដើម្បីបំពេញភារកិច្ចដែលមិនទាន់មានអ្នកទទួលបន្ទុក។

### ៥.២.៧ ការវិនិយោគក្នុងវិស័យទេសចរណ៍

ការជំរុញ និងលើកទឹកចិត្តឲ្យមានការចូលរួមក្នុងវិស័យទេសចរណ៍ គឺជាការចាំបាច់បំផុតសម្រាប់កិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ក្នុងខេត្ត។ ដោយមើលឃើញថា ទេសចរណ៍ខេត្តមណ្ឌលគិរីនៅមានចំណុចជាច្រើនពុំទាន់មានលក្ខណៈល្អប្រសើរ ដូចជា ផលិតផលទេសចរណ៍នៅមានកម្រិត និងសេវាកម្មទេសចរណ៍ពុំទាន់មានលក្ខណៈស្តង់ដាត្រឹមត្រូវ ដែលពុំទាន់អាចបំពេញតម្រូវការពេញចិត្តរបស់ភ្ញៀវទាំងស្រុងនោះ រាល់បណ្តាយុទ្ធសាស្ត្រទាំងឡាយនៅក្នុងផែនការនេះ គឺជាការចាំបាច់បំផុត ចំពោះការចូលរួមពីគ្រប់វិស័យជាពិសេសវិស័យឯកជនដើម្បីសម្រេចបានដល់គោលដៅខាងលើ។

ដើម្បីឲ្យការអភិវឌ្ឍទេសចរណ៍ខេត្តមណ្ឌលគិរីមានការរីកចម្រើន និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពជាចាំបាច់ដូចតទៅ ៖

- ត្រូវជំរុញស្វែងរកអ្នកវិនិយោគ និងដៃគូរអភិវឌ្ឍទាំងក្នុងស្រុកនិងក្រៅស្រុកជាពិសេសជំរុញ
- លើកទឹកចិត្ត និងផ្តល់អាទិភាពដល់អ្នកវិនិយោគក្នុងស្រុកជាមុនព្រោះថា ចំណូលដែលបានមកនឹងមិនលេចធ្លាយ(រូបិយវត្ថុ)ទៅក្រៅប្រទេស។

- សម្រួល និងលើកទឹកចិត្តដល់ប្រតិបត្តិករក្នុងខេត្តឲ្យធ្វើការវិនិយោគបម្រើឲ្យវិស័យទេសចរណ៍ជាលក្ខណៈទ្រង់ទ្រាយតូចនិងមធ្យម ដោយសម្រួលនិងបង្កលក្ខណៈងាយស្រួលដល់ពួកគេ មុនពេលបោះទុនវិនិយោគ ដូចជា លិខិតស្នាមស្នើសុំធ្វើអាជីវកម្ម និងបែបបទគតិយុត្តផ្សេងៗ
- មន្ទីរទេសចរណ៍ដែលជាមន្ទីរសាមីត្រូវធ្វើការសហការជាមួយខេត្ត និងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំចងក្រងព័ត៌មានផែនការវិនិយោគជាលក្ខណៈទ្រង់ទ្រាយតូច មធ្យម និងធំឲ្យបានលម្អិតនិងច្បាស់លាស់ និងធ្វើការផ្សព្វផ្សាយស្វែងរកដៃគូវិនិយោគដែលចាប់អារម្មណ៍ក្នុងវិស័យ ទេសចរណ៍។
- ជាពិសេសការបង្កើតយន្តការរដ្ឋ ឯកជនក្នុងវិស័យទេសចរណ៍ ក៏ត្រូវរៀបចំជាមួយភាគីពាក់ព័ន្ធផងដែរ។

### ៥.២.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ

ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី គឺពឹងផ្អែកទាំងស្រុងលើធនធាន និងសម្បត្តិវប្បធម៌ដែលមានស្រាប់នៅក្នុងខេត្ត (ជីវៈចម្រុះគ្រប់ប្រភេទ ទំនៀមទំលាប់ប្រពៃណីរបស់បងប្អូនជនជាតិ និងការធ្វើបរកសិកម្ម)។ ដើម្បីចូលរួមចំណែកក្នុងការលើកស្ទួយអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរីឲ្យមានការរីកចម្រើនកាន់តែល្អប្រសើរ និងប្រកបដោយនិរន្តរភាពការចូលរួមក្នុងកិច្ចការពារសម្បត្តិវប្បធម៌ និងធនធានដែលមានស្រាប់នៅក្នុងខេត្តជាការងារចម្បង និងការទទួលខុសត្រូវរបស់យើងគ្រប់គ្នា។ ជាយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ចាំបាច់ត្រូវធ្វើការរួមគ្នាជាមួយស្ថាប័នពាក់ព័ន្ធដូចជា៖ មន្ទីរបរិស្ថាន មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ និងអង្គការនានាក្នុងខេត្តដោយធ្វើការរៀបចំផែនការរួមគ្នាដើម្បីធានាដល់ការងារគ្រប់គ្រង និងអភិរក្សធនធាន និងសម្បត្តិ វប្បធម៌ប្រកបដោយចីរភាព ។

ការលើកកម្ពស់គុណភាព និងរៀបចំបរិស្ថានឲ្យបានប្រសើរជាផ្នែកមួយដ៏សំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរមកកំសាន្តក្នុងខេត្ត និងការផ្តល់នូវផាសុខភាពដល់ភ្ញៀវផងដែរ។ ជំរុញរៀបចំសកម្មភាពទាំងឡាយក្នុងន័យអប់រំ លើកកម្ពស់ចំណេះដឹងស្តីពីបរិស្ថានដោយអនុវត្តឆ្ពោះទៅរកសោភណ្ឌភាពទីក្រុងស្អាត និងភាពបៃតងជានិច្ចតាមតំបន់រមណីយដ្ឋានទេសចរណ៍ ដូចជា ការបង្កើតកម្មវិធីចូលរួមដាំដើមឈើឡើងវិញ និងការបង្កើតសួនអាពាហ៍ពិពាហ៍ដោយរៀបចំឲ្យមានជាលក្ខណៈស្តង់ដាតាមច្បាប់របស់ក្រសួងបានដាក់ចេញ ។

ដើម្បីគាំទ្រដល់យុទ្ធនាការផ្សព្វផ្សាយ **កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ** និងចលនាប្រលងប្រណាំង “ **ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ** ” ស្របតាមប្រព័ន្ធស្តង់ដាទីក្រុងស្អាត គឺចាំបាច់ត្រូវធ្វើការជំរុញដល់ការគ្រប់គ្រងកាកសំណល់តាមដងផ្លូវ ទីប្រជុំជន និងតំបន់ គោលដៅទេសចរណ៍ត្រូវតែមានភាពស្រស់ស្អាត មានសោភណ្ឌភាព ដោយធ្វើការរៀបចំឲ្យមានរបៀបរៀបរយ និងប្រកបដោយការទទួលខុសត្រូវខ្ពស់។ ខេត្តមណ្ឌលគិរីដែលមានរដ្ឋបាលក្រុង មន្ទីរសាធារណៈការ និងដឹកជញ្ជូន មន្ទីរបរិស្ថាន ត្រូវធ្វើការរួមគ្នាសិក្សាឲ្យបានច្បាស់លាស់លើការងារគ្រប់គ្រងកាកសំណល់ និងការរៀបចំផែនការមេក្នុងការបង្កើតឲ្យមានទីលានចាក់សំរាមរបស់ខេត្ត។

## ៥.៣ ផែនការសកម្មភាពអាទិភាព

បណ្ដាទិសដៅយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រត្រូវបានបែងចែកបន្តជាសកម្មភាពការងារជាក់ស្ដែង ដើម្បីឈាន ទៅការអនុវត្ត និងដែលចាំបាច់ទាមទារនូវការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធទាំងផ្នែកសាធារណៈផ្នែកឯកជន ប្រជាពលរដ្ឋ និងដៃគូអភិវឌ្ឍប្រកបដោយការទទួលខុសត្រូវ និងការប្ដេជ្ញាចិត្តរួមសហការគ្នា។

### ៥.៣.១ ការអភិវឌ្ឍផលិតផលទេសចរណ៍ និងពង្រឹងគុណភាពសេវាកម្ម

#### ក. តំបន់អាទិភាព និងសក្ដានុពលសម្រាប់អភិវឌ្ឍន៍ទេសចរណ៍

- ចុះប្រមូល និងចងក្រងទិន្នន័យក្នុងតំបន់សក្ដានុពលនីមួយៗដោយសហការជាមួយអាជ្ញាធរ និង ជំនាញពាក់ព័ន្ធ
- រៀបចំកែសម្រួលផែនទីទេសចរណ៍ខេត្តមណ្ឌលគិរី និងលើកស្លាកផ្ទាំងប៉ាណូផ្សព្វផ្សាយតាមតំបន់ សំខាន់ៗក្នុងខេត្ត
- ខិតខំរកមូលនិធិ ដើម្បីសាងសង់មណ្ឌលព័ត៌មានទេសចរណ៍នៅលើទីតាំងដែលសាលាខេត្ត បាន កំណត់ទុកជូនមន្ទីរទេសចរណ៍
- រៀបចំពង្រឹងផលិតផល និងសេវាកម្មទេសចរណ៍ សហគមន៍អេកូទេសចរណ៍ កសិទេសចរណ៍ និងទេសចរណ៍ជនបទ
- រៀបចំតំបន់ទេសចរណ៍សំខាន់ៗនិងមានសក្ដានុពលដើម្បីទទួលបាននូវស្តង់ដារអប្បមារមណីយដ្ឋាន ដែលក្រសួងបានកំណត់
- រៀបចំចំណតរថយន្តឲ្យមានសណ្ដាប់ធ្នាប់នៅក្នុងក្រុងសែនមនោរម្យ និងតាមតំបន់គោលដៅ ទេសចរណ៍សំខាន់ៗ
- រៀបចំដាក់ធុងសំរាមឲ្យបានគ្រប់គ្រាន់នៅទីសាធារណៈសំខាន់ៗ ក្នុងក្រុង និងតាមតំបន់ ទេសចរណ៍សំខាន់ៗ
- ប្រមូលព័ត៌មាននិងចងក្រងឯកសារពិធីបុណ្យផ្សេងៗនិងប្រវត្តិសំខាន់ៗ ដែលពាក់ព័ន្ធតំបន់ ទេសចរណ៍ក្នុងខេត្តមណ្ឌលគិរី
- សហការជាមួយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ក្នុងការស្រាវជ្រាវពីរបាំប្រពៃណីប្រចាំខេត្ត និងនៅ តាមភូមិឃុំ ស្រុក ក្រុង
- សហការជាមួយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ក្នុងការចងក្រងរឿងព្រេងនិទាននានា ទាក់ទងនឹង ភូមិសាស្ត្រក្នុងខេត្ត
- សហការជាមួយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈ ក្នុងការរៀបចំនិងអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រ នៅក្នុងក្រុង និងស្រុកនានា ដូចជាទីទួលប្រាសាទនានា

- ផ្សព្វផ្សាយដល់ប្រតិបត្តិករទេសចរណ៍ មានដូចជា សណ្ឋាគារ ផ្ទះសំណាក់ អាហារដ្ឋាន ភោជនីយដ្ឋាន និងកន្លែងកម្សាន្តនានាក្នុងការពង្រឹងគុណភាពទាំងសេវានិងអនាម័យ
- បណ្តុះបណ្តាលដល់ទេសចរណ៍សហគមន៍ពីអនាម័យ និងការផ្តល់សេវាកម្មទេសចរណ៍ ប្រកបដោយគុណភាពខ្ពស់។

**ខ. ពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍ " សេវាមួយ ស្តង់ដាមួយ "**

- ចុះពិនិត្យ វាយតម្លៃ និងលើកគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍នានា រួមទាំងបន្តកសាងសមត្ថភាពដល់សមាជិកគណៈកម្មការគ្រប់គ្រងតំបន់រមណីយដ្ឋាននានាក្នុងខេត្ត
- ចុះពិនិត្យ វាយតម្លៃ ណែនាំ និងពង្រឹងសមត្ថភាពដល់ក្រុមសិប្បកម្មទាំង០៥កន្លែង ដោយសហការជាមួយភាគីពាក់ព័ន្ធ
- ជួយស្វែងរកទីផ្សារទេសចរណ៍សម្រាប់ផលិតផលសិប្បកម្ម
- ផ្សព្វផ្សាយក្នុងចំណោមអាជីវករកុំឲ្យមានការភូតកុហកពីវត្ថុអនុស្សាវរីយ៍ដល់ភ្ញៀវដោយប្រាប់ភ្ញៀវពីប្រភពពិតរបស់វា
- បន្តពង្រឹង និងរៀបចំក្រុមអ្នកនាំទេសចរទស្សនាដំរីនៅ ភូមិពូតាំង និងភូមិពូលូង
- បន្តផ្តល់វគ្គបណ្តុះបណ្តាលដល់ប្រតិបត្តិករទេសចរណ៍ លើជំនាញសេវាកម្មដែលនៅមានភាពខ្វះខាត ដូចជា សេវាកម្មម្ហូបអាហារ និងភេសជ្ជៈ បដិសណ្ឋារកិច្ច គេហកិច្ច ការិយាល័យជួរមុខ ផុងកាហ្វេ ចុងភៅ មគ្គុទ្ទេសក៍ទេសចរណ៍ ស្តង់ដាផ្ទះស្នាក់។ល។
- បន្តយុទ្ធនាការ " ភោជនីយដ្ឋានស្អាត " ភោជនីយដ្ឋានគ្មានសំរាមជាក្រដាស
- បន្តចុះវាយតម្លៃចំណាត់ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍
- បន្តអនុវត្តឲ្យមានប្រសិទ្ធភាពនូវបទដ្ឋានគតិយុត្តនានារបស់ក្រសួងទេសចរណ៍ ។

**គ. ការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មី**

- រៀបចំតំបន់រមណីយដ្ឋាន ដែលកំពុងដំណើរការឲ្យមានសេវាកម្មដែលនៅខ្វះខាតស្របតាមស្តង់ដារអប្បរមាសម្រាប់រមណីយដ្ឋានទេសចរណ៍
- ចុះពិនិត្យ និងវាយតម្លៃសេវាកម្មដែលមាននិងកម្រិតគុណភាពសេវាកម្មនៅតាមតំបន់រមណីយដ្ឋានសាធារណៈ និងឯកជន
- ផ្សព្វផ្សាយ និងជំរុញអនុវត្តតាមស្តង់ដារមណីយដ្ឋាន
- ចុះសិក្សា ស្រាវជ្រាវ លទ្ធភាពដើម្បីអភិវឌ្ឍន៍គម្រោងទេសចរណ៍នៅតាមតំបន់ដែនជម្រកសត្វព្រៃទាំង ០៥រួមមាន៖ ដែនជម្រកសត្វព្រៃណាមលៀរ ដែនជម្រកសត្វព្រៃស្រែពក ដែនជម្រកសត្វព្រៃភ្នំព្រេចដែនជម្រកសត្វព្រៃកែវសីមា និងដែនជម្រកសត្វព្រៃលំផាត់ដែលស្ថិតក្នុងទឹកដីនៃ ខេត្តមណ្ឌលគិរី

- រៀបចំព្រឹត្តិការណ៍ទេសចរណ៍នានា ដែលអាចឆ្លុះបញ្ចាំងពីអត្តសញ្ញាណ និងប្រវត្តិខេត្ត
- ចុះសិក្សាស្រាវជ្រាវពីប្រវត្តិបុណ្យនានាក្នុងខេត្ត និងចងក្រងទុកជាឯកសារ
- ចូលរួមសហការជាមួយមន្ទីរបរិស្ថានខេត្តមណ្ឌលគិរីជម្រុញវិនិយោគលើគម្រោងអភិវឌ្ឍទេសចរណ៍ធម្មជាតិ (ទំហំដីមិនលើសពី១០ហិកតា)
- រៀបចំបង្កើតព្រឹត្តិការណ៍បុណ្យទាន និងកីឡាថ្មីៗដែលអាចទាក់ទាញទេសចរ ។

**ឃ. ការជំរុញការអភិវឌ្ឍអេកូទេសចរណ៍ និងទេសចរណ៍សហគមន៍**

- ធ្វើផែនការ និងបែងចែកតំបន់សក្តានុពលសម្រាប់ការអភិវឌ្ឍអេកូទេសចរណ៍
- រៀបចំតំបន់រមណីយដ្ឋានអេកូទេសចរណ៍គំរូ
- ពង្រឹងគុណភាពផលិតផលក្នុងរមណីយដ្ឋានអេកូទេសចរណ៍
- សិក្សាទីផ្សារ និងផ្សព្វផ្សាយអេកូទេសចរណ៍
- បង្កើនលទ្ធភាពធ្វើអាជីវកម្ម និងវិនិយោគអេកូទេសចរណ៍
- ធានាសុវត្ថិភាពនៅតាមរមណីយដ្ឋានអេកូទេសចរណ៍
- បញ្ជ្រាបការយល់ដឹង និងអប់រំពីទេសចរណ៍អេកូទេសចរណ៍ទៅដល់សហគមន៍ និងភ្ញៀវទេសចរ
- សហការពង្រឹង និងពង្រីកការបង្កើតសហគមន៍ទេសចរណ៍ និងសហគមន៍អេកូទេសចរណ៍ ដើម្បីកិច្ចការពារបរិស្ថាន បង្កើនប្រាក់ចំណូល ឱកាសការងារ កាត់បន្ថយភាពក្រីក្រ និងកាត់បន្ថយចំណាកស្រុក
- បណ្តុះបណ្តាលជំនាញអេកូទេសចរណ៍ រួមមាន មគ្គុទេសក៍ទេសចរណ៍សហគមន៍ ការរៀបចំផ្ទះស្នាក់ គេហកិច្ច ម្ហូបអាហារ និងភេសជ្ជៈ ការិយាល័យជួរមុខ ចុងភៅ ការទទួលបដិសណ្ឋារកិច្ច និងការធានាសន្តិសុខសុវត្ថិភាពជូនភ្ញៀវ។ល។
- ជំរុញចលនាទេសចរណ៍ម្នាក់ដើមឈើមួយដើម នៅតាមបណ្តាសហគមន៍ទេសចរណ៍/អេកូទេសចរណ៍និង រមណីយដ្ឋានអេកូទេសចរណ៍
- ជំរុញការរក្សាអនាម័យបរិស្ថាននៅតាមទីក្រុង ទីប្រជុំជន និងគោលដៅទេសចរណ៍ទាំងអស់
- ជំរុញយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក និងលុបបំបាត់កុំឲ្យមានថង់ប្លាស្ទិកហើរតាមខ្យល់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ជំរុញរាល់គម្រោងវិនិយោគ (ខ្នាតធំ) និងសហគមន៍ទេសចរណ៍/អេកូទេសចរណ៍ (ខ្នាតតូច) នៅគ្រប់តំបន់សក្តានុពលក្នុងខេត្តតាមស្តង់ដាសហគមន៍ទេសចរណ៍កម្ពុជា
- រៀបចំពិធីបុណ្យអេកូទេសចរណ៍
- ជំរុញការផលិតក្នុងសហគមន៍ ដើម្បីផ្គត់ផ្គង់ដល់ទេសចរ ដូចជា ការដាំបន្លែ ផ្លែឈើគ្មានជាតិគីមី ការចិញ្ចឹមសត្វ និងសិប្បកម្មតាមសហគមន៍ ។

### ៥.៣.២ ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍

- ធ្វើអង្កេតមួយទៅលើភ្ញៀវដែលមកទស្សនាខេត្តមណ្ឌលគិរី
- ជ្រើសរើសមធ្យោបាយសមស្រប ដើម្បីផ្សព្វផ្សាយសម្រាប់ទាក់ទាញទីផ្សារគោលដៅ
- រៀបចំសិក្សាស្រាវជ្រាវទីផ្សារទេសចរណ៍ខេត្តមណ្ឌលគិរី ដោយសិក្សាលម្អិតពីប្រភេទភ្ញៀវទេសចរ ដែលចូលមកកម្សាន្ត និងតម្រូវការរបស់ភ្ញៀវលើផលិតផលទេសចរណ៍
- ធ្វើបច្ចុប្បន្នភាព និងចងក្រងទិន្នន័យសក្តានុពលទេសចរណ៍ក្នុងខេត្ត ដើម្បីបញ្ចូលទៅក្នុងឧបករណ៍ផ្សព្វផ្សាយមានគេហទំព័រ Page របស់មន្ទីរ ផែនទីទេសចរណ៍ ប័ណ្ណផ្គត់ ថង់យួរ (Eco-bag) សៀវភៅ (Pocket Guide) និងកម្រងបញ្ជីរមណីយដ្ឋានទេសចរណ៍
- ពង្រឹងការគ្រប់គ្រងមណ្ឌលព័ត៌មានទេសចរណ៍ ដើម្បីផ្តល់ព័ត៌មានជូនភ្ញៀវទេសចរជាតិ និអន្តរជាតិ
- រៀបចំបង្កើតសៀវភៅមគ្គុទេសក៍ទេសចរណ៍សម្រាប់ខេត្តមណ្ឌលគិរីទាំងមូល
- ចរចារជាមួយនឹងខេត្តដាក់ណុង ដាក់ឡាក់ ប៊ិញភឿក (វៀតណាម) ដើម្បីទាក់ទាញ និងដោះដូរភ្ញៀវទេសចររវាងខេត្តទាំងបួន។

### ៥.៣.៣ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍

- ជំរុញដោះស្រាយបញ្ហាប្រឈមនានាដើម្បីសម្រួលការធ្វើដំណើរ និងការដឹកជញ្ជូនទេសចរ
- ស្នើសុំអោយមានការអភិវឌ្ឍ និងជួសជុលផ្លូវចូលទៅកាន់រមណីយដ្ឋានមួយចំនួន ដែលមានសក្តានុពល
- សិក្សាស្រាវជ្រាវស្វែងរកដៃគូវិនិយោគរៀបចំទីចំណតសាធារណៈក្នុងក្រុង និងផ្សារខេត្តប្រកបដោយសោភ័ណ្ឌភាព
- ជំរុញអាកាសចរណ៍ស៊ីវិល និងស្ថាប័នពាក់ព័ន្ធ សិក្សាពីលទ្ធភាពក្នុងការស្តារ និងពង្រីកព្រលានយន្តហោះខេត្តឲ្យមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការចុះចតយន្តហោះគ្រប់ប្រភេទ
- សិក្សារៀបចំទីសម្រាកទេសចរ និងបង្គន់សាធារណៈនៅតាមតំបន់រមណីយដ្ឋាន ។

### ៥.៣.៤ សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន

- ជំរុញពង្រឹងតួនាទីរបស់នគរបាលទេសចរណ៍ បំផុសចលនាការពាររបស់សហគមន៍ ដោយការចូលរួមរបស់ប្រជាជនតាមស្មារតីប្រជាជនម្នាក់ជាអ្នកការពារម្នាក់នៅតាមរមណីយដ្ឋាន និងទីកន្លែងទេសចរណ៍នានា
- ពិនិត្យលទ្ធភាព និងរៀបចំឲ្យមានកន្លែងសង្គ្រោះបឋម មធ្យោបាយដឹកជញ្ជូន និងការទំនាក់ទំនងតាមតំបន់គោលដៅទេសចរណ៍នានា ដើម្បីជួយសង្គ្រោះភ្ញៀវពេលមានគ្រោះថ្នាក់
- ផ្តល់ការអប់រំបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធ ពិសេសមគ្គុទេសក៍ទេសចរណ៍អំពីវិធីរបៀប សង្គ្រោះបឋម ព័ត៌មានរហ័ស និងការត្រៀមបង្ការទប់ស្កាត់បញ្ហាផ្សេងៗដែលអាចកើតឡើងចំពោះភ្ញៀវ
- សហការជាមួយមន្ទីរជំនាញ ដើម្បីចុះអប់រំប្រតិបត្តិករទេសចរណ៍ដល់មូលដ្ឋានអាជីវកម្មទេសចរណ៍

ស្តីពីអនាម័យចំណីអាហារ និងការថែរក្សាបរិស្ថាននៅតាមភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ រមណីយដ្ឋាន និងកន្លែងកម្សាន្តនានា

- សិក្សា និងស្នើសុំទៅអាជ្ញាធរខេត្តនូវតំបន់ដែលអាចរៀបចំជាសួនសម្រាប់ដាំ និងបណ្តុះកូនឈើបម្រើឲ្យភ្ញៀវទេសចរ
- បន្តសហការជាមួយរដ្ឋបាលក្រុងសែនមនោរម្យ និងអាជ្ញាធរ ឃុំ សង្កាត់ ដើម្បីអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីអនាម័យ ការទុកដាក់សំរាម និងការថែរក្សាបរិស្ថាននៅតាមគេហដ្ឋាន និងទីធ្លាសាធារណៈ
- អប់រំផ្សព្វផ្សាយជាស្លាកសញ្ញា រូបភាព អត្ថបទ និងតាមរយៈមគ្គុទេសក៍ទេសចរណ៍ទៅដល់ភ្ញៀវនិងប្រជាសហគមន៍ដើម្បីទប់ស្កាត់ការចម្លងវប្បធម៌បរទេស និងលើកតម្កើងការថែរក្សាវប្បធម៌ជនជាតិដើមភាគតិចឲ្យបានជាអតិបរមា
- ចុះសិក្សាលទ្ធភាពរៀបចំសហគមន៍ដាំបន្លែ ចិញ្ចឹមសត្វ និងសិប្បកម្មដើម្បីជំរុញលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យទេសចរណ៍
- បន្តការបញ្ជ្រាបការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀនដល់ប្រតិបត្តករទេសចរណ៍ និង បុគ្គលិកបម្រើការនៅក្នុងអាជីវកម្ម សេវាកម្មទេសចរណ៍ ពិសេសការចុះផ្សព្វផ្សាយអប់រំតាមមណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ និងកន្លែងសប្បាយនានាដែលងាយរងគ្រោះ ដើម្បីចូលរួមទប់ស្កាត់ពីការជួញដូរការប្រើប្រាស់គ្រឿងញៀន នៅក្នុងមូលដ្ឋានអាជីវកម្មទេសចរណ៍
- សហការជាមួយក្រុមការងារក្រសួងទេសចរណ៍ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងការចូលរួមលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍
- សហការជាមួយក្រុមការងារក្រសួងទេសចរណ៍រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការបង្ការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍!ជំងឺអេដស៍ក្នុងវិស័យទេសចរណ៍ ជូនប្រតិបត្តករទេសចរណ៍រួមមាន ម្ចាស់ ឬអ្នកគ្រប់គ្រងបុគ្គលិកមូលដ្ឋានអាជីវកម្មទេសចរណ៍
- សហការជាមួយរដ្ឋបាលខេត្ត ក្រុង ស្រុក មន្ទីរ អង្គភាពពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយវិធានសុវត្ថិ ភាពសុខាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍ ដែលដាក់ចេញដោយក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍ ពិសេសវិធានការ ៣ការពារ គឺពាក់ម៉ាស់ លាងដៃ និងរក្សាគម្លាតសុវត្ថិភាព និងវិធាន ៣កុំ គឺកុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំចូលទៅកន្លែងដែលបិទជិតឈឹង និងកុំប៉ះពាល់គ្នា
- សហការជាមួយក្រុមការងារក្រសួងទេសចរណ៍ក្នុងការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីធានាបានបរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍ ដែលសក្តិសមជាមាសបៃតងក្នុងការចូលរួមកសាងសេដ្ឋកិច្ចបៃតង និងសហគមន៍បៃតង
- សហការជាមួយក្រុមការងារក្រសួងទេសចរណ៍ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់ សិទ្ធិជន

មានពិការភាពការជម្រុញកិច្ចការពារ និងលើកកម្ពស់សុខុមាលភាព ស្របតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនមានពិការភាព។

**៥.៣.៥ ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង**

- ចុះផ្សព្វផ្សាយ ណែនាំអនុវត្តច្បាប់ស្តីពីទេសចរណ៍ បទបញ្ញត្តិស្តីពីការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ ដល់ប្រតិបត្តិករទេសចរណ៍រួមទាំងសហគមន៍ទេសចរណ៍
- សហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គភាពពាក់ព័ន្ធចុះតាមដានត្រួតពិនិត្យនៅតាមបណ្តាលអាជីវសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គភាពពាក់ព័ន្ធចាត់វិធានការទប់ស្កាត់សកម្មភាព អាជីវកម្មទេសចរណ៍ខុសច្បាប់ និងគ្មានអាជ្ញាប័ណ្ណ
- ចុះប្រមូល និងចងក្រងទិន្នន័យ ស្តីពីបណ្តាឧស្សាហកម្មទេសចរណ៍ដែលមានក្នុងខេត្ត ដើម្បីក្តាប់ឲ្យបានពីទំហំ និងសកម្មភាពអាជីវកម្មពាក់ព័ន្ធនឹងទេសចរណ៍
- បង្កើតបណ្តាញអ្នកតាមដានត្រួតពិនិត្យ និងរាយការណ៍ពីការអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងបទដ្ឋានគតិយុត្តនានាដោយប្រមូលផ្តុំសមាសភាពមកពីផ្នែកឯកជន ផ្នែករដ្ឋ អង្គការសង្គមស៊ីវិល និងសហគមន៍ ។

**៥.៣.៦ ការអភិវឌ្ឍធនធានមនុស្ស និងសមភាពយេនឌ័រក្នុងវិស័យទេសចរណ៍**

**ក. ធនធានមនុស្សក្នុងវិស័យទេសចរណ៍ “ បុគ្គលិកម្នាក់ ជំនាញមួយ”**

- បើកវគ្គបណ្តុះបណ្តាលជំនាញក្នុងការផ្តល់សេវាកម្មទេសចរណ៍ទៅដល់ប្រតិបត្តិករទេសចរណ៍៖ ជាអាទិ៍មានវគ្គ បដិសណ្ឋារកិច្ច មគ្គុទ្ទេសក៏ទេសចរណ៍ ការិយាល័យជួរមុខ សេវាកម្មម្ហូបអាហារ និងភេសជ្ជៈ ចុងភៅ គេហកិច្ច និងផ្ទះកាហ្វេ។ល។
- បើកវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពជំនាញក្នុងការគ្រប់គ្រង និងផ្តល់សេវាកម្មទេសចរណ៍ដល់បណ្តាសហគមន៍ទេសចរណ៍/អេកូទេសចរណ៍ក្នុងខេត្ត
- ធ្វើការវាយតម្លៃពីតម្រូវការវគ្គបណ្តុះបណ្តាលថ្មីៗទៀតស្របតាមតម្រូវការជាក់ស្តែង
- ចុះពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងរមណីយដ្ឋាននានា
- បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលនានា រៀបចំឡើងដោយក្រសួងទេសចរណ៍ និងអង្គការនានា
- បន្តបណ្តុះបណ្តាលគ្រូបង្គោលជំនាញវិជ្ជាជីវៈទេសចរណ៍របស់មន្ទីរ និងឯកជន
- រៀបចំសិក្ខាសាលាវគ្គណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបយេនឌ័រស្ត្រី និងទីក្រុងស្អាត ស្ត្រីនិងការអភិវឌ្ឍបៃតង ស្ត្រីនិងសីលធម៌សង្គម ស្ត្រីនិងបដិសណ្ឋារកិច្ច ភាពជាអ្នកដឹកនាំ និងការបង្កើនភាពអងអាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីក្នុងវិស័យទេសចរណ៍ព្រមទាំង ផ្សព្វផ្សាយអនុសាសន៍ ១១ចំណុចរបស់**សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាអនុប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និង

អនុសាសន៍ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរ។

**ខ. អភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យទេសចរណ៍**

- រៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្មខេត្ត ០៥ ឆ្នាំ និងផែនការ ០៣ឆ្នាំរំកិល
- ពង្រឹងរចនាសម្ព័ន្ធការងាររបស់មន្ទីរទេសចរណ៍ខេត្តបែងចែកតួនាទី និងភារកិច្ចរបស់មន្ត្រីមន្ទីរទេសចរណ៍ទៅតាមជំនាញ និងបទពិសោធន៍
- បញ្ជូនមន្ត្រីឲ្យចូលរួមវគ្គបណ្តុះបណ្តាល ដែលរៀបចំដោយក្រសួងទេសចរណ៍ និងស្ថាប័នអប់រំទេសចរណ៍នានាទាំងក្នុង និងក្រៅប្រទេស
- លើកកម្ពស់ប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវរបស់មន្ត្រី ការគោរពវិន័យការងារ សាមគ្គីភាព ការខិតខំបំពេញភារកិច្ចដែលប្រគល់ជូនបានទាន់ពេលវេលា និងប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីរាជការ
- កៀរគរការចូលរួមរបស់អាជ្ញាធរ ស្ថាប័នជំនាញពាក់ព័ន្ធ ប្រតិបត្តិករទេសចរណ៍ និងដៃគូអភិវឌ្ឍជុំវិញខេត្ត ក្នុងដំណើរការអភិវឌ្ឍទេសចរណ៍
- សម្របសម្រួលកិច្ចសហការរវាងភាគីពាក់ព័ន្ធក្នុងវិស័យទេសចរណ៍
- បង្កបរិយាកាសងាយស្រួល និងអំណោយផលដល់រាល់គម្រោងវិនិយោគ និងអភិវឌ្ឍន៍ទេសចរណ៍ក្នុងខេត្ត
- បង្កើត និងដំណើរការប្រអប់គណនេយ្យភាព ដើម្បីទទួលយករាល់គំនិតរិះគន់ស្ថាបនារបស់ភាគីពាក់ព័ន្ធ និងមហាជនក្នុងខេត្ត ដើម្បីបន្តកែប្រែ និងពង្រឹងប្រសិទ្ធភាពការងាររបស់មន្ទីរទេសចរណ៍
- បើកវគ្គផ្សព្វផ្សាយអនុវត្តប្រកាស និងសេចក្តីណែនាំស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ទៅអោយរដ្ឋបាលខេត្ត ក្រុង ស្រុក ដល់ប្រតិបត្តករទេសចរណ៍ និងមន្ត្រីអង្គភាពច្រកចេញចូលតែមួយ
- ចុះពិនិត្យគាំទ្រលក្ខណៈបច្ចេកទេសដល់មន្ត្រីនៃមន្ទីរទេសចរណ៍ប្រចាំអង្គភាពច្រកចេញចូលតែមួយ
- ស្នើសុំមន្ត្រីក្របខណ្ឌបន្ថែម ដើម្បីបំពេញភារកិច្ចដែលមិនទាន់មានអ្នកទទួលបន្ទុក។

**៥.៣.៧ ការវិនិយោគក្នុងវិស័យទេសចរណ៍**

- សម្របសម្រួល និងពិភាក្សាលើបញ្ហាប្រឈម ដើម្បីស្វែងរកដំណោះស្រាយលើការងារ វិនិយោគជាមួយម្ចាស់វិនិយោគនៅតាមរមណីយដ្ឋាន
- សហការរៀបចំបញ្ជីរមណីយដ្ឋានទេសចរណ៍ និងតំបន់សក្តានុពលទេសចរណ៍ដើម្បីចុះបញ្ជីនិងផ្សព្វផ្សាយដើម្បីទាក់ទាញការវិនិយោគ

- សហការជាមួយមន្ទីរពាណិជ្ជកម្មដើម្បីសម្របសម្រួលដល់ការដាក់ពាក្យសុំចុះបញ្ជីពាណិជ្ជកម្មលើអាជីវកម្មទេសចរណ៍
- ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានទាក់ទងនឹងសក្តានុពលសម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍ ទៅដល់វិនិយោគិន និងដៃគូរអភិវឌ្ឍន៍ដែលចាប់អារម្មណ៍
- ជំរុញលើកទឹកចិត្តដល់វិនិយោគិនក្នុងស្រុក ក្នុងការរៀបចំភោជនីយដ្ឋានប្រកបដោយស្តង់ដា និងមានគុណភាពខ្ពស់ប្រចាំខេត្ត
- សិក្សារៀបចំផែនការវិនិយោគ និងគម្រោងស្នើសុំអភិវឌ្ឍន៍ទ្រុងទ្រាយតូច ឬមធ្យម សម្រាប់បណ្តារមណីយដ្ឋាន និងទីតាំងដែលមានសក្តានុពលទេសចរណ៍ ដើម្បីដាក់ជូនវិនិយោគិនដែលចាប់អារម្មណ៍ និងដៃគូរអភិវឌ្ឍន៍។

### ៥.៣.៨ ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ

- សហការការពារ អភិរក្សធនធានវប្បធម៌ដែលមានស្រាប់របស់ខេត្ត មានជាអាទិ៍ របាំវប្បធម៌ប្រពៃណីជនជាតិដើមភាគតិច
- អប់រំប្រជាពលរដ្ឋ ស្តីពីផលប៉ះពាល់អវិជ្ជមាននានាលើបរិស្ថាន និងធនធានធម្មជាតិ
- រៀបចំឲ្យមានឆ្នាំការពារធនធានធម្មជាតិនិងបរិស្ថាននៅតាមតំបន់រមណីយដ្ឋានសំខាន់នានា
- រៀបចំបន្តការផ្សព្វផ្សាយ ចលនាទេសចរម្នាក់ ដើមឈើមួយដើម
- រៀបចំអប់រំផ្សព្វផ្សាយដល់ប្រតិបត្តិករទេសចរណ៍ និងប្រជាពលរដ្ឋអំពីការគ្រប់គ្រងទេសចរណ៍បរិស្ថាន ការថែរក្សាអនាម័យបរិស្ថានតាមទីក្រុង ទីប្រជុំជន និងតាមគោលដៅទេសចរណ៍
- ជំរុញផ្សព្វផ្សាយយុទ្ធនាការទីក្រុងស្អាតជាទីក្រុងដែលគ្មានថង់ប្លាស្ទិកហើរតាមខ្យល់
- បន្តការចូលរួមផ្សព្វផ្សាយ ទិវាជាតិទីក្រុងស្អាត ប្រចាំឆ្នាំ ។







# VI. ធនធានហិរញ្ញវត្ថុ

# VI. ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ទ្រទ្រង់ ការអនុវត្តផែនការនេះ អាចបានមកពីថវិការដ្ឋ ធនធានពីផ្នែកឯកជន ការវិនិយោគពីដៃគូអភិវឌ្ឍន៍ពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងខេត្ត សប្បុរសជននានា និងប្រភពធនធានស្របច្បាប់ផ្សេងៗទៀត។ គម្រោងថវិកា នឹងត្រូវបានរៀបចំស្របទៅតាមសកម្មភាពនីមួយៗ ដើម្បីរៀបចំការអនុវត្តផែនការ ។ ( ដូចមានភ្ជាប់ក្នុង ឧបសម្ព័ន្ធ )

**១. ការស្វែងរក និងការលើកទឹកចិត្តការ វិនិយោគពីផ្នែកឯកជន និងការគាំទ្រ ពីដៃគូរអភិវឌ្ឍន៍**

រាល់បណ្តាផែនការដែលបានលើកឡើងពិតជាមិនអាចសម្រេចទៅបានទេ បើគ្មានការចូលរួម និងការគាំទ្រពីភាគីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍលើវិស័យទេសចរណ៍ ពិសេសទាក់ទងនឹងការគាំទ្រធនធានហិរញ្ញវត្ថុ ដែលជាកំលាំងចលករយ៉ាងសំខាន់ក្នុងការអនុវត្តផែនការ។ ដូចនេះការស្វែងរកការវិនិយោគពីគ្រប់ផ្នែក ពិសេសផ្នែកឯកជន និងការគាំទ្រពីដៃគូរអភិវឌ្ឍន៍ គឺមានសារៈសំខាន់ណាស់ ដើម្បីឲ្យគម្រោងអភិវឌ្ឍន៍មានដំណើរការ និងមាននិរន្តរភាព។ ផែនការដែលគាំទ្រដល់ការស្វែងរកការវិនិយោគ និងការគាំទ្រពីដៃគូរអភិវឌ្ឍន៍មានៈ

១. លើកទឹកចិត្តដល់ផ្នែកឯកជនវិនិយោគិនទាំងក្នុង និងក្រៅប្រទេសឲ្យមកបណ្តាក់ទុនលើវិស័យទេសចរណ៍ក្នុងខេត្ត ជាពិសេសគម្រោងវិនិយោគទ្រង់ទ្រាយធំ និងប្រើបច្ចេកទេសខ្ពស់

២. លើកទឹកចិត្តដល់អាជីវករក្នុងខេត្ត ឲ្យវិនិយោគលើមុខរបរផ្តល់សេវាកម្មទេសចរណ៍ទ្រង់ទ្រាយតូច និងមធ្យម ដូចជា ផ្ទះសំណាក់ ភោជនីយដ្ឋាន អាហារដ្ឋាន រមណីយដ្ឋាន ហាងលក់វត្ថុ អនុស្សាវរីយ៍ មគ្គុទេសក៍។ល។

៣. ជំរុញលើកទឹកចិត្តដល់សហគមន៍មូលដ្ឋានឲ្យរៀបចំបង្កើតរមណីយដ្ឋានទ្រង់ទ្រាយតូចទេសចរណ៍សហគមន៍ និងផ្តល់សេវាកម្ម ដូចជា ផ្ទះស្នាក់ អាហារ មគ្គុទេសក៍ សិប្បកម្ម ការសម្តែងសិល្បៈ ។ល។

៤. សម្រួលដល់ការដាក់ពាក្យសុំចុះបញ្ជីពាណិជ្ជកម្មលើអាជីវកម្មទេសចរណ៍ តាមយន្តការច្រកចេញចូលតែមួយ

៥. ផ្តល់ព័ត៌មានទាក់ទងនឹងសក្តានុពលសម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍ទៅដល់វិនិយោគិន និងដៃគូរអភិវឌ្ឍន៍ដែលចាប់អារម្មណ៍ដើម្បីស្វែងរកការវិនិយោគ

៦. សហការជាមួយគ្រប់ភាគីពាក់ព័ន្ធ និងដៃគូរអភិវឌ្ឍន៍លើគម្រោងអភិវឌ្ឍន៍ទេសចរណ៍

៧. រៀបចំផែនការវិនិយោគ និងគម្រោងសំណើរអភិវឌ្ឍន៍ទ្រង់ទ្រាយធំមធ្យម និងតូចសម្រាប់បណ្តារមណីយដ្ឋាន និងទីតាំងដែលមានសក្តានុពលដើម្បីដាក់ជូនវិនិយោគិន និងដៃគូអភិវឌ្ឍន៍ដែលមានសក្តានុពលចាប់អារម្មណ៍។







# VII. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

# VII. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ផែនការសម្រាប់ការអភិវឌ្ឍនេះទាមទារការពិនិត្យ និងវាយតម្លៃការអនុវត្តទៅតាមកាលកំណត់នីមួយៗ ដោយពឹងផ្អែកជាមូលដ្ឋានលើផែនការសកម្មភាព និងវិធានការទាំងឡាយដែលបានដាក់ចេញរួមទាំងសូចនាករគោលសំខាន់ៗ។ បន្ទាប់ពីឯកសារផែនការនេះត្រូវបានអនុម័តសូចនាករតាមដាន នឹងត្រូវបានរៀបចំភ្លាម ហើយប្រគល់ភារកិច្ចអនុវត្តទៅតាមផ្នែកពាក់ព័ន្ធនីមួយៗ។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តផែនការនេះ នឹងត្រូវបានធ្វើឡើងតាមយន្តការ**គណៈកម្មាធិការគ្រប់គ្រងអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី** ។

**គណៈកម្មាធិការគ្រប់គ្រងអភិវឌ្ឍន៍ទេសចរណ៍ខេត្ត**ត្រូវប្រជុំ ពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ទេសចរណ៍នេះយ៉ាងតិចមួយដងក្នុងមួយឆ្នាំ និងកិច្ចប្រជុំវិសាមញ្ញផ្សេងៗទៀតទៅតាមការចាំបាច់។ នៅរៀងរាល់បំណាច់ឆ្នាំមួយៗ ត្រូវមានការបូកសរុបលទ្ធផលនៃការអនុវត្ត និងរាយការណ៍លទ្ធផលនេះជូនក្រសួងទេសចរណ៍ និងអាជ្ញាធរខេត្ត។ នៅឆ្នាំ២០២៣ត្រូវចាត់ទុកជាឆ្នាំពាក់កណ្ដាលអាណត្តិនៃការអនុវត្តផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្មនេះ ដោយត្រូវពិនិត្យ និងវាយតម្លៃលទ្ធផលរួមពាក់កណ្ដាល អាណត្តិ។ ក្រោយការត្រួតពិនិត្យម្ដងៗ ផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្មនេះអាចត្រូវបានកែសម្រួលតាមសភាពការណ៍ជាក់ស្ដែងដោយមានការពិនិត្យម៉ត់ចត់ និងស្នើឡើងដោយ**គណៈកម្មាធិការគ្រប់គ្រងអភិវឌ្ឍន៍ទេសចរណ៍ខេត្ត**ពិនិត្យ និងសម្រេច ។







# VIII. សេចក្តីសន្និដ្ឋាន

# VIII. សេចក្តីសន្និដ្ឋាន

ខេត្តមណ្ឌលគិរី គឺជាខេត្តមួយដែលមានសក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍទេសចរណ៍ ទាំងបែបធម្មជាតិ និងវប្បធម៌ដោយសារធនធានដ៏សម្បូរបែបដែលមាននៅពាសពេញ និងដែលមិនទាន់បានប្រើប្រាស់ ឲ្យអស់លទ្ធភាព។ ទេសចរណ៍ក៏ជាវិស័យអាទិភាពមួយរបស់ខេត្តសម្រាប់លើកកម្ពស់សេដ្ឋកិច្ច ការអភិរក្សធនធានធម្មជាតិ វប្បធម៌ បរិស្ថាន និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនក្នុងខេត្តដាច់ស្រយ៉ាលមួយនេះ។

ដើម្បីឲ្យការអភិវឌ្ឍទេសចរណ៍ខេត្តអាចធានាបាននូវប្រសិទ្ធភាព និរន្តរភាព ការទទួលខុសត្រូវ ជៀសវាងបានជាអតិបរមានូវផលប៉ះពាល់អវិជ្ជមាន និងឈានទៅសម្រេចលទ្ធផលដែលរំពឹងទុក ការគ្រប់ គ្រង និងអភិវឌ្ឍទេសចរណ៍ត្រូវមានផែនការមួយច្បាស់លាស់ ដែលបង្កើតឡើងដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធសំខាន់ៗក្នុងខេត្ត និងដោយមានការផ្តល់យោបល់ពីថ្នាក់ដឹកនាំក្រសួងទេសចរណ៍ ដើម្បីយកទៅអនុវត្តប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ។

ឯកសារផែនការនេះ ជាត្រីវិស័យមួយ ដើម្បីសម្រេចគោលបំណងក្នុងការអភិវឌ្ឍទេសចរណ៍ខេត្តមណ្ឌលគិរី យ៉ាងពិតប្រាកដ ការអនុវត្តតាមផែនការដែលបានរៀបចំ គឺជាកិច្ចការចាំបាច់ ក្នុងនោះការប្រមូល ផ្តុំធនធានចាំបាច់នានា ដើម្បីយកទៅអនុវត្ត គឺជាគន្លឹះមួយដើម្បីឈានទៅសម្រេចគោលដៅនេះ។ លើសពីនេះទៀត ដើម្បីឲ្យផែនការអាចអនុវត្តទៅបានដោយរលូនក៏តម្រូវឲ្យមានធនធានមនុស្សបម្រើការលើ វិស័យនេះផងដែរ។ ដូចនេះ ជំហានបន្ទាប់ គឺការកៀរគរធនធានទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដើម្បីយកមកអនុវត្តផែនការឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ដើម្បីរួមចំណែកសម្រេចគោលដៅអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា និងគោលដៅអភិវឌ្ឍន៍ខេត្តក្នុងរយៈពេល ០៥ ឆ្នាំ ខាងមុខ ។

# ផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០២១-២០២៥ ខេត្តមណ្ឌលគិរី

| ល.រ | ឈ្មោះគម្រោង/សកម្មភាព | ស្ថាប័នទទួលខុសត្រូវ | ពេលខ្លី ២០២១ ២០២២ | ពេលវែង ២០២៣ ២០២៥ | ប្រភពថវិកា |
|---|---|---|---|---|---|
| **១. ការអភិវឌ្ឍផលិតផលទេសចរណ៍** | | | | | |
| ១.១ | ការអភិវឌ្ឍសម្បទាទេសចរណ៍តំបន់អាទិភាព | | | | |
| ១.១.១ | រៀបចំកែសម្រួលផែនទីទេសចរណ៍ខេត្តមណ្ឌលគីរីនិងលើកស្លាកផ្ទាំងប៉ាណូផ្សព្វផ្សាយតាមតំបន់សំខាន់ៗក្នុងខេត្ត | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ |
| ១.១.២ | សាងសង់មណ្ឌលព័ត៌មានទេសចរណ៍នៅលើទីតាំងដែលសាលាខេត្តបានកំណត់ទុកឲ្យមន្ទីរទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ |
| ១.១.៣ | រៀបចំរមណីយដ្ឋានដែលកំពុងដំណើរការទាំង០៧កន្លែងឲ្យមានស្របតាមស្តង់ដាអប្បបរមាសម្រាប់រមណីយដ្ឋានទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.១.៤ | យុទ្ធនាការ "ភោជនីយដ្ឋានស្អាត ៖ ភោជនីយដ្ឋានគ្មានសំរាមជាក្រដាស់" | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.១.៥ | រៀបចំផែនការ និងបែងចែកតំបន់សក្តានុពលសម្រាប់អភិវឌ្ឍន៍អេកូទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ១.១.៦ | រៀបចំតំបន់រមណីយដ្ឋានអេកូទេសចរណ៍គំរូ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ១.១.៧ | ពង្រឹងគុណភាព ផលិតផលក្នុងរមណីយដ្ឋានអេកូទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ១.១.៨ | បញ្ជ្រាបការយល់ដឹង និងការអប់រំពីទេសចរណ៍ អេកូទេសចរណ៍ទៅដល់សហគមន៍ និងភ្ញៀវទេសចរ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ១.១.៩ | សហការពង្រឹង និងពង្រីកការបង្កើតសហគមន៍ទេសចរណ៍ និងសហគមន៍អេកូទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ១.១.១០ | ជំរុញចលនាទេសចរណ៍ម្នាក់ ដើមឈើមួយដើមនៅតាមបណ្ដាសហគមន៍ទេសចរណ៍/អេកូទេសចរណ៍ និងរមណីយដ្ឋានអេកូទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ១.១.១១ | ជំរុញយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ថង់ផ្លាស់ស្ទិកហើរតាមខ្យល់ | មន្ទីរបរិស្ថាន និង មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ១.១.១២ | លើកកម្ពស់កសិទេសចរណ៍នៅតាមសហគមន៍ទេសចរណ៍តាមរយៈការផ្គត់ផ្គង់បន្លែ ផ្លែឈើគ្មានគីមី ការចិញ្ចឹមសត្វ និងសិប្បកម្ម | មន្ទីរកសិកម្ម និង មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ១.១.១៣ | សហការចុះសិក្សាលទ្ធភាពរៀបចំ សហគមន៍ដាំបន្លែ ចិញ្ចឹម សត្វ និងសិប្បកម្ម ដើម្បីជំរុញលើកទឹកចិត្តដល់សហគ្រាស ធុនតូច និង មធ្យម ក្នុង វិស័យទេសចរណ៍ក្នុង ខេត្ត | មន្ទីរកសិកម្ម និង មន្ទីរទេសចរណ៍ | | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ១.២ | **ការអភិវឌ្ឍទេសចរណ៍ថ្មីៗ** | | | | |
| ១.២.១ | ចុះពិនិត្យ និងវាយតម្លៃ សេវាកម្មដែលមាន និងកម្រិតគុណភាពសេវាកម្មនៅតាមតំបន់រមណីយដ្ឋានសាធារណៈ និងឯកជន | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.២.២ | ផ្សព្វផ្សាយ និងជំរុញការអនុវត្តតាមស្តង់ដាររមណីយដ្ឋានទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.២.៣ | សហការចុះសិក្សាស្រាវជ្រាវលទ្ធភាពដើម្បីអភិវឌ្ឍគម្រោងទេសចរណ៍នៅតាមតំបន់ដែនជម្រកសត្វព្រៃ | មន្ទីរទេសចរណ៍<br>មន្ទីរបរិស្ថាន | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.២.៤ | សហការរៀបចំព្រឹត្តិការណ៍ទេសចរណ៍នានាដែលអាចឆ្លុះបញ្ចាំងពីអត្តសញ្ញាណ និងប្រវត្តិខេត្ត | មន្ទីរទេសចរណ៍<br>មន្ទីរវប្បធម៌វិចិត្រសិល្បៈ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.២.៥ | រៀបចំអភិវឌ្ឍន៍ផលិតផល សេវាកម្មសហគមន៍ទេសចរណ៍ធម្មជាតិនិងសហគមន៍អេកូទេសចរណ៍ កសិទេសចរណ៍ថ្មីៗបន្ថែម | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.២.៦ | ជំរុញរៀបចំព្រឹត្តិការណ៍ទេសចរណ៍នានាក្នុងខេត្ត ( ការប្រណាំងសត្វក្របី )សេះ ព្រឹត្តការណ៍សង្ក្រានខេត្តមណ្ឌលគីរីជាដើម | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៣ | **ការអភិវឌ្ឍទេសចរណ៍ក្នុងក្រុងនិងជុំវិញក្រុង** | | | | |
| ១.៣.១ | ប្រារព្ធ ពិធីអបអរសា ទរទិវាជាតិទីក្រុងស្អាត | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ១.៣.២ | រៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តង់ដាទីក្រុងស្អាត | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៣.៣ | បណ្តុះបណ្តាលស្តីពីស្តង់ដាសេវាកម្ម "វិថីលក់ ម្ហូបអាហារ" និង "តូបលក់ម្ហូបអាហារ" | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៣.៤ | បន្តសហការជាមួយសាលាក្រុងសែនមនោរម្យ និងអាជ្ញាធរឃុំ សង្កាត់ ដើម្បីអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីអនាម័យ ការទុកដាក់សំរាម និងការថែរក្សាបរិស្ថាននៅតាមគេហដ្ឋាន និងទីធ្លាសាធារណៈ | សាលាខេត្ត និង មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៣.៥ | សហការរៀបចំបង្កើតកន្លែងកម្សាន្តនានា និងរៀបចំដំណើរទេសស្សនកិច្ចជុំវិញក្រុងសែនមនោរម្យ | មន្ទីរទេសចរណ៍ | | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៣.៦ | រៀបចំកែលម្អក្រុងសែនមនោរម្យឲ្យមានភាពបៃតងអភិវឌ្ឍន៍សួនច្បារក្នុងក្រុងសែនមនោរម្យ | សាលាខេត្ត និង មន្ទីរសាធារណៈការ និងដឹកជញ្ជូន | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៣.៧ | រៀបចំកសាងនិងកែលម្អសេវាកម្មបង្គន់អនាម័យសាធារណៈក្នុងក្រុងសែនមនោរម្យ | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៣.៨ | រៀបចំកែលម្អចំណតរថយន្តទេសចរណ៍ឲ្យមានសណ្តាប់ធ្នាប់ | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ រដ្ឋបាលក្រុង | | | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ១.៣.៩ | រៀបចំដាក់ធុងសំរាមឲ្យបានគ្រប់គ្រាន់នៅទីសាធារណៈសំខាន់ៗ ក្នុងក្រុងសែនមនោរម្យ និងតាមទីតាំងទេសចរណ៍សំខាន់ៗ | មន្ទីរបរិស្ថានខេត្ត | ✓ | | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| **១.៤** | **ការស្រាវជ្រាវប្រវត្តិសំខាន់ៗតាមតំបន់រមណីយដ្ឋានទេសចរណ៍ និងពិធីបុណ្យផ្សេងៗ** | | | | |
| ១.៤.១ | ប្រមូលព័ត៌មាននិងចងក្រងឯកសារ ពិធីបុណ្យផ្សេងៗនិងប្រវត្តិសំខាន់ៗ ដែលពាក់ព័ន្ធតំបន់ទេសចរណ៍ក្នុងខេត្តមណ្ឌលគិរី | មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ<br>មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ១.៤.២ | រៀបចំបង្កើតព្រឹត្តិការណ៍បុណ្យទាន និងកីឡាថ្មីៗដែលអាចទាក់ទាញទេសចរ | មន្ទីរទេសចរណ៍ និងមន្ទីរវប្បធម៌វិចិត្រសិល្បៈ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ១.៤.៣ | រៀបចំពិធីបុណ្យអេកូទេសចរណ៍នៅតាមសហគមន៍អេកូទេសចរណ៍ និងនៅតាមតំបន់ទាក់ទាញសំខាន់ៗ | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ១.៤.៤ | រៀបចំបកប្រែនិងបោះពុម្ពឯកសារ ពិធីផ្សេងៗ និងប្រវត្តិសំខាន់ៗ ដែលពាក់ព័ន្ធតំបន់ទេសចរណ៍ក្នុងខេត្តមណ្ឌលគិរីទៅក្នុងបណ្តាញទំនាក់ទំនងដូចជា) (គេហទំព័រទេសចរណ៍និងទស្សនាវដ្ដីជាដើម | មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ<br>មន្ទីរទេសចរណ៍ | | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ១.៤.៥ | សហការជាមួយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈក្នុងការស្រាវជ្រាវពីរបាំប្រពៃណីប្រចាំខេត្តនិងនៅតាមភូមិឃុំ ស្រុក ក្រុងនានាក្នុងខេត្ត | មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ<br>មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ១.៤.៦ | សហការជាមួយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈក្នុងការចងក្រងរឿងព្រេងនិទាននានាទាក់ទងនឹងភូមិសាស្ត្រក្នុងខេត្តមណ្ឌលគិរី | មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ<br>មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៤.៧ | សហការជាមួយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈក្នុងការរៀបចំនិងអភិរក្សសម្បត្តិវប្បធម៌ប្រវត្តិសាស្ត្រនៅក្នុងក្រុង និងស្រុកនានា ដូចជាទីទួលប្រាសាទនានា | មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ<br>មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| **១.៥** | **ការអភិវឌ្ឍផលិតផល សេវាកម្មទេសចរណ៍បន្ថែម** | | | | |
| ១.៥.១ | រៀបចំបង្កើតសមាគមវត្ថុអនុស្សាវរីយ៍និងផលិតផលសហគមន៍ខេត្តមណ្ឌលគិរី | មន្ទីរទេសចរណ៍<br>មន្ទីរពាណិជ្ជកម្ម | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៥.២ | រៀបចំបង្កើតមណ្ឌលផ្សព្វផ្សាយនិងគាំទ្រដល់វត្ថុអនុស្សាវរីយ៍និងផលិតផលសហគមន៍ក្នុងខេត្តមណ្ឌលគិរី | មន្ទីរទេសចរណ៍<br>មន្ទីរពាណិជ្ជកម្ម | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៥.៣ | ជំរុញនិងលើកទឹកចិត្តដល់អ្នកវិនិយោគទុនក្នុងការរៀបចំបង្កើតមជ្ឈមណ្ឌលកម្សាន្តនានាក្នុងខេត្តមណ្ឌលគិរី | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៥.៤ | ផ្តួចផ្តើមរៀបចំបង្កើតផ្សាររាត្រីប្រចាំខេត្តមណ្ឌលគិរី | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| ១.៦ | ជំរុញគុណភាពផលិតផល និងសេវាកម្មទេសចរណ៍ | | | | |
|---|---|---|---|---|---|
| ១.៦.១ | ចុះពិនិត្យ វាយតម្លៃ និងលើកគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍នានាចាំបាច់ក្នុងខេត្ត | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៦.២ | ចុះពិនិត្យវាយតម្លៃ ណែនាំ និងពង្រឹងសមត្ថភាពដល់ក្រុមសិប្បកម្មទាំង ០៥កន្លែង | មន្ទីរពាណិជ្ជកម្ម និងមន្ទីរទេសចរណ៍ មន្ទីរកិច្ចការនារី | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៦.៣ | កសាងសមត្ថភាពដល់សមាជិកគណៈកម្មាធិការគ្រប់គ្រងតំបន់រមណីយដ្ឋាន | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៦.៤ | ស្វែងរកទីផ្សារទេសចរណ៍សម្រាប់ផលិតផលសិប្បកម្មកែច្នៃក្នុងស្រុក | មន្ទីរពាណិជ្ជកម្ម និងមន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៦.៥ | បើកវគ្គបណ្តុះបណ្តាលដល់ប្រតិបត្តិករទេសចរណ៍លើជំនាញសេវាកម្មដែលនៅមានភាពខ្វះខាតរួមមាន ការិយាល័យជួរមុខ គេហកិច្ច សេវាកម្មម្ហូបអាហារ និងភេសជ្ជៈ ចុងភៅ និងឆុងកាហ្វេ | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៦.៦ | ពង្រឹង និងរៀបចំក្រុមអ្នកនាំទេសចរទស្សនាដំរីនៅភូមិពូតាំង និងភូមិពូ លូង | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ១.៦.៧ | ចុះវាយតម្លៃចំណាត់ថ្នាក់សណ្ឋាគារ រមណីយដ្ឋាន ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៦.៨ | រៀបចំបង្កើតសមាគមមគ្គុទេសក៍ទេសចរណ៍ខេត្តមណ្ឌលគិរី( ការកំណត់ឲ្យមាន )ឯកសណ្ឋានច្បាស់លាស់និងការពង្រឹងគុណភាពសេវាកម្ម | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ១.៦.៩ | បណ្តុះបណ្តាលដល់សហគមន៍ទេសចរណ៍អំពីអនាម័យនិងការផ្តល់សេវាកម្មប្រកបដោយគុណភាព | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| **២. ការសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍** | | | | | |
| ២.១ | រៀបចំសិក្សាស្រាវជ្រាវទីផ្សារទេសចរណ៍ខេត្តមណ្ឌលគិរី ដោយសិក្សាលម្អិតពីប្រភេទភ្ញៀវទេសចរដែលចូលមកកម្សាន្តនិងតម្រូវការរបស់ភ្ញៀវលើផលិតផលទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| | ជ្រើសរើសប្រព័ន្ធផ្សព្វផ្សាយសមស្រប និងធ្វើការផ្សព្វផ្សាយដើម្បីទាក់ទាញទីផ្សារគោលដៅ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ២.២ | ធ្វើបច្ចុប្បន្នភាពនិងចងក្រងទិន្នន័យសក្តានុពលទេសចរណ៍ដើម្បីបញ្ចូលទៅក្នុងឧបករណ៍ផ្សព្វផ្សាយ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ២.៣ | ពង្រឹងការគ្រប់គ្រងមណ្ឌលព័ត៌មានទេសចរណ៍ដើម្បីផ្តល់ព័ត៌មានជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ២.៤ | ចរចារជាមួយនឹងខេត្តដាក់ណុង ដាក់ឡាក់ ប៊ិញភឿក (វៀតណាម) ដើម្បីទាក់ទាញ និងដោះដូរភ្ញៀវទេសចររវាងខេត្តទាំងបួន | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ២.៥ | រៀបចំសិក្ខាទីផ្សារ និងផ្សព្វផ្សាយអេកូទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ២.៦ | រៀបចំបង្កើតគេហទំព័រព័ត៌មានទេសចរណ៍ខេត្តមណ្ឌលគីរីនិងធ្វើការផ្សព្វ ផ្សាយព័ត៌មានផលិតផលទេសចរណ៍តំបន់សក្តានុពលទេសចរណ៍ក្នុងខេត្តទាំងមូល តាមរយៈភ្ជាប់ជាមួយគេហទំព័រល្បីៗ របស់ក្រុមហ៊ុនការីទេសចរណ៍សំខាន់ៗ ទាំងក្នុងប្រទេសនិងក្រៅប្រទេស | មន្ទីរទេសចរណ៍ និងមន្ទីរព័ត៌មាន | | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ២.៧ | បង្កើតសៀវភៅមគ្គុទេសក៏ទេសចរណ៍ខេត្តអោយបានទូលំទូលាយតាមភ្នាក់ ងារទេសចរណ៍នានាក្នុងក្រុងភ្នំពេញ ក្រុងព្រះសីហនុ ក្រុងសៀមរាបនិងខេត្តមួយចំនួនទៀតដែលមានសក្តានុពលទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ២.៨ | ផ្សព្វផ្សាយបទចម្រៀងទេសចរណ៍ និងស្បតវីដេអូទេសចរណ៍ខ្លីៗ ដែលបានផលិតនិងបង្ហាញពី តំបន់សក្តានុពលទេសចរណ៍ក្នុងខេត្តនិងផលិតផលទេសចរណ៍ថ្មីៗ ដែលបានអភិវឌ្ឍន៍តាមប្រព័ន្ធផ្សព្វផ្សាយក្នុងខេត្ត និងជាតិដោយធ្វើការសហការជាមួយមន្ទីរព័ត៌មានខេត្ត | មន្ទីរទេសចរណ៍ និងមន្ទីរព័ត៌មាន | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ២.៩ | រៀបចំចងក្រងព័ត៌មានផលិតផលទេសចរណ៍ដែលបានរៀបចំថ្មីៗបន្ថែម ដោយបញ្ចូលក្នុងគេហទំព័រទេសចរណ៍ និងសៀវភៅផ្ទត់ទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ២.១០ | រៀបចំសិក្ខាសាលាផ្សព្វផ្សាយផលិតផលទេសចរណ៍ទាំងក្នុង និងក្រៅស្រុកនៅក្នុងខេត្តមណ្ឌលគីរី | មន្ទីរទេសចរណ៍ | | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ២.១១ | រៀបចំព្រឹត្តិការណ៍សំខាន់ៗក្នុងខេត្ត( ប្រគុំតន្ត្រីទេសចរណ៍ ការតាំងពិព័រណ៍ )ផលិតផល និងពិធីបុណ្យជាតិសំខាន់ៗនៅក្នុងខេត្តមណ្ឌលគីរី | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ២.១២ | រៀបចំដំណើរកំសាន្តទេសចរណ៍រួមគ្នារបស់ភ្នាក់ងារទេសចរណ៍និងការីទេសចរណ៍ជាតិ និងអន្តរជាតិធំៗ និងការចូលរួមពីអ្នកប្រតិបត្តិករទេសចរណ៍សំខាន់ៗមកកាន់តំបន់គោលដៅខេត្តមណ្ឌលគិរី | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ២.១៣ | រៀបចំបោះពុម្ពឯកសារផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម២០២១-២០២៥ខេត្តមណ្ឌលគិរី និងបកប្រែជាភាសាអង់គ្លេស | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| **៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្រួលការធ្វើដំណើរទេសចរណ៍** | | | | | |
| ៣.១ | ជំរុញដោះស្រាយបញ្ហាប្រឈមនានាដើម្បីសម្រួលការធ្វើដំណើរនិងការដឹកជញ្ជូនក្នុងវិស័យទេសចរណ៍ | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៣.២ | ស្នើសុំអោយមានការអភិវឌ្ឍនិងជួសជុលផ្លូវចូលទៅកាន់រមណីយដ្ឋានទេសចរណ៍សំខាន់ៗក្នុងខេត្តមណ្ឌលគិរី | មន្ទីរសាធារណការនិងដឹកជញ្ជូន | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៣.៣ | សិក្សាស្រាវជ្រាវស្វែងរកដៃគូវិនិយោគរៀបចំទីចំណតក្នុងក្រុង និងទីប្រជុំជនប្រកបដោយសោភ័ណ្ឌភាព | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៣.៤ | សិក្សារៀបចំទីសម្រាកទេសចរ និងបង្គន់សាធារណៈនៅតាមតំបន់រមណីយដ្ឋាននានាក្នុងខេត្តមណ្ឌលគិរី | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៣.៥ | សម្រួលជួសជុលផ្លូវឱ្យមានលក្ខណៈទូលាយមានសុវត្ថិភាពនិងសោភ័ណភាព | មន្ទីរសាធារណការនិងដឹកជញ្ជូន | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| ៤. សន្តិសុខ សុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាន | | | | | |
|---|---|---|---|---|---|
| **៤.១** | **វិធានការពង្រឹងសន្តិសុខ សុវត្ថិភាពភ្ញៀវទេសចរ** | | | | |
| ៤.១.១ | សិក្សារៀបចំផែនការសន្តិសុខ សុវត្ថិភាពដើម្បីធានាសុវត្ថិភាពភ្ញៀវនៅតាមរមណីយដ្ឋានអេកូទេសចរណ៍ | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៤.១.២ | ជំរុញការរក្សាអនាម័យ បរិស្ថាន នៅតាមទីក្រុងទីប្រជុំជន និងគោលដៅទេសចរណ៍ទាំងអស់ | មន្ទីរបរិស្ថាន មន្ទីរទេសចរណ៍ និងអាជ្ញាធរក្រុង ស្រុក | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៤.១.៣ | ជំរុញពង្រឹងតួនាទីរបស់នគរបាលទេសចរណ៍ និងបំផុសចលនាការពារ រ បស់សហគមន៍ដោយការចូលរួមរបស់ប្រជាជនតាមស្មារតីប្រជាជនម្នាក់ ជាអ្នកការពារម្នាក់នៅតាមរមណីយដ្ឋាន និងទីកន្លែងទេសចរណ៍ | អាជ្ញាធរខេត្ត ក្រុង ស្រុក និងមន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៤.១.៤ | ពិនិត្យលទ្ធភាព និងរៀបចំឲ្យមានកន្លែងសង្គ្រោះបឋម មធ្យោបាយដឹកជញ្ជូន និងការទំនាក់ទំនងតាមតំបន់គោលដៅទេសចរណ៍នានា ដើម្បីជួយ សង្គ្រោះភ្ញៀវពេលមានគ្រោះថ្នាក់ | មន្ទីរសុខាភិបាល មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៤.១.៥ | ផ្តល់ការអប់រំបណ្តុះបណ្តាល ដល់អ្នកពាក់ព័ន្ធ ពិសេស មគ្គុទេសក៍ទេសចរណ៍ អំពីវិធី របៀបសង្គ្រោះបឋម ព័ត៌មាន រហ័ស និងការត្រៀម បង្ការទប់ស្កាត់បញ្ហាផ្សេងៗ ដែលអាចកើតឡើងចំពោះភ្ញៀវ | មន្ទីរទេសចរណ៍ និងមន្ទីរសុខាភិបាល | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ៤.១.៦ | សហការជាមួយមន្ទីរជំនាញចុះអប់រំប្រតិបត្តិករទេសចរណ៍ ស្តីពីអនាម័យចំណីអាហារ និងការថែរក្សាបរិស្ថាន នៅតាមភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ រមណីយដ្ឋាន និងកន្លែងកម្សាន្តនានា | មន្ទីរសុខាភិបាល<br>មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/<br>ឯកជន |
| ៤.១.៧ | ណែនាំដល់ប្រតិបត្តិករទេសចរណ៍ សហគមន៍ទេសចរណ៍អោយមានបំពាក់នូវឧបករណ៍ សម្ភារៈនិងមធ្យោបាយសមស្រប ដើម្បីបង្ការនិងជួយសង្គ្រោះបន្ទាន់ក្នុងករណីភ្ញៀវមានគ្រោះថ្នាក់ | មន្ទីរសុខាភិបាល<br>មន្ទីរទេសចរណ៍<br>ស្នងការនគរបាលខេត្ត | ✓ | | ថវិការដ្ឋ /ដៃគូរ/<br>ឯកជន |
| ៤.១.៨ | រៀបចំប្រព័ន្ធផ្តល់ព័ត៌មានទំនាក់ទំនង តាមតំបន់គោលដៅទេសចរណ៍នានាក្នុងខេត្ត | មន្ទីរទេសចរណ៍<br>ស្នងការនគរបាលខេត្ត | ✓ | | ថវិការដ្ឋ /ដៃគូរ/<br>ឯកជន |
| ៤.១.៩ | ផ្សព្វផ្សាយបណ្តុះបណ្តាលអប់រំស្តីពី វិធានការ ៣ការពារ គឺពាក់ម៉ាស់ លាងដៃ និងរក្សាគម្លាតសុវត្ថិភាព និងវិធានការ ៣កុំ គឺកុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំចូលទៅកន្លែងដែលបិទជិតឈឹង និងកុំប៉ះពាល់គ្នា គ្រោះថ្នាក់នៃគ្រឿងញៀន ជំងឺអេដស៍ ច្បាប់ស្តីពីកិច្ច ការពារ និងលើកកម្ពស់ សិទ្ធិជនមានពិការភាព និងលិខិតបដ្ឋានគតិយុត្តនានា ដើម្បីធានាបានបរិស្ថានគ្មានផ្សែងបារីក្នុងវិស័យទេសចរណ៍ | មន្ទីរសុខាភិបាល<br>និងមន្ទីរទេសចរណ៍<br>មន្ទីរពាក់ព័ន្ធ និង<br>ស្នងការ នគរបាលខេត្ត | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/<br>ឯកជន |

| ៤.២ | ការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន | | | | |
|---|---|---|---|---|---|
| ៤.២.១ | ចូលរួមនូវគ្រប់សកម្មភាពនៃការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ | មន្ទីរកិច្ចការនារី<br>មន្ទីរទេសចរណ៍<br>និងស្នងការនគរបាលខេត្ត | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៤.២.២ | ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់និងបញ្ជ្រាបការយល់ដឹងអំពីផលប៉ះពាលនៃគ្រឿងញៀនដល់ប្រត្តិបតិករទេសចរណ៍ និង អ្នកបម្រើសេវា | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍<br>និងស្នងការនគរបាលខេត្ត | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៤.២.៣ | ចូលរួមនូវរាល់សកម្មភាពក្នុងការទប់ស្កាត់ការជួញដូរមនុស្សនិងបញ្ជ្រាបការយល់ដឹងដល់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ក្នុងខេត្ត | មន្ទីរកិច្ចការនារី<br>មន្ទីរទេសចរណ៍<br>និងស្នងការនគរបាលខេត្ត | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៤.២.៤ | ធ្វើការផ្សព្វផ្សាយណែនាំនិងទប់ស្កាត់ការបំពុលបរិស្ថានដែលកើតពីសកម្មភាពរបស់ភ្ញៀវទេសចរ | មន្ទីរបរិស្ថាន<br>មន្ទីរទេសចរណ៍ | | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៤.២.៥ | មានវិធានការក្នុងការលប់បំបាត់ភាពអានាធិបតេយ្យផ្សេងៗនិងសកម្មភាពការកេងប្រវ័ញ្ចន៍នានាចំពោះភ្ញៀវទេសចរនិងសកម្មភាពអាជីវកម្មផ្សេងៗ | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ៤.២.៦ | ធ្វើការផ្សព្វផ្សាយអប់រំវិធានការ ៣ការពារ គឺពាក់ម៉ាស់ លាងដៃ និងរក្សាគម្លាតសុវត្ថិភាព និងវិធានការ ៣កុំ គឺកុំទៅកន្លែងដែលមានមនុស្សច្រើនកុះករ កុំចូលទៅកន្លែងដែលបិទជិតឈឹង និងកុំប៉ះពាល់គ្នា | គណៈកម្មការខេត្តដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19) ក្នុងខេត្តមណ្ឌលគិរី មន្ទីរទេសចរណ៍ | | ✓ | ថវិការដ្ឋ |
| ៤.២.៧ | ផ្សព្វផ្សាយអប់រំវិធានសុវត្ថិភាពទេសចរណ៍ | ក្រុមការងារជម្រុញណែនាំ និងតាមដាន ការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ | | ✓ | ថវិការដ្ឋ |
| **៥. ប្រព័ន្ធច្បាប់ និងយន្តការគ្រប់គ្រង** | | | | | |
| ៥.១ | ចុះផ្សព្វផ្សាយ ណែនាំ អនុវត្តច្បាប់ស្តីពីទេសចរណ៍ បទបញ្ញត្តិស្តីពីការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ដល់ប្រតិបត្តិករទេសចរណ៍ និងសហគមន៍ទេសចរណ៍ | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៥.២ | សហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ចុះតាមដាន ត្រួតពិនិត្យតាមបណ្តាអាជីវកម្មទេសចរណ៍ ដើម្បីពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានគតិយុត្តនានា | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៥.៣ | សហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គភាពពាក់ព័ន្ធចាត់វិធានការទប់ស្កាត់សកម្មភាពអាជីវកម្មទេសចរណ៍ខុសច្បាប់ និងគ្មានអាជ្ញាប័ណ្ណ | គណៈកម្មាធិការអភិវឌ្ឍទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ៥.៤ | ប្រមូល និងចងក្រងទិន្នន័យស្តីពីបណ្តាឧស្សាហកម្មទេសចរណ៍ក្នុងខេត្ត ដើម្បីក្តាប់ឲ្យបានពីទំហំ និងសកម្មភាព អាជីវកម្មពាក់ព័ន្ធនឹងទេសចរណ៍ ក្នុងខេត្ត | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៥.៥ | បង្កើតបណ្តាញអ្នកតាមដានត្រួតពិនិត្យ និងរាយការណ៍ពីការអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងបទដ្ឋានគតិយុត្តនានា ដោយប្រមូលផ្តុំសមាសភាពមកពីវិស័យឯកជន រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងសហគមន៍ | មន្ទីរទេសចរណ៍ និងអាជ្ញាធរខេត្ត | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៥.៦ | រៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្មខេត្ត ០៥ ឆ្នាំ និង ផែនការ ០៣ឆ្នាំរំកិល | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៥.៧ | បង្កើតប្រអប់គណនេយ្យភាព ដើម្បីទទួលយករាល់គំនិតរិះគន់ស្ថាបនារបស់ភាគីពាក់ព័ន្ធ និងមហាជនក្នុងខេត្ត ដើម្បីបន្តកែប្រែនិងពង្រឹងប្រសិទ្ធ ភាពការងាររបស់មន្ទីរ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៥.៧ | បើកវគ្គ ផ្សព្វផ្សាយអនុវត្តប្រកាស និងសេចក្តីណែនាំ ស្តីពីការធ្វើប្រតិភូកម្មមុខងារផ្តល់សេវាទេសចរណ៍ ទៅដល់រដ្ឋបាលខេត្តក្រុងស្រុក និងមន្ត្រីអង្គភាពច្រកចេញចូលតែមួយ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៥.៨ | ប្រមូលនិងចងក្រងទិន្នន័យប្រភេទអាជីវកម្មទេសចរណ៍នៅក្នុងខេត្តទាំងមូល | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| ៦. ការអភិវឌ្ឍធនធានមនុស្ស និងសមភាពយេនឌ័រ | | | | | |
|---|---|---|---|---|---|
| **ក** | **ពង្រឹងសមត្ថភាពមន្ត្រីរាជការនៃមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី** | | | | |
| ៦.ក.១ | បញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលនានា រៀបចំឡើងដោយក្រសួងទេសចរណ៍ និងអង្គការនានា ទាំងក្នុង និងក្រៅប្រទេស | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៦.ក.២ | បន្តបណ្តុះបណ្តាលគ្រូបង្គោលមន្ទីរ និងឯកជន | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៦.ក.៣ | លើកកម្ពស់ប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវរបស់មន្ត្រីការគោរពវិន័យការងារ សាមគ្គីភាព ការខិតខំបំពេញភារកិច្ចដែលប្រគល់ជូនបានទាន់ពេលវេលា និង ប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៦.ក.៤ | ពង្រឹងការអនុវត្តតួនាទីភារកិច្ចនិងបទបញ្ជាផ្ទៃក្នុងរបស់មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៦.ក.៥ | ពង្រឹងសមត្ថភាពមន្ត្រីក្របខណ្ឌនិងមន្ត្រីកិច្ចសន្យាតាមរយៈការចែករំលែកបទពិសោធន៍ការរៀនសូត្រនិងការបង្រៀនគ្នាទៅវិញទៅមក | មន្ទីរទេសចរណ៍ | | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| **ខ** | **ធនធានមនុស្សក្នុងឧស្សាហកម្មទេសចរណ៍** | | | | |
| ៦.ខ.១ | បណ្តុះបណ្តាលជំនាញអេកូទេសចរណ៍រួមមានមគ្គុទ្ទេសក៍ទេសចរណ៍ក្នុងសហគមន៍ ការរៀបចំផ្ទះស្នាក់ ម្ហូបអាហារ ការទទួលបដិសណ្ឋារកិច្ច និងការធានាសន្តិសុខ សុវត្ថិភាពភ្ញៀវ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ៦.ខ.២ | បើកវគ្គបណ្តុះបណ្តាល ជំនាញក្នុងការផ្តល់សេវាកម្មទេសចរណ៍ទៅដល់ប្រតិបត្តិករទេសចរណ៍ជាអាទិ៍ មានវគ្គ បដិសណ្ឋារកិច្ច មគ្គុទ្ទេសក៏ ទេសចរណ៍ គេហកិច្ច ការិយាល័យជួរមុខ សេវាកម្មម្ហូបអាហារ ភេសជ្ជៈ ផុងកាហ្វេ និងចុងភៅ | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៦.ខ.៣ | បើកវគ្គបណ្តុះបណ្តាល កសាងសមត្ថភាពជំនាញ<br><br>គ្រប់គ្រង និងផ្តល់សេវា ទេសចរណ៍ដល់បណ្តា សហគមន៍ទេសចរណ៍/ អេកូទេសចរណ៍ក្នុងខេត្ត | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៦.ខ.៤ | វាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាលថ្មីៗទៀត ស្របតាមតម្រូវការជាក់ស្តែង | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៦.ខ.៥ | ចុះពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងរមណីយដ្ឋាន | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៦.ខ.៦ | បើកវគ្គបណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធស្នើសុំអាជ្ញាបណ្ណទេស ចរណ៍តាមអនឡាញ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៦.ខ.៧ | ធ្វើការជំរុញឲ្យម្ចាស់អាជីវកម្មនៅក្នុងវិស័យទេសចរណ៍ចាត់បញ្ជូនបុគ្គលិកបម្រើសេវាកម្មទេសចរណ៍ចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗដែលរៀបចំដោយក្រសួង មន្ទីរឬអង្គការក្រៅរដ្ឋាភិបាល | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ៦.៤.៨ | បំផុសឲ្យមានការយល់ដឹងអំពីចលនាទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ នៅទូទាំងខេត្ត ព្រមទាំងជំរុញឲ្យមានការអនុវត្តលើការបម្រើសេវា និង បដិសណ្ឋារកិច្ចល្អ ក្នុងគោលបំណងរក្សានូវគុណភាពតម្លៃ សុខភាព សោភ័ណភាព និងបទពិសោធន៍ល្អសម្រាប់ភ្ញៀវ | គណៈកម្មាធិការ អភិវឌ្ឍទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| **៧. ការវិនិយោគក្នុងវិស័យឧស្សាហកម្មទេសចរណ៍** | | | | | |
| ៧.១ | រៀបចំគម្រោងអភិវឌ្ឍន៍សម្រាប់តំបន់សក្តានុពលមួយចំនួន និងស្វែងរកការ វិនិយោគ | មន្ទីរទេសចរណ៍ និងអាជ្ញាធរខេត្ត | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ៧.២ | រៀបចំចងក្រងតំបន់អេកូទេសចរណ៍សម្រាប់ផ្តល់លទ្ធភាពធ្វើអាជីវកម្ម និង វិនិយោគ | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ៧.៣ | ជំរុញ និងស្វែងរករាល់គម្រោងវិនិយោគខ្នាតធំ និងសហគមន៍ទេសចរណ៍/អេកូ ទេសចរណ៍ ( ខ្នាតតូច ) នៅគ្រប់តំបន់សក្តានុពល | គណៈកម្មាធិការ អភិវឌ្ឍទេសចរណ៍ | | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ៧.៤ | កៀរគរការចូលរួមរបស់អាជ្ញាធរ ស្ថាប័នជំនាញពាក់ព័ន្ធ ប្រតិបត្តិករទេសចរណ៍ និងដៃគូរអភិវឌ្ឍន៍ជុំវិញខេត្ត ក្នុងដំណើរការអភិវឌ្ឍទេសចរណ៍ | មន្ទីរទេសចរណ៍ និងអាជ្ញាធរខេត្ត | ✓ | | ថវិការដ្ឋ /ដៃគូរ/ ឯកជន |
| ៧.៥ | ស្វែងរកវិនិយោគិនទាំងក្នុង និងក្រៅប្រទេសឲ្យមកបណ្តាក់ទុនលើវិស័យ ទេសចរណ៍ក្នុងខេត្ត ពិសេសគម្រោង វិនិយោគទ្រង់ទ្រាយធំ និងប្រើបច្ចេកទេស ខ្ពស់ | គណៈកម្មាធិការ អភិវឌ្ឍទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ៧.៦ | លើកទឹកចិត្ត ព្រមទាំងផ្តល់ជំនួយបច្ចេកទេស និងផ្នែកច្បាប់ដល់សហគមន៍មូលដ្ឋានក្នុងការរៀបចំបង្កើតរមណីយដ្ឋានទ្រង់ទ្រាយតូច និងទេសចរណ៍សហគមន៍ | មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៧.៧ | ផ្តល់ព័ត៌មានទាក់ទងនឹងសក្តានុពលសម្រាប់គម្រោង អភិវឌ្ឍន៍ទេសចរណ៍ទៅដល់ វិនិយោគិន និងដៃគូអភិវឌ្ឍដែលចាប់អារម្មណ៍ | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៧.៨ | ចុះសិក្សា និងរៀបចំផែនការវិនិយោគ និងគម្រោងសំណើអភិវឌ្ឍន៍ទ្រង់ទ្រាយធំ មធ្យម និងតូចសម្រាប់បណ្តារមណីយដ្ឋាន និងទីតាំងដែល មានសក្តានុពល ដើម្បីដាក់ជូនវិនិយោគិនដែលចាប់អារម្មណ៍ និងដៃគូអភិវឌ្ឍន៍ដែលមានសក្តានុពល | មន្ទីរទេសចរណ៍ និងអាជ្ញាធរខេត្ត | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៧.៩ | តាមដានជម្រុញក្រុមហ៊ុនវិនិយោគរៀបចំអភិវឌ្ឍន៍រមណីយដ្ឋានទឹកជ្រោះប៊ូស្រា ជ្រៃយស អូរឆ្លាយ និងរមណីយដ្ឋាន រមនា១ | អាជ្ញាធរខេត្ត | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| **៨. ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ** | | | | | |
| ៨.១ | អភិរក្សធនធានវប្បធម៌ដែលមានស្រាប់របស់ខេត្តមណ្ឌលគិរីជាអាទិ៍របាំវប្បធម៌ ប្រពៃណីជនជាតិដើមភាគតិច | មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/ឯកជន |
| ៨.២ | អប់រំដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់ពីផលប៉ះពាល់អវិជ្ជមាននានាចំពោះបរិស្ថាននិងធនធានធម្មជាតិ | មន្ទីរបរិស្ថាន មន្ទីរទេសចរណ៍ | ✓ | | ថវិការដ្ឋ /ដៃគូរ/ឯកជន |

| | | | | | |
|---|---|---|---|---|---|
| ៨.២ | សហការរៀបចំឲ្យមានឆ្នាំការពារធនធានធម្មជាតិនៅតាមតំបន់រមណីយដ្ឋានសំខាន់ៗនៅក្នុងខេត្ត | មន្ទីរបរិស្ថាន<br>មន្ទីរទេសចរណ៍ | | ✓ | ថវិការដ្ឋ /ដៃគូរ/<br>ឯកជន |
| ៨.៣ | សហការដាំដើមឈើឡើងវិញនៅតាមតំបន់ទេសចរណ៍សំខាន់ៗក្នុងខេត្ត | មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ<br>មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/<br>ឯកជន |
| ៨.៤ | សិក្សា និងជ្រើសរើសតំបន់ដែលអាចរៀបចំជាសួនសម្រាប់ដាំ និងបណ្តុះកូនឈើបម្រើឲ្យភ្ញៀវទេសចរ | អាជ្ញាធរខេត្ត | ✓ | | ថវិការដ្ឋ /ដៃគូរ/<br>ឯកជន |
| ៨.៥ | ធ្វើសំណើទៅអាជ្ញាធរខេត្តនូវទីតាំងដាំកូនឈើសក្តានុពល ដែលបានសិក្សា ដើម្បីចូលរួមអភិរក្សធនធានធម្មជាតិ | មន្ទីរបរិស្ថាន | ✓ | | ថវិការដ្ឋ /ដៃគូរ/<br>ឯកជន |
| ៨.៦ | អប់រំផ្សព្វផ្សាយតាមរយៈស្លាកសញ្ញា រូបភាព អត្ថបទ និងមគ្គុទ្ទេសក៏ទេសចរណ៍ទៅដល់ភ្ញៀវ និងប្រជាសហគមន៍ ដើម្បីទប់ស្កាត់ការចម្លង វប្បធម៌បរទេស និងលើកតម្កើងការថែរក្សាវប្បធម៌ជនជាតិដើមភាគតិចឲ្យបានជាអតិបរមា | មន្ទីរទេសចរណ៍ | ✓ | ✓ | ថវិការដ្ឋ /ដៃគូរ/<br>ឯកជន |

# សេចក្តីថ្លែងអំណរគុណ

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍** ដែលបានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ និងណែនាំឱ្យមន្ទីរទេសចរណ៍រាជធានីខេត្ត រៀបចំ កសាងផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ និងសូមថ្លែងអំណរគុណជូនចំពោះ៖

| | | |
|---|---|---|
| ១. | ឯកឧត្តម **ទិត ចន្ថា** | រដ្ឋលេខាធិការប្រចាំការ នៃក្រសួងទេសចរណ៍ |
| ២. | ឯកឧត្តម **ថង សាវុន** | អភិបាលខេត្ត នៃគណៈអភិបាលខេត្តមណ្ឌលគិរី |
| ៣. | ឯកឧត្តម **កើត ពុទ្ធវីរៈ** | អនុរដ្ឋលេខាធិការ នៃក្រសួងទេសចរណ៍ |
| ៤. | ឯកឧត្តម **ថោង រដ្ឋសក្តិ** | អគ្គនាយក នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងទេសចរណ៍ |
| ៥. | លោក **ម៉ែន តារម្យ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងទេសចរណ៍ |
| ៦. | លោកស្រី **ទិន ស៊ីធួន** | អភិបាលរងនៃគណៈអភិបាលខេត្តមណ្ឌលគិរី ទទួលបន្ទុកការងារទេសចរណ៍ |
| ៧. | លោក **សាយ ម៉េងគីម** | អភិបាលរង នៃគណៈអភិបាលខេត្តមណ្ឌលគិរី |
| ៨. | លោក **ជួប វេតនា** | ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ |
| ៩. | លោក **នុត សុខា** | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ |
| ១០. | លោក **អ៊ុច លីណា** | ប្រធានការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍ |
| ១១. | លោក **ផន សុភ័ក្រ្ត** | ប្រធានការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍សៀមរាប និងតំបន់ជុំវិញ |
| ១២. | លោក **ម៉ុញ ទី** | ប្រធានការិយាល័យផែនការអភិវឌ្ឍន៍ទេសចរណ៍តំបន់ភូមិភាគឦសាន |
| ១៣. | លោក **កែន ពេញ** | មន្ត្រីនាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ |

ដែលជានិច្ចកាលតែងតែយកចិត្តទុកដាក់ក្នុងការណែនាំ គាំទ្រនិងជួយសម្រួលផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរី រហូតទទួលបានជោគជ័យ។

សូមគោរពជូនពរ **ឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត ឯកឧត្តម លោក លោកស្រី** សូមទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# ក្រុមការងាររៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍បច្ចុប្បន្នកម្ម ២០២១-២០២៥ ខេត្តមណ្ឌលគិរី

| | |
|---|---|
| ១. លោក **ខិន សុទិមាន** | ប្រធានមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី |
| ២. លោកស្រី **ម៉ី សារឹម** | អនុប្រធានមន្ទីរទេសចរណ៍ ទទួលបន្ទុកការិយាល័យ ផែនការ វិនិយោគ និងអភិវឌ្ឍន៍ផលិតផលទេសចរណ៍ |
| ៣. លោកស្រី **ម៉ុល រ័ត្នដេន** | អនុប្រធានមន្ទីរទេសចរណ៍ ទទួលបន្ទុកការិយាល័យគ្រប់គ្រង ឧស្សាហកម្មទេសចរណ៍ |
| ៤. លោក **លី ណាខិន** | ប្រធានការិយាល័យផែនការ វិនិយោគ និងអភិវឌ្ឍន៍ ផលិតផលទេសចរណ៍ |
| ៥. លោកស្រី **សុខ សុវណ្ណារ័ត្ន** | ប្រធានការិយាល័យរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងសន្តិសុខ សុវត្ថិភាពទេសចរ |
| ៦. លោក **នេត ម៉ូឌីណា** | ប្រធានការិយាល័យគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ |
| ៧. លោកស្រី **សេខ រីណា** | ប្រធានការិយាល័យអប់រំបណ្តុះបណ្តាល |
| ៨. លោកស្រី **នាង ឈុនម៉ា** | មន្ត្រីការិយាល័យព័ត៌មានទេសចរណ៍ និងផ្សព្វផ្សាយ ទេសចរណ៍ |
| ៩. លោកស្រី **តាន់ ស៊ាងមី** | មន្ត្រីការិយាល័យទីក្រុងស្អាត |





កម្ពុជា
ព្រះរាជាណាចក្រអច្ឆរិយៈ
ផ្តល់ភាពកក់ក្តៅ






**មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី**

ភូមិដោះក្រមុំ សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី

មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី